ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគម្រប់ពីរ

លេខ ២

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គូវែរណឺម៉ង់

គ្រិ. ឆ្នាំ ១៩២៧

ពុ. ស. ២៤៧០

អ្នកទទួលខុសត្រូវ ជុំ-មៅ

# បញ្ជីរឿង

ទំព័រ


១ សេចក្ដីពណ៌នាប្រារព្ធ របស់អ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យ . . . ៨៥

២ សេចក្ដីពណ៌នាមរណកិច្ច របស់ព្រះមហាវិមលធម្ម ថោង ចាងហ្វាងសាលាបាលីជាន់ខ្ពស់, ព្រះគ្រូវិមលបញ្ញា អ៊ុម ស៊ូ អាចារ្យព្រះរាជបណ្ណាល័យកម្ពុជា ជាអ្នករៀបរៀង . . . . . . . . ៨៩

៣ សេចក្ដីថ្លែងគុណ ព្រះមហាវិមលធម្ម ថោង ព្រះគ្រូសំឃវិជ្ជា ហ. ពាត អាចារ្យបង្រៀនភាសាសំស្ក្រឹត នៅសាលាបាលីជាន់ខ្ពស់អធិប្បាយ . . . ១០៦

៤ សេចក្ដីប្រកាសគុណបជិការ របស់ព្រះមហាវិមលធម្ម ថោង ព្រះគ្រូសំសត្ថា ជ. ណាត អាចារ្យនៅសាលាបាលីជាន់ខ្ពស់ពណ៌នា . . . ១១៦

៥ គុណូបការានុស្សរណសច្ចកិរិយា របស់ព្រះមហាវិមលធម្ម ថោង ព្រះញាណបវរវិជ្ជា អែម អាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់អធិប្បាយ . . ១៣២

៦ គុណកថា របស់ព្រះមហាវិមលធម្ម ថោង ព្រះពុទ្ធវង្ស ម៉ី អាំងស្ប៉ិកទ័រត្រួតត្រាការសិក្សាបឋមវិជ្ជាប៉ែកខាងជើង រៀបរៀង . . . . ១៤២

៧ សេចក្ដីពណ៌នាកិត្តិគុណ របស់ព្រះមហាវិមលធម្មថោង ព្រះញាណវិរិយឡុង អាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់ ជាអ្នកតែង . . . ១៥៦

៨ កិត្តិគុណកថា របស់ព្រះមហាវិមលធម្ម ថោង អាចារ្យ អិត ហ៊កគ្រូបង្រៀនក្នុងសាលាបាលីជាន់ខ្ពស់ពណ៌នាសរសើរ . . . . ១៦៣

៩ កតវេទិកថា ឧកញ៉ាភក្ដីរាជា យ៉ុង សម្ដែងរៀបរាប់អំពីគុណូបការ និងគុណសម្បត្តិនៃព្រះមហាវិមលធម្ម ថោង .. . . . . ១៨៥

១០ កល្យាណមិត្តកថា ឧកញ៉ាសុធម្មប្រីជា កង អាចារ្យសាលាបាលីជាន់ខ្ពស់ពណ៌នាអំពីគុណសម្បត្តិព្រះមហាវិមលធម្ម ថោង. . . . ១៩៣

១១ វណ្ណកិត្តិគុណកថាព្រះធម្មបិដកវិជ្ជា ហឹម អាំងស្ប៉ិកទ័រត្រួតត្រាការសិក្សាបឋមវិជ្ជាប៉ែកខាងត្បូង ពណ៌នាសរសើរគុណព្រះមហាវិមលធម្មថោង . ២០៦

១២ សេចក្ដីសូត្ររំឭកគុណ ឧទ្ទិសផលចំពោះព្រះមហាវិមលធម្មថោង ក្នុងវេលាដែលអ្នករាជការក្នុងព្រះរាជបណ្ណាល័យ វេរភត្តប្រគេនដល់សង្ឃ . ព្រមការ ជុំ-មៅ ធ្វើរាជការនៅព្រះបណ្ណាល័យ អធិប្បាយ . . ២១៦

# សេចក្ដីប្រារព្ធ

ទស្សនាវដ្ដីខ្មែរនេះ យើងឧទ្ទិសសេចក្ដីទាំងមូល ចំពោះដល់លោកគ្រូព្រះសព ព្រះមហាវិមលធម្ម រឿង ល្អង នាមដើម ៖ ថោង ជាមហាបរិយត្តិនាយក និង ជាក្រុមជំនុំប្រឹក្សាការព្រះរាជបណ្ណាល័យផង ដែលលោកទទួលអនិច្ចធម្ម ទៅកាន់បរលោកកាលពីថ្ងៃ ២ គ្ហិតឆ្នាំ ១៩៦៧ ក្នុងកំណត់ព្រះជន្មាយុគម្រប់ ៦៥ ឆ្នាំ នៅនាទីកុដិរបស់លោកក្នុង វត្តឧណ្ណាលោមក្រុងភ្នំពេញ ។ សេចក្ដីឧទ្ទិសនេះ ជាការគោរពដោយស្មោះ ដល់ឧបត្ថម្ភកានុស្សរណកិច្ច របស់លោក ។

សេចក្ដីមរណៈនេះធ្វើឲ្យព្រះរាជបណ្ណាល័យ ខាតកល្យាណមិត្ត ១ ដែលមានសតិបញ្ញា និងស្មារតីជ្រៅទូលាយ ហើយស្មោះទៅកាន់សេចក្ដីចម្រើន កល្យាណមិត្តនេះ បាននាំផលប្រយោជន៍មកផ្គត់ផ្គង់ ព្រះរាជបណ្ណាល័យជាច្រើន ដើម្បីឲ្យប្រព្រឹត្តលឿនជានិច្ចទៅមុខ ។

ជាតិបារាំងទាំងឡាយ ដែលបានមកនៅធ្វើរាជការជិតលោកនោះ និងមិនភ្លេចឡើយ ថាលោកមានព្រះហឫទ័យឈឺឆ្អាលជួយសម្រួលការឲ្យបានស្រួលដល់គ្នា ជាច្រើនដងណាស់ ព្រមទាំងបានជួយរឹតបំណងមេត្រីក្នុងផ្លូវសតិបញ្ញា ដែលក្រុងបារាំងសេស និងក្រុងកម្ពុជាមានទៅវិញទៅមកសព្វថ្ងៃនេះផង ជាតិបារាំងទាំងនេះ ក៏ចូលកាន់នូវមរណសញ្ញាមួយអន្លើដោយសិស្សានុសិស្សទាំងប៉ុន្មានរបស់ព្រះមហាថេរនេះ ។

ស៊ុយសានការ៉ីប្លែស

# ប្រកាស

សៀវភៅទស្សនាវដ្ដីខែ ២ នេះ ជាសៀវភៅប្លែកបន្ទោះពីធម្មតា មានចំនួនទំព័រជាច្រើនលើសខែឯទៀត នាំឲ្យព្រះរាជបណ្ណាល័យបង្កើនថ្លៃសៀវភៅនេះឡើងទើបបានមិនខាត តែថាបណ្ដាជនឯណា ដែលបានចុះឈ្មោះយកកំណត់ ១ ឆ្នាំ ៗ នោះ យើងមិនបង្កើនថ្លៃឡើយ គឺឲ្យនៅនឹងដដែល ។

បណ្ដាជនឯណាដែលមិនបានចុះឈ្មោះទិញកំណត់១ ឆ្នាំ ហើយត្រូវការចង់មើលខែនេះ ដោយមានសេចក្ដីពណ៌នាអំពីគុណធម៌ និងគុណូប-ការ របស់លោកគ្រូព្រះមហាវិមលធម្ម ថោង ទាំងអស់នោះ អាចនឹងទៅរកទិញបានក្នុងព្រះរាជបណ្ណាល័យ ថ្លៃ ១ ក្បាល ១ រៀល យើងបម្រុងទុកនឹង លក់ជូនអស់លោក-អ្នក ២០០ ក្បាល ធ្វើមុខផ្សេងគ្នាពីទស្សនាវដ្ដី តែឯសេចក្ដីដូចគ្នាទាំងអស់ ។

# សេចក្ដីពណ៌នាមរណកិច្ច

របស់ព្រះមហាវិមលធម្ម ថោង ចាងហ្វាងសាលាបាលីជាន់ខ្ពស់

ក្រុងភ្នំពេញ

ព្រះគ្រូវិមលបញ្ញា អ៊ុម ស៊ូរ អាចារ្យព្រះរាជបណ្ណាល័យកម្ពុជា

ជាអ្នករៀបរៀង

# សេចក្តីពណ៌នាមរណកិច្ច

អំពីអាការរោគ និង ពាក្យបណ្តាំ និង មរណកិច្ចរបស់

ព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម ព្រះនាម ថោង

ខ្ញុំនឹងរាប់រៀប ពីសេចក្តីឈឺចាប់របស់លោក ជម្រាបអស់លោកអ្នកទាំងឡាយ មិនបានមកមើល មកឃើញចំពោះនឹងភ្នែកគ្រប់គ្នាឲ្យជាក់ស្តែង កាលដែលលោកជុរៈនោះ ដោយខ្ញុំនឹកស្មានថាប្រហែលជាអ្នកទាំងអស់គ្នា នឹងមានបំណងចង់ដឹងការនេះដោយពិតប្រាកដមិនខាន ព្រោះព្រះតេជព្រះគុណនេះ លោកជាមនុស្សមានគុណនឹងពុទ្ធសាសនាដោយច្រើន ដូចយើងបានដឹង ៗ មកយូរឆ្នាំហើយ គឺលោកមានកិច្ចតែម្យ៉ាង គ្រង់សង្គ្រោះទំនុកបំរុងពុទ្ធសាសនានោះឯង ។

ខុសអស់អ្នកទាំងឡាយយើងគួរសំវេគពេកណាស់ ព្រះតេជព្រះគុណ ព្រះមហាវិមលធម្មនេះ លោកជាអ្នកមិនសូវដែលមានរោគអ្វីមួយ ឲ្យជាធំមាំមួន មកពាល់ត្រូវអង្គកាយរបស់លោកសោះឡើយ លោកប្រកបដោយសេចក្តីសុខកាយ នោះជាច្រើនណាស់ ប្លែកពីគេទាំងពួងខ្លះ តែក្នុងសម័យនេះ លោកមកប្រទះនឹងសេនាយោធារបស់ស្តេចអន្តករាជ មកព័ទ្ធព័ទ្ធជិតជុំវិញអង្គលោកហើយ តោមចាប់ចំពោះត្រង់ដួងវិញ្ញាណ ដែលជាគ្រឿងរសនៅរបស់លោក នឹងជាទីរាប់អានរបស់យើងពល់គ្នានាំយកចេញទៅ អំពីទីចំពោះមុខពួកបរិស័ទដែលជាកូនសិស្ស ឥតមានកោតញញើត ឬ ករុណាមេត្តាអ្វីសោះឡើយ ហើយនិងរកអ្នកណា ១ ជួយ

អន្ទរប្ដូយឃាត់ដោយពាក្យទន់ពិរោះឬដោយសំដីបោះបោកទៅកេរគេនោះ គ្មានសោះឡើយ ឃើញមានតែនាំគ្នាផ្គុំស្រោមដៃសំពះទៅខាងលើ ហើយក្រឡេកមើលមុខគ្នាទៅវិញទៅមក ដោយសេចក្ដីទោរទន់តាមទស្សតែពល់គ្នា នឹងរកអ្នកណា ១ ជាអ្នកមានបញ្ញាកសនាប្រកបដោយឧបាយកលអាចដោះស្រាយ និងទប់ទល់អំណាចអាជ្ញា ឬលោះដូរដោយទ្រព្យសម្បត្តិអ្វីនីមួយក៏គ្មានដល់ម្នាក់ឡើយ នៃអ្នកសប្បុរសទាំងឡាយ មច្ចុរាជនេះ មិនមែនមកបួនយក ចំពោះតែដួងចិត្តជីវិតរបស់លោក ១ អង្គនេះទេ ដោយយើងជឿប្រាកដ ថាមុខជានឹងមកប្រហារផ្ដាច់ផ្ដិលជីវិតិន្ទ្រិយអាយុសង្ខារ លួចឆក់ឆ្លក់យកទ្រព្យតម្លៃ គឺដួងហឫទ័យរបស់យើងពល់គ្នាទៀតមិនខានឡើយ ព្រោះស្ដេចនេះឯងជាធំផុតពេកណាស់ ជាម្ចាស់ជីវិតលើស្ដេចទាំងឡាយ មានស្ដេចចក្រពត្រាធិរាជ និងស្ដេចទេវតា ដែលមាននាមថាព្រះឥន្ទ្រ ព្រះព្រហ្ម ទាំងអស់ ដែលជាអ្នកមានបុណ្យមានអានុភាពច្រើន កុំបាច់និយាយទៅថ្វីដល់យើងពល់គ្នា ដែលជាសត្វសាធារណៈទាំងពួងនេះ នឹងរកទីពួនទីជ្រកឲ្យកំបាំងពីស្ដេចនេះដូចម្ដេចបានៗ

ព្រះតេជព្រះគុណនេះ កាលដែលលោកជួបប្រទះតទល់នឹងសត្រូវ គឺមរណសង្គ្រាមនោះ វេលាយប់ម៉ោង ១២ ឯអធ្រាត្រ ថ្ងៃច័ន្ទ ៤ រោចខែអាសាធ ឆ្នាំថោះនព្វស័ក ឯពួកបច្ចាមិត្រនេះ កាលដើមដំបូងឡើយរាចូលមកចាប់បានត្រង់ឧទរលោក គឺធ្វើឲ្យទល់, ឆ្អល់, ចង្អោរ, អត់អាហារប្រមាណ ៣ ថ្ងៃ ទើបយើងខ្ញុំពល់គ្នាទៅអញ្ជើញលោក ដុកទ័រ គ្រូពេទ្យ

មកដាក់ថ្នាំបញ្ចុះ ថ្នាំនោះក៏ពូកែធុតឆាប់ណាស់ដែរ អាចកែរោគនោះឲ្យចុះរាកចូរទៅបានដូចប្រាថ្នា បាត់ផ្លូវវេទនា ១ បំពូកនៅតែបង្អោរនៅឡើយ ទើបគ្រូពេទ្យឲ្យលេបថ្នាំកែបង្អោរនោះទៅ ក៏បានបាត់វេទនានោះដូចគ្នា នៅតែអត់អាហារ នឹងអាចលេបចូលពុំរួចសោះឡើយ ឯយើងរាល់គ្នាមើលទៅកម្លាំងរោគនោះ ឃើញថាគួរតែវេទនា តែដល់បានពិតសួរលោកទៅ លោកក៏មានពុទ្ធដីកាប្រាប់ថាមិនមានឈឺអ្វីទេ កុំឲ្យព្រួយវាគ្រាន់តែអស់កម្លាំងម្យ៉ាងប៉ុណ្ណឹងទេ បើបានបាយឬបបរបន្តិចចូលទៅ នឹងមានកម្លាំងជាហើយ លុះដល់ថ្ងៃទី ៤ ទី ៥ ក្នុងវេលា ១ នោះលោកគ្រូព្រះញាណបវរវិជ្ជា អែម លោកក៏ចូលទៅជិតទៀបអង្គលោក ទើបព្រះតេជព្រះគុណលោកប្រាប់ថា លោកខ្ញុំមានចិត្តត្រេកអរណាស់នឹងលោកដែលខំមើលរោគខ្ញុំនេះ ប្រហែលជាលោកនឹកស្មានថា ការនេះជាការដំមាំមួនលើខ្លួនលោកណាស់ហើយ តែមិនដូចនោះទេ ធម្មវិន័យដែលជាតួពុទ្ធសាសនាឯណោះ ទើបជាគុណដំបំផុតរកគុណអ្វីឲ្យត្រឹមស្មើពុំបាន ចូរលោកយកចិត្តទុកដាក់ខំបង្ហាត់បង្រៀន ធម្មវិន័យ ដល់ភិក្ខុសាមណេរឲ្យច្រើនជាធុរៈរបស់ខ្ញុំនេះចុះ ហើយទើបលោកគ្រូព្រះញាណបវរវិជ្ជាពិតតបទៅវិញថា ខ្ញុំព្រះករុណាមិនធ្វេសប្រហែសទេ សូមព្រះតេជព្រះគុណកុំព្រួយឡើយ ដល់ថ្ងៃទី ៦, ទី ៧, ទី ៨, ទី ៩, ទី ១០, ពួកលោកដែលជាកូនសិស្សដែលមានបណ្តាសក្តិធំតូចជាច្រើនរូប មានលោកគ្រូព្រះពុទ្ធវង្ស ម៉ី ព្រះវិនយធរ [illegible] ព្រះញាណបវរវិជ្ជា អែម ព្រះ

អមរមូលី ឈឹង ព្រះបាឡាត់សំវិជ្ជា មៀង ព្រះគ្រូសំសត្ថា ឈាត ព្រះគ្រូសំវិជ្ជា តាត ព្រះមហា លុង ព្រះមហា ជេត្រ ព្រះគ្រូធម្មវិជ្ជា ជា ព្រះបាឡាត់ធម្មបតី ប៉ុក ព្រះបាឡាត់អរិយកិមល ប៉ែង ជាដើមហើយនិងសិស្សានុសិស្សទាំងឡាយច្រើនរូប មកប្រជុំគិតគ្នាថា ឯអាការពេតនេះ មើលទៅរកថយគ្មានទេ បើដូចនេះយើងត្រូវនាំគ្នា ចម្រើនព្រះបរិត្តជាពុទ្ធមន្តយ៉ាងវិសេសប្រគេនលោកទៅ លុះព្រមគំនិតគ្នាហើយទើបបានចូលទៅជិតលោកថា យើងខ្ញុំទាំងអស់គ្នាមានបំណងនឹងចម្រើនពុទ្ធមន្ត ដើម្បីជាឧសថទិព្វប្រគេន ព្រះតេជព្រះគុណ លោកក៏ព្រមហើយមានពុទ្ធដីកាថា ខ្ញុំអរណាស់ ដែលលោកពលអង្គគិតយ៉ាងហ្នឹង ប៉ុន្តែសូមឲ្យលោកសូត្រចម្រើនព្រះសត្តពោជ្ឈង្គត្រង់ចុន្ទបរិត្តសូត្រ ឲ្យខ្ញុំស្តាប់ជាមុន ព្រោះខ្ញុំចេះតែនឹករឿយ ៗ ពេកណាស់ត្រង់ព្រះបរិត្តសូត្រនោះ ទើបយើងទាំងឡាយបានរៀបចំសូត្រ ពុទ្ធមន្តបាននិមន្តលោក ៧ អង្គមានលោកគ្រូសំសត្ថា ឈាត ជាដើម តាំងសូត្រចម្រើនព្រះសត្តពោជ្ឈង្គតាំងអំពីដើមរហូតដល់ចប់ ទើបព្រះគ្រូសំសត្ថា ឈាត លោកតាំងសូត្រឧទ្ទិសផលកសីជាគាថា ដែលលោកបានតែងទុកមកក្នុងពេលមុនបន្ទាប់នេះបន្តិច ប្រគេនដល់លោក ៗ ក៏មានសោមនស្សត្រេកអរ បានទាំងទទួលអំណរថា៖ សាធុ ខ្ញុំពេញចិត្តពេកណាស់លោក ឯសេចក្តីឧទ្ទិសនោះដូចមានក្នុងគាថានោះស្រាប់ រួចហើយទើបលោកគ្រូព្រះញាណបវរវិជ្ជាអែម លោកតាំងសូត្រប្រកាសសច្ចកិរិយារបស់លោកដូចមានក្នុងសេចក្តី

សច្ចកិរិយារបស់លោកនោះស្រាប់ លុះចប់វេលាណា ហើយលោកក៏ទទួលសាធុយ៉ាងខ្លាំង ដោយសេចក្ដីត្រេកអររបស់លោក តពីនោះមកទើបលោកគ្រូព្រះពុទ្ធវង្ស ម៉ី តាំងប្រកាសគុណកថារបស់លោកប្រគេនលោក ដូចមានក្នុងសេចក្ដីគុណកថារបស់លោកនោះស្រាប់ លុះចប់ហើយ អគ្គលោកក៏តាំងសោមនស្សរាំពា ទទួលអនុមោទនាថាសាធុ ៗ តមកទើបលោកគ្រូវិន័យធម៌ ពោធ លោកក៏តាំងប្រកាសពាក្យសច្ចរបស់លោកប្រគេន លុះចប់ហើយ លោកក៏សាធុទទួលយក រួចហើយទើបខ្ញុំបាទតាំងប្រកាសសច្ចរាំពា ជាជំនួសតំណាងអស់លោកកូនសិស្សជាអ្នកបួស និង គ្រហស្ថទាំងឡាយដែលមកជួបជុំក្នុងសម័យនោះថា សូមពិតព្រះតេជព្រះគុណ ត្បិតអស់លោកទាំងអស់គ្នានិងខ្ញុំព្រះករុណា មានសេចក្ដីព្រួយ នឹងអាការពេកដែលកើតមានក្នុងអង្គកាយ ព្រះតេជព្រះគុណនោះ ជាទីបំផុតពេកណាស់ពាល់គំនិតប្រាជ្ញា នឹងរិះរកកលឧបាយណាមករំដោះបន្សាបនូវសត្រូវនោះពុំបានឡើយ ឃើញនៅមានតែគុណម៉្យាងដែលជាទីកំបាំង ដែលអ្នកប្រាជ្ញទាំងឡាយអំពីបូរាណ លោកតែងអំពាវនាវរកមកជាទីពឹង ក្នុងពេលដែលមានភ័យធំជាទីបំផុតនោះ ឯគុណនោះមិនគឺអ្វី គឺសេចក្ដីសច្ចៈពិតត្រង់នោះឯង ។

ក៏ឥឡូវនេះយើងខ្ញុំទាំងអស់គ្នាសូមសច្ចាថា ធម្មទានឬអាមិសទាន ឯណាដែលយើងខ្ញុំបានធ្វើហើយ ដោយចិត្តសទ្ធាជ្រះថ្លា សីលឯណា ដែល

ព្រះមហាវិមលធម្មអ្នកនេះដល់ខ្ញុំមានអាយុ ២ ឆ្នាំ បានបំពេញឧបសម្បទ ជាភិក្ខុភាវ នាមបញ្ញត្តិជាព្រហ្មជោត, សម្តេចព្រះមហាសង្ឃរាជ ជាព្រះឧបជ្ឈាយ៍ ព្រះមង្គលទេពាចារ្យ ព្រះនាម ជុំ ក្រុយ ព្រះបាឡាត់សង្ឃវង្សព្រះនាមដើម សុខ ជាឧបសម្បទាចារ្យ ហើយខ្ញុំសូមក្រាបថ្វាយបង្គំលាសម្តេចព្រះមហាសង្ឃរាជ មកនៅកុដិជាមួយនឹងលោក តាំងអំពីលោកទទួលទី ជាព្រះគ្រូសំសត្ថា ព្រះបាឡាត់សង្ឃវិជ្ជា ជាឋានានុក្រមៗ

កាលដែលខ្ញុំចូលទៅជាសទ្ធិវិហារិកលោកនោះ លោកមានសេចក្តីកប់អានអាណិតអាសូរករុណា បានឲ្យអានគ្រឿងបរិក្ខារ មានត្រៃចីវរជា-ដើម ព្រមទាំងអាហារបរិភោគ ពុំដែលឲ្យមានខ្វះឡើយ ហើយលោកបានបង្ហាត់បង្រៀនឲ្យសិក្សា សម្តែងធម៌ទេសនា អធិប្បាយធម៌អាថ៌សិក្ខាវិន័យ តាមក្បួនគម្ពីរព្រះត្រៃបិដក ដែលបានរៀនរួចហើយពុំទាន់យល់សេចក្តី អធិប្បាយច្បាស់លាស់ឲ្យជ្រួលចិត្ត ឃើញជាក់ច្បាស់ប្រាកដឡើង មិនតែប៉ុណ្ណោះ លោកបានទំនុកបម្រុង ឲ្យធ្វើជាអាចារ្យបង្រៀនព្រះបរិយត្តិធម៌ភិក្ខុ-សាមណេរ ឲ្យរៀនប្រែមូលវិជ្ជាព្រមទាំងគម្ពីរផ្សេង ១ ជាដំណាងព្រះអង្គលោក ហើយលោកបានប្រើខ្ញុំឲ្យទៅជាវគម្ពីរព្រះត្រៃបិដកឯស្រុកបាងកក ខ្ញុំក៏បានទៅតាមបង្គាប់លោក ជាវបានគម្ពីរ ព្រះសូត្រខ្លះ ព្រះវិន័យខ្លះ ព្រះអភិធម្មខ្លះ ចំនួន ៥៨ គម្ពីរ នាំមកតម្កល់ទុកក្នុងកុដិលោកសព្វថ្ងៃនេះ លុះខ្ញុំបួស បាន [illegible] វស្សា បានសុំ

លាចាកសិក្ខាបទមកជាឃរាវាសបានប្រមាណ ១ ឆ្នាំ នោះមានសៀ ហ៊ី-ណូត៍ ជាចាងហ្វាងសាលាបាលីពិសេស អេកស្ត្រែមអូរីយ៉ង់ បានយកខ្ញុំទៅធ្វើការ ឯស្រុកហាណូយបាន ២ ឆ្នាំ ៦ ខែ ដល់លោកហ៊ីណូត៍អញ្ជើញទៅស្រុកបារាំងទៅ ខ្ញុំក៏ត្រឡប់មកស្រុកភ្នំពេញវិញ បានប្រមាណ ១ ឆ្នាំ ៦ ខែ នោះ រាជការលោកជាធំសព្វថ្ងៃ បានរើសយកអ្នកចេះអក្សរសៀមចេះ ភាសាសៀមស្ទាត់ យកទៅធ្វើការខេត្តមឿងក្រាត កោះកុង នោះរាជការបានតាំងខ្ញុំឲ្យធ្វើជាទីបាឡាត់ខេត្តក្រាត ដល់រាជការយកមឿងក្រាតថ្វាយខេត្តបាត់ដំបង-សៀមរាប មកជាអាណាខេត្តនគរកម្ពុជាវិញ នោះខ្ញុំបានធ្វើជាបាឡាត់ស្រុកស្រែខ្ទម ក្នុងខេត្តក្រចេះ ហើយផ្លាស់ពីស្រែខ្ទមទៅធ្វើជាបាឡាត់ខេត្តគងពិសី ផ្លាស់ពីគងពិសីទៅធ្វើបាឡាត់ខេត្តស្ទឹងត្រែង ធ្វើបានប្រហែល ៣ ឆ្នាំ ដល់រាជការ តាំងបង្កើតឲ្យមានសាលាបាលីពីឆ្នាំ ១៩១៤ នោះ លោកគ្រូព្រះមហាវិមលធម្ម លោកបានឲ្យខ្ញុំចូលប្រឡងវិជ្ជាខាងភាសាបាលី ធ្វើជាអាចារ្យខ្ញុំក៏បានចូលប្រឡង បានជាប់លេខជាបានការទី ១ ក៏បានធ្វើជាអាចារ្យ ក្នុងសាលាបាលីរៀងរាបមក ដល់ថ្ងៃអង្គារ ៤ កើតខែស្រាពណ៍ ឆ្នាំថោះនព្វស័ក ត្រូវនឹងថ្ងៃ ៣ ខែអ៊ូត ឆ្នាំ ១៩២៧ លោកក៏ទទួលអនិច្ចធម្មកន្លងទៅ ត្រូវជា ១៤ ឆ្នាំមកហើយ ពុំដែលមានសេចក្ដីសៅហ្មងបន្តិចបន្តួចឡើយ ។

ហេតុដែលខ្ញុំមានចំណេះវិជ្ជា ហើយនឹងសក្តិយសទាំងនេះ គឺពី

ព្រោះដែលលោកយកព្រះហឫទ័យទុកដាក់ ខិតខំបង្ហាត់បង្រៀនឲ្យខ្ញុំបាន ចេះដឹងនាំឲ្យមាន ប្រយោជន៍ពីរប្រការគឺ: ប្រយោជន៍ក្នុងលោក ១ ប្រយោជន៍ក្នុងបរលោក ១ មុខគួរខ្ញុំស្តាយស្រណោះ លោកជាធម្មាចារ្យ របស់ខ្ញុំ ទីងរកអ្វីថ្លឹងពុំបាន ព្រោះលោកមានគុណឧបការដល់រូបខ្ញុំជា សិស្ស ជាខ្លាំងពន់ពេកណាស់ ។

តែជាសត្វកើតមកក្នុងភពវដ្តសង្សារ ពុំដែលឃើញសត្វណាមួយឲ្យ រួចផុតអំពីសេចក្តីស្លាប់សេចក្តីកើតនេះបានឡើយ មានតែព្រះនិព្វានទើប រួចផុតអំពីធម៌ទាំងពីរគឺ កើតនិងស្លាប់, កើតនិងស្លាប់ជាគូនឹងគ្នាតែ មានជាតិគឺកំណើត មុខជាមានមរណៈ គឺសេចក្តីស្លាប់មិនខាន ។

ប្រៀបដូចជាព្រះអាទិត្យ តែរះឡើងហើយទៀងតែនឹងលិចទៅវិញ ជាធម្មតាមិនខាន ។

ហេតុនេះគួរយើងខំឧស្សាហ៍ធ្វើទានកុសល ចម្រើនការនាជា ឧបនិស្ស័យ ទើបនឹងបានព្រះនិព្វានជាបរមសុខប្រាសចាកទុក្ខមាន ជាតិជាដើម មានមរណៈជាបរិយោសាន, ហេតុនោះមានបាលីក្នុងគម្ពីរ បឋមសម្ពោធិកថា មានដើមថា ៖

ឃរំអនិច្ចតំជម្មំ ញត្វា ទុរភិសម្ភវំ
តំបត្តាភយមេជីភោ យំនិច្ចំអមតំបទន្តិ

ប្រែថា លោកជាអ្នកប្រាជ្ញបានជ្រាបច្បាស់ណាស់នូវអនិច្ចតាធម៌នេះ

ថាជាធម៌លាមកអាក្រក់ជាងធម៌ទាំងអស់ កម្រក្រៃក្រសត់ណាទឹងអាចកន្លងបានដោយងាយ យ៉ាងដូចនេះហើយ អមតធម៌គឺព្រះនិព្វាន ឯណាជាធម៌ទៀង គឺមិនកើតមិនស្លាប់ គប្បីព្យាយាម ដើម្បីដល់នូវព្រះនិព្វាននោះឯង ។

កាលព្រះបរមសាស្ដាជាម្ចាស់ទ្រង់ផ្ទំលើគ្រែខ្ទង ជាឧដ្ឋានសយាដែលព្រះអានន្ទត្ថេររៀបថ្វាយ យកព្រះសិរសាទៅទិសឧត្តរព្រះភក្ត្របែរទៅទិសបស្ចិម ក្នុងទីជាចន្លោះដើមរាំងទាំងគូ ក្នុងនគរកុសិនារា នោះព្រះអង្គទ្រង់សម្ដែងធម៌ប្រារព្ធចំពោះនូវព្រះអានន្ទត្ថេរថា ៖

អនិច្ចា វត សង្ខារា     ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ     តេសំ វូបសមោ សុខោតិ

ប្រែថាសង្ខារធម៌ទាំងឡាយ ទោះជាឧបាទិន្នសង្ខារ គឺរូបសត្វទាំងអស់ក្ដី អនុបាទិន្នសង្ខារ គឺវត្ថុមានដែនដីជាដើមទាំងអស់ក្ដី សឹងតែជារបស់មិនទៀងទាត់ចិតប្រែប្រួលពិតណាស់ សង្ខារធម៌ទាំងឡាយមានកិរិយាកើតឡើងហើយ ទឹងវិនាសទៅជាបការ តែកើតឡើងហើយទឹងវិនាសទៅពុំខានមានតែព្រះនិព្វានជាធម៌រម្ងាប់សង្ខារទាំងឡាយ អាចនាំមកនូវសេចក្ដីសុខ ក្រៃលែងជាងសុខដទៃ ។

ឯសេចក្ដីគុណសម្បត្តិរបស់លោកនោះ គឺលោកមានព្រះហឫទ័យរាប់អានខ្ពស់ចំពោះភិក្ខុក្ដី សាមណេរក្ដី កុមារក្ដី បណ្ដាដែលជាសិស្ស

ក្នុងកុដិក្តី ក្រៅកុដិក្តី លោកតែងមានពាក្យពីរោះពៀរេក ពុំមានពាក្យជា ផរុសវាចាដល់តិចឡើយ ។

ម្យ៉ាងទៀតគុណសម្បត្តិរបស់លោក គឺលោកចេះព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកចាំមួនប្រាកដណាស់ ទីងរកលោកអ្នកប្រាជ្ញណាឲ្យចេះជាងលោកក្នុងកាលឥឡូវនេះ ឥតមានឡើយ ហើយលោកខំព្យាយាមខំបង្ហាត់បង្ហាញសិស្សឲ្យបានចេះដឹង ព្រោះធ្វើជាគ្រូអាចារ្យគេតទៅទៀតសឹងមានច្រើនរូបណាស់ ហើយលោកមានប្រាជ្ញាអាចឈ្លាសវៃក្នុងព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ទាំងទំនៀមទម្លាប់ខាងឯអាណាចក្រ ទាំងអក្សរសៀម ទាំងភាសាសៀម អក្សរលង្ការ អក្សរភូមា ជាបាលីលោកក៏ចេះស្ទាត់ ហើយលោកបានប្រែរៀបរៀងធម៌វិន័យ ចេញពីគម្ពីរព្រះត្រៃបិដកមកជាសម្រាយ សម្រាប់ទុកឲ្យភិក្ខុសាមណេរ ឧបាសកឧបាសិកា រៀនសូត្រជាផ្លូវបដិបត្តិយកមគ្គផល ទៅខាងអនាគតកាលក៏សឹងមានច្រើនបែប ច្រើនឈ្មោះ ដូចមានសៀវភៅ អនាគារវិន័យជាដើម ។

មិនតែប៉ុណ្ណោះ លោកបានជួលកេងពុម្ព បោះពុម្ពផ្សាយចេញដល់ ២.០០០ ច្បាប់ ដោយលោកពុំមានសេចក្តីកំណាញ់ ចង់ទុកទ្រព្យសម្បត្តិឲ្យមានច្រើន ដូចលោកទាំងពួងទេ ។

សេចក្ដីខ្ញុំពោល ពណ៌នារៀបរប់គុណឧបការ លោកគ្រូព្រះសព្វ ព្រះមហាវិមលធម្មថាន់ហ្វាន់សា លាបាលី ដោយសេចក្ដីសង្ខេបតែប៉ុណ្ណោះ បើនឹងពោលដោយពិស្ដារ ក៏មានសេចក្ដីអធិប្បាយច្រើនតទៅទៀត ៗ

## កល្យាណមិត្តកថា

---

# របស់ឧកញ៉ាសុធម្មប្រីជា ភខ

*អាចារ្យសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ*

# ពណ៌នាពីគុណសម្បត្តិរបស់ព្រះមហាវិមលធម្ម នាម ថោង

*ចាងហ្វាងសាលាបាលីជាន់ខ្ពស់*

# កល្យាណមិត្តកថា

ព្រះមហាវិមលធម្ម នាមដើម **ថោង** ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ជាស្មៀនហ្វាងក្រសួងសង្ឃផង បិតាឧកញ៉ាពិតក្ដិកវី រ័តន៍ មាតាឈ្មោះ ទាវ កើតនៅភូមិកំពង់ផែ ក្រុងភ្នំពេញ នៅថ្ងៃព្រហស្បតិ៍ ១៣ កើតខែចេត្រ ឆ្នាំកុរបញ្ចស័ក ត្រូវនឹងឆ្នាំ ១៨៦៣ ពុទ្ធសករាជ ២៤០៦ លោកទទួលអនិច្ចធម្មនៅថ្ងៃអង្គារ ១៤ កើត ខែស្រាពណ៍ ឆ្នាំថោះនព្វស័ក ត្រូវនឹងថ្ងៃ ២ ខែអ៊ូត ឆ្នាំ ១៩២៧ នៅវេលាយប់ ម៉ោង ២, ១០ នាទី ព្រះជន្មលោកបាន៦៤ ឆ្នាំ កាលពីក្មេងបានអាយុ ១៣ ឆ្នាំ ចូលទៅជាកូនសិស្សសម្ដេចព្រះមហាសង្ឃរាជ សង្ឃនាយក ក្នុងវត្តឧណ្ណាលោម ។

គ្រានោះលោកចាប់រៀនព្រះត្រៃបិដកមានព្យាយាម ឧស្សាហសូត្ររៀនជាមួយឧកញ៉ាខុំ ក្នុងសំណាក់លោកឧកញ៉ាសុធម្មមេធាអាចារ្យ រ៉ត លុះលោករៀនចេះច្រើនហើយ លោកនិមន្តទៅស្រុកសៀម បង្រៀនព្រះត្រៃបិដក នៅស្រុកសៀម ហើយជាវព្រះគម្ពីរផង ក្នុងព្រះពុទ្ធសករាជ ២៤៤៤ ប្រហែលជា ១ ឆ្នាំ លោកត្រឡប់មកវិញ ។

ឯចិត្តលោកនោះក៏ល្អតែងទំនុកបម្រុងសមគួរ នឹងមិត្តសម្លាញ់ នឹងកូនសិស្សនឹងអ្នកដទៃមិនសូវរើសមុខ ហើយលោកបួសប្រព្រឹត្តតាមធម៌តាមវិន័យល្អ អាល់តែអស់ជីវិត លោកអង្គនោះជាកល្យាណមិត្តខ្ញុំ គឺមិត្តជាកុសលល្អ មុខគួរឱ្យ[illegible]លោកណាស់ កាលលោកគង់ព្រះជន្មនៅ

ឡើយ ពីមុន ៗ រៀងមក បើមានការអ្វី ៗ លោកតែងឲ្យហៅរកឧកញ៉ា ខ្ញុំទៅប្រឹក្សាកិច្ចការជាមួយផង ហើយលោករកឧកញ៉ាខ្ញុំឲ្យប្រែធម៌ព្រះ

ពុទ្ធគុណ
ធម្មគុណ } ពីបាលីអក្សរខ្មែរទៅជាអក្សរសៀមវិញ ជូនញោមសិកាលោក
សង្ឃគុណ

រៀនដោយសេចក្ដីរាប់អាន ហើយលោកបានប្រើឧកញ៉ាខ្ញុំ ឲ្យប្រែបាលី ជាអក្សរលង្កា ហើយលោកប្រើឲ្យតែងវិធីបក្ខ និងគម្ពីរ ជិនកាលមាលិនី ជាព្រះពុទ្ធពង្សាវតារ និងរឿងសាសនវង្ស និងបញ្ជាខន្ធក និងសាមណេរ សិក្ខា ចតុបរិសុទ្ធិសីល អាគារិយវិន័យ និងព្រះត្រៃលក្ខណ៍ និងរឿងព្រះ ពុទ្ធសាសនាផ្សេង ៗ ជាច្រើន លោកតែងរាប់អានឧកញ៉ាខ្ញុំ រៀងរាប់ដ រាបមកដល់ថ្ងៃអាទិត្យ ៩ កើត ខែផល្គុណ ឆ្នាំជូតបញ្ចស័ក ត្រូវនឹងថ្ងៃ១៦ ខែម៉ាវ្ស៍ឆ្នាំ ១៩១៣ ព្រះពុទ្ធសករាជ ២៤៥៦ នោះ លោកព្រះមហាវិមល ធម្ម បានធ្វើជាមេប្រឡងវិធីប្រយោគ ព្រះត្រៃបិដកគន្ធធុរៈ គ្រានោះ ឧកញ៉ាខ្ញុំក៏បានចូលធ្វើរាជការកាន់កាប់ប្រយោគជាមួយផង ដល់មកថ្ងៃ ព្រហស្បតិ៍ ៩ រោច ខែចេត្រ ឆ្នាំថោះ នៅក្នុងឆស័ក គឺថ្ងៃ ៨ ខែអាវ្រិល ឆ្នាំ ១៩១៥ នោះ លោកព្រះមហាវិមលធម្ម ថោង បានជាអធិបតីក្នុង សាលាបាលីក្រុងភ្នំពេញ បាននាំឧកញ៉ាខ្ញុំ និងក្រុមអាចារ្យដែលប្រឡងវិធី ប្រយោគក្នុងរាជការ ទៅបង្រៀនព្រះត្រៃបិដកកូនសិស្ស ដែលប្រឡង បាននៅមន្ទីរកុដម្ភវត្តព្រះកែវមរកតជាដំបូងបង្អស់ រៀងរាបដរាបដល់

សាលាបាលី សព្វថ្ងៃនេះ មុនលោកនឹងទទួលមរណភាពនោះ លោកបានផ្តាំឧកញ៉ាខ្ញុំថា ឲ្យខំបង្រៀនលោកភិក្ខុចាស់ ១ អង្គ ដែលមកអំពីស្រុកបាកយណ៍នោះ ឲ្យចេះដឹងប្រាកដផង ត្បិតលោករៀនយកបុណ្យគ្រាន់បានជាផ្លូវប្រតិបត្តិតទៅ ។

គួរឲ្យស្តាយលោកជាកល្យាណមិត្តល្អ ប្រែថមិត្តជាកុសល នឹងពោលពីមិត្តតទៅទៀត ឯមិត្តមាន ៤ ជំពូកគឺ ៖

| | |
|---|---|
| មិត្តមានឧបការ ១<br>មិត្តរួមសុខរួមទុក្ខ ១<br>មិត្តណែនាំឲ្យបានមានប្រយោជន៍ ១<br>មិត្តមានសេចក្តីស្រឡាញ់ភ្ជាប់ខ្លួន ១ | មិត្ត ៤ ជំពូកនេះ ជាមិត្តពិត គួរគប់រក ។ |

## ១- មិត្តមានឧបការមានលក្ខណៈ ៤ គឺ :

១- បង្ការមិត្តអ្នកប្រមាទហើយ,

២- បង្ការទ្រព្យសម្បត្តិរបស់មិត្តប្រមាទហើយ,

៣- កាលមានភ័យជាទីពឹងពំនាក់បាន,

៤- កាលមានធុរៈជួយចេញទ្រព្យឲ្យលើសជាងចេញភិចា ។

## ២- មិត្តរួមសុខរួមទុក្ខមានលក្ខណៈ ៤ គឺ :

១- និយាយសេចក្តីកំបាំងរបស់ខ្លួនប្រាប់មិត្ត,

២- បិទសេចក្តីកំបាំងរបស់មិត្តមិនឲ្យខ្ចរខ្ចាយ,

៣- មិនលះបង់ចោលក្នុងវេលាមានវិបត្តិ,

៤- ទោះបីជីវិតក៏អាចលះបង់ជួសបាន ។

យើងខ្ញុំបានរក្សាហើយដោយវិរតិចេតនា ការទានឯណា ដែលយើងខ្ញុំបានចម្រើនបានរៀនសូត្រ ពិចារណាក្នុងសមថ និង វិបស្សនា ហើយដោយប្រាជ្ញាដ៏បរិសុទ្ធ និងកុសលពសីដទៃ ៗ ទៀត ដែលយើងខ្ញុំបានសាងសន្សំទុកមកហើយនោះ ក៏សូមឧទ្ទិសផលសម្បត្តិទាំងនោះ ប្រគេនព្រះតេជព្រះគុណទាំងអស់ ព្រមជាមួយនឹងសេចក្តីមេត្តាករុណាភាពរបស់យើងគ្រប់គ្នា សូមឲ្យផលសម្បត្តិទាំងនោះ ជាសេនាយោធាទាហាន ចូលទៅបណ្តេញនូវពួកសត្រូវ គឺរោគា ព្យាធិ ដែលបៀតបៀនក្នុងសរីរកាយរបស់ព្រះតេជព្រះគុណនោះ ឲ្យវិនាសបាត់បង់ឃ្លាតឆ្ងាយអំពីខន្ធសន្តាននោះទៅកុំឲ្យខានឡើយ លុះចប់សេចក្តីប្រកាសនេះ វេលាណាហើយលោកក៏ទទួលអនុមោទនាថា សាធុ ខ្ញុំអរពេកណាស់លោក សូមឲ្យខ្ញុំបានស្រាកស្រាន្តចាកសេចក្តីវេទនា ឲ្យបានដូចពាក្យសច្ចារបស់លោកគ្រប់អង្គកុំខានឡើយ ហើយលោកថា ៖ ឱអស់លោកទាំងឡាយគ្រប់អង្គលោកមានចិត្តអាណិតស្រឡាញ់ខ្ញុំពន់ពេកណាស់ សម្តែងសេចក្តីគោរពរាប់អានខ្ញុំចម្រើនពុទ្ធមន្ត ខ្ញុំប្រកាសសច្ចាបាអំពាវនាវរកទេវតា ដែលរក្សាពុទ្ធសាសនាឲ្យជួយខ្ញុំ ដើម្បីឲ្យខ្ញុំរស់នៅ ទាំងចិត្តខ្ញុំសោក ក៏មានប្រាជ្ញាជាមនុស្សរស់នៅឲ្យបានយូរបន្តិចដែរ ដោយសេចក្តីបំណងចង់បានឃើញការចម្រើនព្រះពុទ្ធសាសនានោះពេកណាស់ ព្រោះសព្វថ្ងៃនេះសាសនាកំពុងតែចម្រើនកើនឡើងបន្តិច ៗរាល់ឆ្នាំ តែថាសមុដ្ឋានរោគរបស់ខ្ញុំនេះមើលទៅរាបេះតែចម្រើនឡើងឥតមានអាក់ មិនទទួលថ្នាំមិនទទួលមន្ត

## ៣- មិត្តណែនាំឲ្យបានមានប្រយោជន៍ មានលក្ខណៈ ៤ គឺ :

១- ហាមមិនឲ្យធ្វើសេចក្ដីអាក្រក់,

២- ណែនាំឲ្យតាំងនៅសេចក្ដីល្អ,

៣- ឲ្យបានស្ដាប់ធម៌អ្វីដែលនៅមិនធ្លាប់ស្ដាប់,

៤- ប្រាប់ផ្លូវឋានសួគ៌ ១ ។

## ៤ មិត្តមានសេចក្ដីស្រឡាញ់រាប់អាន មានលក្ខណៈ៤ គឺ :

១ មានទុក្ខៗ ផងគ្នា,

២ បានសុខៗ ផងគ្នា,

៣- ជជែកដោះស្រាយនឹងអ្នកដែលនិយាយតិះដៀលដល់មិត្ត,

៤- ទទួលសមគួរនឹងមនុស្ស ដែលជាអ្នកនិយាយសរសើរដល់មិត្ត ។

*ឥឡូវនេះខ្ញុំជាចៅក្រមក្រសួងពុទ្ធបណ្ឌិត្យ ធ្វើការក្នុងសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ ខ្ញុំគិតនឹករឭកដល់កិត្តិគុណរបស់ព្រះមហាវិមលធម្ម ចាន់ហ្វាន់ រឿង ឃ្វាង ក្រសួងសង្ឃដែលជាកល្យាណ-មិត្ត គិតរកព្រះធម៌ឯណាមួយ នឹងបានជាផលប្រយោជន៍ក្នុងព្រះពុទ្ធសាសនាក្នុងការបុណ្យសពលោកនេះ ឲ្យបានជាធម៌ល្អដែលសម្ដេចព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ចំពោះនឹងព្រះសារីបុត្តថេរថា បឋមត-រំ អនិច្ចំ ទុក្ខំ អនត្តាតិ ឧច្ចារេត្វា ជាអាទិ កោសារីបុត្រ ម្នាលសារីបុត្រដ៏ចម្រើន ថាបើបុគ្គលមានសេចក្ដីប្រាថ្នា នឹងចម្រើនការនាធម៌ ដើមដំបូងបង្អស់នោះឲ្យសូត្រព្រះត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា ដូច្នេះជាដើមដំបូងមុនដោយវិសេស ជាព្រះពុទ្ធដីកាប្រាកដ នឹងសម្ដែងព្រះធម៌ព្រះត្រៃលក្ខណ៍តទៅ ៗ*

# អនិច្ចលក្ខណកថា

អវិជ្ជាទីហិ សម្ភូតា  រូបញ្ច វេទនា តថា
អថោ សញ្ញា ច សំខារា  វិញ្ញាណញ្ចាតិ បញ្ចិមេ
ឧប្បជ្ជន្តិ និរុជ្ឈន្តិ  ឃរំ ហុត្វា អភាវតោ
ឃរំ ធម្មា អនិច្ចាវ  ឥថាៈវកាលិកា តាទិតោ
អហោ អនិច្ចា សំខារា  តេកាលិកា អសណ្ឋិតា
សកាលា កាទិកា សព្វេ  ហុត្វា ហុត្វា នហោន្តិ តេ
តំតុត្តេជ អក្ខាលោភកោ  យទុប្បន្នំ នចស្សតិ
ឃរំក្ខតេស្សុ វេតេស្សុ  សាធុតត្វា កុបេក្ខតា
បដិបត្តិយា តិសាធុតំ  អប្បមាទេន សព្វទាតិ

ចប់អនិច្ចលក្ខណកថា ជាបាលីសុទ្ធតែប៉ុណ្ណេះ

និច្ចលក្ខណកថា ស្រាយសេចក្តីជាភាសាខ្មែរថា ៖

អ្នកជាសាធុជនគប្បីពិចារណាថា កាយនិងចិត្តដែលសម្បយុត្ត ជាមួយគ្នានេះ បែកចេញជា ៥ គឺ រូប ១, វេទនា ១, សញ្ញា ១, សំខារ ១, វិញ្ញាណ ១, ឯរូបនោះ គឺធម្មជាតិដែលវិនាសដោយត្រជាក់ទឹកក្តៅជាដើម ឬមានពណ៌សណ្ឋានទ្រង់ទ្រាយ ទើបចង្អុលឲ្យច្បាស់ គឺសក់, រោម, ក្រចក, ធ្មេញ, ស្បែក, សាច់ឈាម, ពោះវៀន, ក្រពះ, ថ្លើម, បេះដូង, ទឹកសម្បោរ, ទឹកមាត់, ទឹកមូត្រ, អាហារចាស់, ខ្ទុះ ជាដើម ។

ឯវេទនា គឺសេចក្តីសោយអារម្មណ៍ សេចក្តីដឹងច្បាស់នូវអារម្មណ៍ ចាត់ជា៣គឺ សុខវេទនា សេចក្តីសោយនូវអារម្មណ៍ជាសុខ គឺសេចក្តីសប្បាយកាយសប្បាយចិត្ត ទុក្ខវេទនា សេចក្តីសោយអារម្មណ៍ជាទុក្ខ គឺសេចក្តីមិនសប្បាយកាយមិនសប្បាយចិត្ត ឧបេក្ខាវេទនា សេចក្តីសោយអារម្មណ៍ជា ឧបេក្ខា មិនមែនទុក្ខ មិនមែនសុខ សញ្ញា គឺសេចក្តីចាំរូបចាំសម្លេង ចាំក្លិន ចាំរស ចាំសម្ផស្សដែលពាល់ត្រូវ ចាំអារម្មណ៍ដែលដឹងដោយចិត្ត ឯសំខារ គឺសភាវៈដែលបម្រុងសម្រេចចិត្ត ដែលកើតឡើយក្នុងចិត្តទាំងល្អ ទាំងអាក្រក់ទាំងកណ្តាល ៗ មិនល្អមិនអាក្រក់ ឯវិញ្ញាណ គឺចិត្តដែលដឹងច្បាស់នូវអារម្មណ៍ ដែលអាស្រ័យនូវភ្នែកឈ្មោះថា ចក្ខុវិញ្ញាណ ដែលអាស្រ័យនូវត្រចៀកឈ្មោះសោតវិញ្ញាណ, ដែលអាស្រ័យនូវច្រមុះឈ្មោះថា ឃានវិញ្ញាណ, ដែលអាស្រ័យនូវអណ្តាតឈ្មោះថា ជិវ្ហាវិញ្ញាណ, ដែលអាស្រ័យនូវខ្លួនឈ្មោះថា កាយវិញ្ញាណ, ដែលអាស្រ័យនូវសភាវៈ ដែលទ្រទ្រង់ទឹកចិត្តសោយអារម្មណ៍ហើយ សុះទៅចាប់ឈ្មោះថា មនោវិញ្ញាណ ភងកាយនិងចិត្តមួយមុខៗ ដែលកើតក្នុងចិត្តចែកជា៥ដូច្នេះៗ ឯធម៌ទាំងឡាយ៥នេះកើតព្រមហើយអំពីធម៌ទាំងឡាយមានអវិជ្ជា ជាដើម បង្កើតឡើងហើយរមែងរលត់ទៅវិញបានជាឈ្មោះថាមិនទៀងដូច្នេះគឺថា អនិច្ចំ ហេតុដូចម្តេចក៏ថា អនិច្ចំ ។ អនិច្ចំនោះ ត្បិតថាមានដូច្នេះហើយ ក៏ត្រឡប់

ប្រែជាមិនមានទៅវិញបានជាថា អនិច្ចំ គឺថាសេចក្ដីមិនទៀងនោះឯង ។

ឯអ្នកជាសាធុជនគប្បីពិចារណានូវ ខន្ធបញ្ចកា គឺប្រមាណ ៥ នៃខន្ធៈនោះ ការនោក្នុងចិត្តពិតគិតថា អហោ ឱដូចជាយើងនឹកសង្វេគថា បញ្ចខន្ធ តាំងឡាយ ៥ ឯណាជារបស់មិនទៀង ជា អនិច្ចំ ដូចជារបស់ប្រកបក្នុងកាលមានប្រមាណប៉ុណ្ណោះ ឬដូចជារបស់ខ្ចីគេមក លុះយូរបន្តិចទៅគេទារយករបស់ផងគេទៅវិញ ឯ បញ្ចខន្ធ តាំងឡាយ ៥ នោះ មិនបានឋិតថេរមាំមួនយូរប៉ុន្មានទេ ខន្ធតាំងឡាយតាំងពួង ប្រកបក្នុងកាលមានតែប៉ុណ្ណោះជាដើម មានទ្រព្យសម្បត្តិយសសក្ដិ ហើយត្រឡប់ប្រែជាមិនមានវិញបានជាឈ្មោះថា អនិច្ចំ គឺថារកទៀងទាត់កន្លែងណាគ្មានសោះឡើយ ឯខន្ធតាំងឡាយ ៥ នោះ ជាបើគួ នឹងកើតហើយក៏គង់តែនឹងវិនាសទៅក្នុងលោកនេះវិញ មិនបាន តាំងនៅយូរអង្វែងអស់កប្ប ១ ទេ គួរតែយើងតាំងចិត្តជា ឧបេក្ខា ក្នុង បញ្ចខន្ធ នេះ ជាកណ្ដាល ។ កុំថាល្អកុំថាអាក្រក់ ក្នុង បញ្ចខន្ធ តាំងឡាយ ៥ នោះ ។ ដែលកើតឡើងហើយ មានកម្លាំងខ្លាំងណាស់ ដោយពិតប្រាកដដូច្នេះឯង យើងខំឧស្សាហ៍ប្រតិបត្តិការនោះពិចារណា ឲ្យស្រួលបួលល្អប្រពៃដោយអប្បមាទធម៌ ដោយបការតាំងពួង ឃុំ ដូច្នេះ ទៅហោង ។

## ទុក្ខលក្ខណកថា

អរិដ្ឋា ឌីហិ សង្ខតា   រូបញ្ចវេទនាតថា

អជោសញ្ញាសំខារ វិញ្ញាណញាតិបញ្ចិមេ
ឧប្បជ្ជន្តិនិរុជ្ឈន្តិ បុនប្បុនំបិឡិតត្តា
ឧប្បាទេនវយេន ច តេទុក្ខាវអនិប្បាយេ
អជសន្តស្សតានិតោ សព្វេសំខារទុក្ខាតិ
យទាបញ្ញាយបស្សតិ អថនិព្វិន្ទតិទុក្ខេ
ឯសមគ្គោវិសុទ្ធិយាតិ ។

ចប់ទុក្ខលក្ខណកថា

## ទុក្ខលក្ខណៈកថា សូត្រជាភាសាខ្មែរ

អ្នកជាសាធុជន គប្បីពិចារណាដោយប្រាជ្ញា ក្នុងកាលឯណាថា ឯខន្ធទាំងឡាយ ៥ នេះគឺរូបក្តី, វេទនាក្តី, សញ្ញាក្តី, សំខារក្តី, វិញ្ញាណក្តី កើតព្រមហើយអំពីធម៌ទាំងឡាយ មានអវិជ្ជាជាដើម បង្កើតឡើងហើយ ក៏លេតបាត់សូន្យទៅវិញ ឯខន្ធទាំងឡាយ ៥ នោះ នាំមកនូវសេចក្តីទុក្ខ ឲ្យប្រព្រឹត្តទៅដោយច្រើនប្រការក្រៃពេកណាស់ អំពីហេតុដែលកើតឡើងផង ហើយវិនាសទៅវិញផង ហេតុដូចម្តេចក៏ហៅថា ទុក្ខំ ទុទុក្ខំនោះ ត្បិតថាខន្ធទាំងឡាយ ៥ នោះ តែងបៀតបៀនរឿយ ៗ ក្នុងសន្តានខ្លួនសត្វឲ្យតែព្រួយចិត្ត ចង្អៀតតឹងចិត្តណាស់ បានជាឈ្មោះថា ទុក្ខំ, ១ វិញទៀតឯបញ្ចខន្ធទាំងឡាយ ទាំងពួង ដែលមានដល់សត្វប្រាកដដូចជាពោះហើយរមែង នាំមកនូវសេចក្តីទុក្ខទោមនស្ស

អន់ចិត្តពុំខានឡើយ អ្នកជាសាធុជន គួរតែនឿយណាយក្នុងសេចក្ដី ទុក្ខាំ ក្នុងកាលនោះហោង ឯផ្លូវនេះជាផ្លូវប្រព្រឹត្តទៅ ដើម្បីឲ្យបរិ-សុទ្ធល្អពេកណាស់ ។

ចប់ទុក្ខលក្ខណៈ តែប៉ុណ្ណេះ

## អនត្តលក្ខណកថា

សព្វេ ធម្មា អនត្តាតិ  យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ  ឯស មគ្គោ វិសុទ្ធិយាតិ

អ្នកជាសាធុជន គប្បីពិចារណាដោយប្រាជ្ញា ក្នុងកាលឯណាថា សង្ខារ គឺខន្ធទាំងឡាយទាំងពួងឈ្មោះថា អនត្តា ដូច្នេះ ហេតុដូចម្ដេច ឈ្មោះថា អនត្តា ទដែលឈ្មោះថា អនត្តា នោះ គឺថាគេខ្លឹមសារគ្មាន និងមិនបានប្រព្រឹត្តទៅក្នុង អំណាចនៃខ្លួនបានឈ្មោះថា អនត្តា ដូច្នេះ ហើយអ្នកជាសាធុជននឿយណាយក្នុងសេចក្ដីទុក្ខ ហើយពិចារណាដល់ អនត្តា ថាគេខ្លឹមសារគ្មានទីពឹងមិនបានប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួនឈ្មោះ ថាអនត្តា ក្នុងកាលគ្រានោះឯង ឯផ្លូវនេះជាផ្លូវឲ្យបរិសុទ្ធដោយវិសេស អំពីសេចក្ដីទុក្ខទាំងពួងដូចបានពណ៌នាមកនេះហោង ។

ចប់អនត្តលក្ខណ ជាភាសាខ្មែរ

ព្រះគម្ពីរព្រះអភិធម្មសង្គហ បរិច្ឆេទទី ២ លេខ ១២០

សម្ដែងថា ឯបរិកម្ម ជាវេនដែលកើតជាបឋម នោះ កាលកើតហើយ

កំពិចារណានូវសំខារធម៌ជា អនិច្ចំ ទុក្ខំ អនត្តា កំចាត់បង់នូវងងឹត គឺ អវិជ្ជាដែលកំបាំងប្រាជ្ញាទុកមិនឲ្យឃើញនូវព្រះចតុរារិយសច្ច កំចាត់ងងឹតដែលជ្រៅជ្រៀត គឺអកុសលដែលអាក្រក់បង់ហើយ កំធ្វើនូវបញ្ញាត្រៃលក្ខណ៍ គឺ អនិច្ចំ ទុក្ខំ អនត្តា នោះឲ្យប្រាកដក្រៃលែងជាន់មុនហើយក៏រលត់ទៅ ។

លុះបរិកម្មជវនជាបឋមរលត់ហើយ ឧបចារជវនដែលជាគម្រប់ពីរ ទើបបង្កើតឧបចារជវនទីពីរនោះៗនោះជ្រះថ្លាក្លៀវក្លាល្អិតល្អក្រៃពេក ហេតុដ្បិតជាបានអាសេវនបច្ច័យអំពីសំណាក់ឧបចារជវនជាបឋម ។ នោះពិចារណាសំខារធម៌ជា អនិច្ចំ ទុក្ខំ អនត្តា ធ្វើបញ្ញាព្រះត្រៃលក្ខណ៍ឲ្យប្រាកដទៅហើយមែនពិត ធម៌ទាំងឡាយ ដែលជាលោកិយប្រកបដោយអាសវក្តី មិនប្រកបដោយអាសវក្តី គឺជាចំណែកលោកុត្តរក្តី ហេតុនោះបានជាសម្តេចព្រះសារពេជ្ញព្រះពុទ្ធអង្គជាម្ចាស់ទ្រង់ត្រាស់ទេសនាថា បញ្ចខន្ធដោយកេសេសសល់មិនបាន ដើម្បីនឹងសង្គ្រោះយកនូវធម៌ដែលជាសភាពមានចំណែកស្មើគ្នា គឺជារូបៈស្មើគ្នាជា វេទនា សំញា វិញ្ញាណស្មើគ្នាចុះទៅក្នុងភូមិទាំង ៤ គឺ កាមាវចរភូមិ និង រូបាវចរភូមិ អរូបាវចរភូមិ និងលោកុត្តរភូមិ កាលបើត្រាស់ទេសនា សម្តែងដោយឧបាទានខន្ធនោះ ទ្រង់ជ្រើសរើសយកតែធម៌ទាំងឡាយ ដែលប្រកបដោយអាសវៈ ដែលយុត្តក្នុងភូមិទាំងបី វៀរចាកលោកុត្តរភូមិ ដើម្បី

ទឹងសម្ដែងនូវភូមិនៃវិបស្សនា អធិប្បាយថា យោគាវចរទឹងចម្រើនភាវនា ប្រាថ្នាទឹងបំណងបាននូវព្រះលោកុត្តរ ទឹងយកព្រះលោកុត្តរមកជាអារម្មណ៍ នៃព្រះវិបស្សនា លើកឡើងកាន់ព្រះត្រៃលក្ខណ៍ គឺ អនិច្ចំ ទុក្ខំ អនត្តា រកគូមិនមាន អាស្រ័យហេតុដូច្នេះ សម្ដេចព្រះសព្វេជ្ញព្រះពុទ្ធ អង្គជាអម្ចាស់ ទ្រង់រៀបចំនូវព្រះលោកុត្តរហើយ ចំពោះយកតែធម៌ដែល ប្រកបដោយអសវ ចំណែក ១ ឈ្មោះថា ឧចាធិញ្ញា១ទ្ធ ។ បរិបូណ៌ តែប៉ុណ្ណោះ ។

អានិសង្សព្រះត្រៃលក្ខណ

គ្រានេះនឹងបានវិសជ្ជនារឿងអានិសង្សធម៌ព្រះត្រៃលក្ខណ៍ សម្ដែង តាមព្រះគម្ពីរសព្វទានានិសង្ស ដោយព្រះបាលីថាដូច្នេះ ទុក្ខំសត្តរសកាប្បំ ប្រែជាសេចក្ដីថា អ្នកឯណាមួយមានចិត្តជ្រះថ្លា សទ្ធាបាន ភាវនាគិតនឹកដល់ ទុក្ខំ អ្នកនោះបានផល ១៧ កប្ប ។

អនិច្ចំអដ្ឋារសកាប្បំ បើអ្នកឯណា ១ មានចិត្តជ្រះថ្លាសទ្ធាបាន ភាវនាគិតនឹកដល់ព្រះ អនិច្ចំ អ្នកនោះបានផលអានិសង្ស ១៨ កប្ប ។

អនត្តាវីសតិកាប្បានិ បើអ្នកឯណា ១ មានចិត្តជ្រះថ្លាបាន ភាវនា គិតនឹកដល់ព្រះ អនត្តា អ្នកនោះបានផលអានិសង្ស ២០ កប្ប ។

ចប់បរិបូណ៌ហើយ

## ធ្វើជាពាក្យកាព្យបដ្ដិច

អាសូររូបា រូបសត្វភាសា កើតឡើងមិនទៀង មរណៈមកកាត់ រូបសត្វរៀបរៀង គ្មានរូបណាទៀង សល់ផលមួយឡើយ ។ អាសូររូប រស់ កើតឡើងស្មានស្មោះ ជាមនុស្សបានហើយ តែងប្រែរកក្ស័យ ជីពជន្មឥតស្បើយ គ្មានរូបណាឡើយ នឹងជួយរូបបាន ។

# វណ្ណកិត្តិគុណកថា

---

## ពាក្យពណ៌នាសរសើរគុណព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម

## នាម ថោង

*ចាងហ្វាងសាលាបាលីជាន់ខ្ពស់*

## ព្រះធម្មបិដកវិជ្ជា អាំងស្បិកទ័រ ហិម តែង

អាគមអ្វីសោះឡើយ ពោះសេចក្ដីគោរពរបស់លោកក្ដី ការឧស្សាហ៍បម្រើនពុទ្ធមន្តឲ្យខ្ញុំក្ដី និងពាក្យសច្ចាកទិរំឭករំលើកគុណវិសេសក្ដី ទាំងអស់នេះ ក៏ជាគុណយ៉ាងខ្ពស់បំផុតហើយ តែគង់មិនអាចទប់ទាស់នូវបច្ចាមិត្រនោះបានឡើយ ហើយចុះលោកគ្រប់អង្គ ត្រង់ពេលាព្យាធិរបស់ខ្ញុំនេះ ក៏ជាការទម្ងន់ដល់លោកហើយ ៗ លោកក៏បានធ្វើបដិការគុណដល់ខ្ញុំរួចជាស្រេចហើយ តែថាការឈឺស្លាប់នេះ ជារបស់ធម្មតាសម្រាប់សត្វទេ មិនដែលសត្វណាជៀសរួចឡើយ សូមអស់លោកយកព្រះហឫទ័យទុកដាក់ជួយថែរាំទំនុកបម្រុងសង្គ្រោះព្រះពុទ្ធសាសនាឡើង ព្រោះការដែលឈឺចាប់ស្លាប់បាត់នេះ ជាការតូចបន្ទាប់បន្សំទេ គ្រាន់តែផ្លាស់រូបនេះចោល ទៅកេរូបថ្មីទៀតប៉ុណ្ណោះទេ ឯការដែលធំធ្ងន់មាំមួនគ្រប់ខ្លួនសត្វពលគ្នានោះ គឺព្រះពុទ្ធសាសនាឯណោះ បើអ្នកណាបានសង្គ្រោះសាសនាហើយ អ្នកនោះឯងឈ្មោះថាបានសង្គ្រោះខ្លួន សង្គ្រោះគ្រូអាចារ្យ មាតាបិតា បុត្រភរិយា មិត្រសម្លាញ់គ្រប់ផ្នែកទាំងអស់ អ្នកណាបើមិនបានសង្គ្រោះទំនុកបម្រុងពុទ្ធសាសនាហើយ អ្នកនោះឯងបានឈ្មោះថា ជាមនុស្សខាតលាភឃាតធន ៗ

លុះដល់ថ្ងៃទី ១១, ទី ១២, ទី ១៣, លោកបានមានពុទ្ធដីកាសួរខ្ញុំឲ្យខ្ញុំប្រែធម៌ អចិរំវត ត្រង់សព្ទកថា អបេតវិញ្ញាណោ នោះតើប្រែថាដូចម្ដេច ខ្ញុំក៏មកមានចិត្តគិតថាប្រហែលជាព្រះតេជព្រះគុណនេះ លោកអស់អាល័យក្នុងអាយុសង្ខាររបស់លោកហើយដឹង ទើបបានជាលោកសួរ

# វណ្ណាភិត្តិគុណគាថា

ថ្ងៃអង្គារ ១១ កើត ខែស្រាពណ៍ ឆ្នាំថោះនព្វស័ក

ត្រូវនឹងថ្ងៃ ៩ ខែអាគ៊ូត ឆ្នាំ ១៩៦៧ ។

ខ្ញុំករជា ព្រះធម្មបិដកវិជ្ជា នាមដើមឈ្មោះ ហ៊ិម អាយុ ៥៦ ឆ្នាំ សព្វថ្ងៃធ្វើការក្នុងក្រសួងសិក្សាធិការ ជាអាំងស្ប៉ិកទ័រត្រួតត្រាការសិក្សាបឋមវិជ្ជា សាលាវត្ត ក្នុងក្រុងកម្ពុជា ចំណែកខាងត្បូង ។

ខ្ញុំសូមពណ៌នាសរសើរគុណ ព្រះតេជព្រះគុណលោកគ្រូព្រះមហាវិមលធម្ម ឧត្តមមេធាវី វិជ្ជាទេសវិសេស ធម្មសុបរិគោមហាបរិយត្តិនាយក តាំងហ្វាងសាលាបាលីជាន់ខ្ពស់ ព្រះនាមដើមឈ្មោះ ថោង ជួនលោកអ្នកទាំងឡាយបានជ្រាប ហេតុដែលលោកមានគុណូបការលើខ្ញុំ ។

លោកគ្រូលោកកើតថ្ងៃព្រហស្បតិ ១៣ កើត ខែចេត្រ ឆ្នាំច លោកមានចិត្តសន្តានរបស់លោកច្រូច្រង់ធម៌វិន័យតាំងពីលោកបានដឹងសេចក្តី ។

លុះលោកមានព្រះជន្មបាន ៦៨ ឆ្នាំ លោកក៏ទទួលអនិច្ចធម្ម នាពេលម៉ោង ២ និង ១០ មីនុតយប់ ក្នុងថ្ងៃអង្គារ ៤ កើត ខែស្រាពណ៍ ឆ្នាំថោះនព្វស័ក ព្រះពុទ្ធសករាជ ២៥១០ វស្សា ត្រូវនឹងថ្ងៃ ២ ខែអាគ៊ូត ឆ្នាំ ១៩៦៧ ។

ខ្ញុំមានចិត្តសង្វេគក្រៀមក្រំស្តាយ ស្រណោះអាឡោះអាល័យលោកជាទីបំផុត ។

តៀតខ្លួនខ្ញុំជាអ្នករៀនព្រះបរិយត្តិធម៌បានចេះដឹងបន្តិចបន្តួចជាអាចារ្យបង្រៀនព្រះបរិយត្តិធម៌នៅសាលាស្រុកកណ្តាលស្ទឹង ។

ខ្ញុំបានឮកិត្តិសព្ទអំពីអ្នកប្រតិបត្តិព្រះពុទ្ធសាសនា ដែលគេបានចូលទៅកាន់សំណាក់លោក គេចេញទៅសរសើរគុណសម្បត្តិលោកឲ្យខ្ញុំដឹងថា លោកគ្រូព្រះមហាវិមលធម្ម លោកមានឥន្ទ្រិយលោក ក៏បរិសុទ្ធ ហេតុលោកប្រតិបត្តិហ្មត់ចត់ក្នុងធម៌វិន័យ ហើយលោកមានឧស្សាហ៍ក្នុងការព្រះពុទ្ធសាសនា ទំនុកបម្រុងដល់សិស្សឲ្យចេះដឹង តាំងពីហាត់សូត្រធម៌ នឹងប្រែបាលីជាសេចក្តីធម៌ បើសិស្សណារៀនបានចេះដឹងគ្រាន់បើ លោកក៏តែងជួយទំនុកបម្រុងសិស្សនោះ ឲ្យឡើងជាគ្រូបង្ហាត់បង្រៀនសិស្សតទៅទៀត ទោះអ្នកដែលមិនមែនជាសិស្ស ក៏លោកមិនដែលឥច្ឆាឈ្នា-និសបង្អាប់បង្អោន ឲ្យអាក់អន់ដល់ឈ្មោះណាមួយឡើយ មានតែជួយរំពុកដឹកនាំឲ្យល្អឡើង ទោះឧបាសកឧបាសិកាដែលមានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ក៏លោកតែងសម្តែងផ្សាយផ្លូវប្រតិបត្តិនោះ ឲ្យបានចេះដឹងប្រតិបត្តិត្រូវតាមកិច្ចការរបស់ខ្លួនគ្រប់រូប មិនសូវមានរើសមុខ ។

ដល់ឆ្នាំ ១៩០៩ ខ្ញុំមានសេចក្តីជ្រះថ្លា ក្នុងគុណរបស់លោក ខ្ញុំក៏បានចូលមកគោរពប្រតិបត្តិបរណាប្រគល់ខ្លួនខ្ញុំ ជាសិស្សលោក ចាប់ដើមតាំងអំពីឆ្នាំនោះមក ខ្ញុំតែងទៅមកដោយសេចក្តីកតញ្ញូរបស់ខ្ញុំ ក្នុងពេល ១ លោកគ្រូលោកក៏មានព្រះហឫទ័យ ផូរផង់បានសម្តែងធម៌ចំពោះខ្លួនខ្ញុំ

ថា សត្វលោកគឺយើងទាំងឡាយ ដែលកើតក្នុងភាជនលោកនេះបាន សុខក្តី បានទុក្ខក្តី រុងរឿងក្តី ថោកទាបក្តី មានប្រាជ្ញាក្តី ល្ងង់ខ្លៅក្តី ទាំងនេះគឺសត្វបានមកតែអំពីកម្មរបស់ខ្លួន កម្មគឺអំពើដែលខ្លួនធ្វើសត្វណា ជាអ្នកប្រកបធ្វើនូវអំពើអាក្រក់ជាទុច្ចរិត ៣ យ៉ាងគឺ កាយទុច្ចរិត១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ហៅថាអាក្រក់ដោយកាយវាចាចិត្ត សត្វនោះកើតឡើងកាលណា បាននូវសេចក្តីទុក្ខព្រួយលំបាកថោកទាប ខ្សត់ខ្សោយល្ងង់ខ្លៅអាប់ឥតប្រាជ្ញាជាដើម សត្វណាជាអ្នកប្រកប ធ្វើនូវអំពើដ៏ល្អជាសុចរិត ៣ យ៉ាងគឺ កាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ ហៅថាល្អដោយកាយវាចាចិត្ត សត្វនោះក៏កើតឡើងកាលណា បាននូវសេចក្តីសុខឥតព្រួយ ថ្កុំថ្កើងរុងរឿងមានប្រាជ្ញា ជាអ្នកប្រាជ្ញរាជបណ្ឌិតជាដើម អ្នកអាចារ្យបូរដឹងចំពោះថា សត្វមានកម្មជារបស់ខ្លួន ខ្លួនទឹងជាអ្នកទទួលយកនូវផលនៃកម្ម មានកម្មជាកំណើត មានកម្មជាផៅពង្ស សាច់សន្តានឬជាមិត្តសម្លាញ់ មានកម្មជាទីពឹងចំពោះ ឬជានាយចៅហ្វាយ ធ្វើអំពើល្អទៀងជាបានអោយផលល្អ ធ្វើអំពើអាក្រក់ទៀងជាបានអោយផលអាក្រក់ មិនឃ្លៀងឃ្លាតឡើយ ។

ដល់ឆ្នាំ ១៩៩១ លោកក៏បាននិមន្តទៅកាន់សាលាខ្ញុំ ហើយលោកត្រួតត្រាពន្យល់អត្ថពិធីនឹងពិធីប្រែបាលីនិងធម៌ ៨ បទជាធម៌ដំបូន្មានខ្លួនខ្ញុំ ជាធម៌ទាំងឡាយ ៨ ឈ្មោះលោកធម៌ ព្រោះធម៌នោះជាធម៌សម្រាប់លោក

ឬនឹងថាជាធម៌បំពុលលោកដូច្នេះ វិញក៏បាន ព្រោះជាធម៌តែងនាំចិត្តសត្វលោកឲ្យញាប់ញ័រឲ្យរន្ធត់ លោកធម៌ទាំង ៨ នោះគឺ លាភោ មានលាភគឺបាន អលាភោ ឥតលាភគឺមិនបាន យសោ មានយសសក្តិ អយសោ ឥតយសឬថយយសសក្តិ សុខំ សេចក្តីសុខ ទុក្ខំ សេចក្តីទុក្ខ បសំសា ពាក្យសរសើរ និន្ទា ពាក្យតិះដៀលសត្វលោកដែលជាបុថុជ្ជនជាតិ រមែងមានចិត្តដេកត្រាំនទៀលនៅក្នុងលោកធម៌នេះ កាលបើមានលាភតែងមានចិត្តត្រេកអរ បើឥតលាភតែងមានចិត្តអាក់អន់ កាលបើមានយសសក្តិតែងមានចិត្តត្រេកអរ បើថយយសសក្តិតែងមានចិត្តអាក់អន់ កាលបើបានសុខតែងមានចិត្តត្រេកអរ បើមានទុក្ខតែងមានចិត្តអាក់អន់ កាលបើបានឮពាក្យសរសើរ តែងមានចិត្តត្រេកអរ បើឮពាក្យនិន្ទា តែងមានចិត្តអាក់អន់ សត្វលោកទាំងឡាយមានចិត្តសន្តានត្រាំនៅក្នុងលោកធម៌ លោកធម៌តែងនាំចិត្តឲ្យត្រេកអរនឹងអាក់អន់ជានិច្ច ចិត្តដែលត្រេកអរនិងអាក់អន់នេះហើយ ជាចិត្តញាប់ញ័ររន្ធត់គ្រោតគ្រាតឲ្យឃ្លាតចាកសមាធិធម៌ ។

ព្រះអរិយៈទាំងឡាយមានព្រះពុទ្ធជាដើម លោកដកចិត្តរបស់លោកឲ្យឃ្លាតផុតអំពីលាភធម៌ ទោះលោកមានលាភក្តីមានយសសក្តិក្តី បានសេចក្តីសុខក្តី ឮពាក្យសរសើរក្តី លោកក៏ពុំមានចិត្តត្រេកអរ ទោះឥតលាភក្តី ឥតយសសក្តិក្តី មានសេចក្តីទុក្ខក្តី ឮពាក្យតិះដៀលក្តី លោក

ក៏ពុំមានចិត្តអាក់អន់  ចិត្តលោកដែលពុំមានត្រេកអរ  ពុំមានអាក់អន់នេះ ហើយ  ជាចិត្តហ្មត់ចត់គួរនឹងទ្រទ្រង់នូវសមាធិធម៌បាន  ជាលំដាប់ដកប ដល់អរហត្តផលដល់នូវសេចក្តីសុខ  គឺមហានិព្វានជាស្ថានផុតកងទុក្ខទាំង ពួង ។

អ្នកអាចារ្យជាអ្នកប្រតិបត្តិតាមព្រះពុទ្ធសាសនា  តោងធ្វើលោកធម៌ ទាំងឡាយ  ឲ្យទន់ថយក្រោមទ្រុឌទៅ  ទើបបាននូវសេចក្តីសុខ  ហើយ នឹងបានជាបច្ច័យ  សម្រេចនូវព្រះនិព្វាន  ក្នុងកាលអនាគតទៅឯមុខ  បើ មិនទាន់ដល់ព្រះនិព្វាន ក៏គង់បានផលានិសង្សឲ្យសេចក្តីបម្រើនស្រួលបួល គ្រប់ ៗ ជាតិទៅ ។

ដល់ឆ្នាំ ១៩១៤ នោះ លោកក៏មានមេត្តាសង្គ្រោះ ទំនុកបម្រុងហៅ ខ្ញុំ  ឲ្យចូលមកនៅធ្វើជាអាចារ្យសម្រាប់វត្តលង្កាពមក្នុងក្រុង  ហើយ លោកក៏តែងនិមន្តទៅរឿយ ៗ បានឲ្យទានប្រាក់ខែរួមជាមួយនឹងអ្នកស្រុក ចំណុះជើងវត្តដល់ខ្ញុំ លោកបានឲ្យឱវាទដល់ខ្ញុំថា  អ្នកអាចារ្យរូបយើង សត្វទាំងឡាយ  ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងថា  មានលក្ខណា ៣ យ៉ាងគឺ អនិច្ចំ ១ ទុក្ខំ ១ អនត្តា ១   ជាកំណត់របស់រូប  អនិច្ចំ នោះគឺរូបទាំងឡាយមិនទៀងទាត់ស្ថិតស្ថេរ   មានសភាពប្រែប្រួល វិនាសសាបសូន្យទៅជាធម្មតា  ព្រោះរូបដែលកើតឡើង  ដូចអ្នកដំណើរ ទន្ទឹងតែរួចកិច្ចនឹងត្រឡប់វិលវិញយ៉ាងណា   រូបសត្វទាំងឡាយទន្ទឹងតែ

ដល់កំណត់ក៏ទីងស្លាប់ទៅវិញយ៉ាងនោះ ទុក្ខំ នោះគឺរូបសត្វទាំងឡាយ រមែងតែងសោយនូវសេចក្ដីទុក្ខព្រួយលំបាកមានជាតិទុក្ខគឺសោយលំបាក ព្រោះកំណើតដែលកើតជាដើម និងសេចក្ដីព្រួយដទៃទៀតរកបន្ទោះ អនត្តា នោះគឺរូបសត្វទាំងឡាយមិនមែនជារបស់អាត្មារកខ្លឹមសារគ្មាន ព្រោះរូបដែលកើតឡើងអាការទាំងឡាយមិនមានអាស្រ័យគ្នាបាន ហើយរូបនេះឃើញអាស្រ័យរាប់អាន តែពីកាលខ្យល់ដង្ហើមនៅចេញចូលបាន បើផុតខ្យល់ដង្ហើមក៏ស្លាប់កាលណាហើយ ទោះមាតាបិតា ភរិយា បុត្រ មិត្តសម្លាញ់ ក៏ផុតសេចក្ដីមេត្រីរាប់អានពីត្រឹមនោះទៅហើយ ន័យមួយទៀតវត្ថុឯណាជារបស់ក្នុងខ្លួនក្ដី ក្រៅខ្លួនក្ដី ជាគ្រឿងស្រឡាញ់ពេញចិត្ត វត្ថុទាំងអស់នោះ ក៏សុទ្ធតែជាគ្រឿង ព្រាត់ប្រាសវិនាសសាបសូន្យទៅជាធម្មតា ហើយប្រសិនណាបើវត្ថុដែលជាគ្រឿងស្រឡាញ់ពេញចិត្តនោះ វិនាសបាត់បង់ទៅយើងមិនត្រូវមានក្រេវក្រោធស្ដាយស្រណោះឲ្យខូចចិត្តឡើយ ព្រោះសភាវៈក្នុងលោកសុទ្ធតែអនិច្ចំ មិនទៀងទាំងអស់ ន័យមួយទៀតសេចក្ដីសោកនិងសេចក្ដីភ័យកើតមកតែអំពីសេចក្ដីស្រឡាញ់បុគ្គលឯណាមានឧបាយសម្រាកឲ្យស្រាកសេចក្ដីស្រឡាញ់បានហើយ នោះសេចក្ដីសោកនិងសេចក្ដីភ័យ ក៏មិនមានជូនពេកដល់បុគ្គលនោះ ។

ដល់ឆ្នាំ ១៩១៧ ខ្ញុំបានធ្វើអាំងស្បិកទ័រត្រួតត្រាការសិក្សាបឋមវិជ្ជា

ក៏បានដោយអំណាចគុណរបស់លោក ដែលលោកហៅខ្ញុំពីស្រុកក្រៅឲ្យចូលមកនៅក្នុងក្រុង គឺថាបើកុំតែបានលោកហៅខ្ញុំឲ្យមកនៅក្នុងក្រុង នោះខ្ញុំធ្វើម្តេចក៏នឹងបានខ្ទីជាអាំងស្សិកទីនេះបាន ។

ហើយខ្ញុំបានឃើញគុណសម្បត្តិរបស់លោក ដែលលោកនៅក្នុងផ្នួស ប្រព្រឹត្តធម៌វិន័យជាយ៉ាងយូរអង្វែង មិនសូវដែលឃើញលោកធ្វេសប្រហែសក្នុងការប្រតិបត្តិ ឲ្យឃ្លៀងឃ្លាតខុសពាក្យពុទ្ធោវាទ ហើយឃើញតែលោកមានព្យាយាមផ្សាយព្រះពុទ្ធសាសនា និងទំនុកបម្រុងដល់សិស្សានុសិស្សឲ្យបានចេះដឹងវិជ្ជាផ្សេង ៗ ហើយមានឧស្សាហ៍ណែនាំឲ្យទទួលប្រតិបត្តិល្អ ដើម្បីសម្រេចប្រយោជន៍បានជាច្រើនណាស់ ដូចកិត្តិសព្ទដែលខ្ញុំបានឮពីដំបូងនោះពិតមែន ។

ហើយខ្ញុំបានដឹងទៀត អបចិតាគុណ គឺគុណសេចក្តីប្រាថ្នាតិចរបស់លោក គឺថាតាំងពីលោកបានជាអ្នកប្រាជ្ញ ហើយបានលំដាប់ងារក្នុងក្រសួងសង្ឃតាំងពីទីព្រះគ្រូ រហូតដល់ងារព្រះមហាវិមលធម្មនេះ រហូតដល់រាជការចាត់ឲ្យធ្វើជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ ពីលាភសក្ការៈ ដែលកើតសម្រាប់បុណ្យលោកនោះ លោកមិនកំណាញ់ទុកដាក់ឲ្យជាទ្រព្យអសារឥតការ លាភទាំងអស់នោះ បានឃើញតែលោកចាត់ចែងសាងជាសាស្ត្រាព្រះត្រៃបិដក និងទូដាក់គម្ពីរនិងចំណាយជាពុទ្ធបូជា តាំងទុកជាទ្រព្យរបស់ព្រះពុទ្ធសាសនា ឃើញនៅមានជាច្រើនណាស់ ។

ដល់ពេលដែលលោកមានរោគាពាធហើយ លោកក៏មានមធុរកថានឹងសិស្សទាំងឡាយថា ខ្ញុំមានជម្ងឺតែម្តងនេះ ក៏បង្កើតជាបុញ្ញលាភដល់សិស្សទាំងឡាយ ៗ ដែលមានកតញ្ញូបានគោរពប្រតិបត្តិថែរក្សាតែម្តងនេះ ក៏ឲ្យអ្នកទាំងឡាយបាននូវឧត្តមសម្បត្តិចុះ ក៏ឯវាចានេះ ប្រហែលជាលោកមានជ្រាបដំណឹងថា លោកនឹងចេញចាកភពនេះទៅ លោកមិនបានទៅក្នុងភពនេះឲ្យសិស្សទាំងឡាយរវល់ថែរក្សាទៅខាងក្រោយទៀតទេដឹង ៗ

ក្នុងពេលក្រោយទៀត លោកក៏មានបណ្តាំថា អាយុសង្ខារនៃយើងសត្វទាំងឡាយមិនទៀងទាត់ស្ថិតស្ថេរទេ មានតែវិនាសទៅនិងសាបសូន្យទៅជាធម្មតា សិស្សទាំងឡាយដែលដឹងគុណ ហើយបានតបគុណគ្រូ នោះក៏ជាការល្អហើយត្រូវហើយ ក៏ប៉ុន្តែថាការនេះគ្រាន់តែជាការបន្ទាប់បន្សំទេ ក៏ឯការដែលជាធំបំផុត នោះគឺព្រះពុទ្ធសាសនា ដែលព្រះពុទ្ធប្រដៅថា កុំឲ្យធ្វើអំពើអាក្រក់ ឲ្យធ្វើតែអំពើល្អ និងធ្វើចិត្តឲ្យផូរផង់ ក្នុងការជាកុសល ឯណោះទេ សិស្សទាំងឡាយកុំបីមានធ្វេសប្រហែសក្នុងធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធនោះឡើយ ៗ

ដល់ពេលដែលជិតលោកនឹងទទួលអនិច្ចធម្ម នោះលោកក៏ពុំសូវមានវេទនាអន្ទះអន្ទែងពេកទេ ទុកជាទុក្ខគ្របសង្កត់ ព្រះអង្គលោកជាក្លាខ្លាំងយ៉ាងណា ក៏តាំងព្រះហឫទ័យ អត់ធន់ជាទីបំផុត មិនមានថ្ងូរប្តូរញញ្ញើតថ្ងូរឲ្យកូនសិស្សណាមួយបានឮ ហើយក៏យំព្រួយឡើយ

ស្រាប់តែដល់ពេលកំណត់ ដូចបានពោលហើយខាងលើ ក៏លោកនិមន្តចេញចាកខន្ធទៅកាន់ភពដទៃទៅ ។

សិស្សានុសិស្សទាំងឡាយ ដែលនៅចាំថែរក្សាដោយជុំវិញ ក៏សឹងមានសេចក្តីសង្វេគក្រៀមក្រំស្តាយស្រណោះអាឡោះអាល័យលោកគ្រូជាទីបំផុត ។

ឯខ្លួនខ្ញុំសោតក៏មានសេចក្តីសង្វេគដោយហេតុ ២ យ៉ាងគឺ:

១- ស្តាយសាសនាវាទរបស់លោកទាំងប៉ុន្មាន ដែលមានមកលើខ្លួនខ្ញុំ ដោយគិតឃើញថា ចាប់ដើមតាំងអំពីថ្ងៃនេះទៅ ខ្ញុំលែងបានស្តាប់ពាក្យប្រដៅអំពីលោកទៀតហើយ ។

២. សេចក្តីអាណិតនឹងស្តាយរូបលោក ដោយគិតឃើញថា ចាប់ដើមតាំងអំពីថ្ងៃនេះទៅ ខ្ញុំលែងបានឃើញរូបលោកទៀតហើយ ។

តែខ្ញុំមានគំនិតមួយ ដែលនឹងគិតសម្រាកសេចក្តីស្តាយស្រណោះឲ្យស្រាកស្រាលទៅ ដោយគិតថា លោកគ្រូព្រះមហាវិមលធម្ម ដែលលោកចេញចាកភពនេះទៅហើយ មានសង្ឃឹមថា លោកមុខជានឹងទៅកាន់សុគតិភពដោយពិត ។

សេចក្តីស្មូត្រពុំការុណាឧទ្ទិសផល

ចំពោះព្រះសពព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម នាម ថោង

# ក្នុងវេលាដែលអ្នករាជការក្នុងព្រះរាជបណ្ណាល័យ

# វេរភត្ត ប្រគេនដល់សង្ឃ

ក្រុមការ ជុំ មៅ ធ្វើរាជការនៅព្រះរាជបណ្ណាល័យ អធិប្បាយ

យ៉ាងហ្នឹង ហើយខ្ញុំក៏នៅស្ងៀមចាំស្តាប់លោក ទើបលោកប្រែធម៌នោះ
ប្រាប់ខ្ញុំថា ។

អចិរំវតយំកាយោ   បឋវឹអធិសេស្សតិ

ឆុឌ្ឌោអបេតវិញ្ញាណោ   និរត្ថំវកលិង្គរំ

ប្រែថា អយំកាយោ រីកាយនេះ អចិរំវត មិនតាំងនៅយូរឡើយ អបេតវិញ្ញាណោ ដែលមានសេចក្តីដឹងឃ្លាតចេញទៅហើយ ឆុឌ្ឌោ ជាគ្រឿងឆ្អឹងទទេ អធិសេស្សតិ នឹងដេកផ្ងាល់ បឋវឹ លើប្រឹថពី កលិង្គរំ ដូចជាអង្កត់ឧស និរត្ថំ មិនមានប្រយោជន៍ឡើយ ។ ចប់ហើយ ទើបលោកអធិប្បាយថា បណ្តាខន្ធទាំងឡាយ ៥ ប្រការនោះ រូបខន្ធប្រៀបដូចជាតួផ្ទះ វិញ្ញាណក្ខន្ធប្រៀបដូចជាអ្នកម្ចាស់ផ្ទះ វេទនាខន្ធ សញ្ញាខន្ធ សំខារក្ខន្ធ ប្រៀបដូចប្រពន្ធកូនចៅរបស់អ្នកម្ចាស់ផ្ទះនោះ ក៏អ្នកផ្ទះទាំងនោះដែលបានសេចក្តីសុខស្រួល ក៏ព្រោះអាស្រ័យនូវទីលំនៅនោះ មាំមួនមិនមានទ្រុតទ្រេត លុះទីនោះបាក់បែបរលំទៅ ដោយសត្រូវគឺភ្លើងឆេះ ឬខ្យល់រំលំទៅហើយ ជនទាំងនោះមិនអាចនឹងជ្រកកោនបានឡើយ ក៏រត់ខ្ចាត់ខ្ចាយទៅរកទីពួនទីពឹងថ្មីៗទៀត ឯផ្ទះចាស់នោះអស់ត្រូវការទៀតហើយ សេចក្តីនេះប្រៀបដូចម្តេចមិញ ថាប្រៀបដូចជា វិញ្ញាណ វេទនា សញ្ញា ចេតនា ធម្មជាតិទាំង ៤ នេះ ក៏តែងអាស្រ័យនៅនឹងរូបកាយ បានសេចក្តីសុខសប្បាយ ក៏ព្រោះតែកាយនោះមាំមួននៅ លុះកាយនោះដុះដាយវិនាសទៅ ធម្មជាតិទាំងនោះ មិនអាចនឹងតាំង

# សេចក្តីរំលឹកគុណឧទ្ទិសផល

ក្នុងថ្ងៃនេះ ខ្ញុំព្រះករុណា សូមថ្លែងសេចក្តីរំលឹកដល់គុណព្រះតេជព្រះគុណ ព្រះសពព្រះមហាវិមលធម្ម ជាតំណាងអ្នកពងការទាំងអស់គ្នា ក្នុងព្រះរាជបណ្ណាល័យ ដែលមានអ្នកស្រីការ៉ុឡែសជាអធិបតី ។

យើងខ្ញុំទាំងអស់គ្នាមានទុក្ខជាទម្ងន់ ក្នុងឱកាសដែលសេចក្តីមរណមកផ្តួលផ្តេកនូវបង្គោល ដែលយើងខ្ញុំពល់គ្នាធ្លាប់ពឹងពាក់ ធ្លាប់ផ្អែករៀងរៀបដកបមក ។ ចំពោះទឹងក្លែកយើងខ្ញុំពល់គ្នាផង តាមដោយដំណឹងដែលយើងបានដឹងផង នោះយើងហ៊ានពោលក្នុងទីនេះឥតញញើតថា សេចក្តីមរណៈនេះ មិនផ្តួលផ្តេកតែត្រឹមបង្គោលរបស់យើងឡើយ គឺថែមផ្តេកទាំងបង្គោលរបស់សាសនាទៀតផង បានជាហ៊ានពោលដូចនេះក្នុងកណ្តាលប្រជុំជន ព្រោះយើងបានរំពឹងពិចារណាថយក្រោយ ចំនួនប្រហែល ១៥ ឆ្នាំ ថយទៅអំពីវត្តប្រតិបត្តិក្នុងពុទ្ធសាសនា ឃើញថា ក្នុងជាន់នោះ សេចក្តីងងិតងងល់សេចក្តីល្ងង់វង្វេងនៅញាំញីពុទ្ធសាសនិកជនពន់ពេកណាស់ ហើយក្នុងថ្ងៃនេះតម្រិះប្រាជ្ញា នឹងសេចក្តីចេះដឹងខាងផ្លូវសាសនា ក៏បានចម្រើនជ្រាបផ្សាយទូទៅ ដល់ជនដែលគោរពប្រតិបត្តិ ជាច្រើនក្រាស់ក្រែលសមគួរហើយ ក៏សេចក្តីដែលចេះដឹងសេចក្តីដែលគោរពប្រតិបត្តិ ត្រូវតាមគន្លងនេះ មិនមែនបានមកពីណា គឺកើតឡើងដោយស្នាដៃដោយសេចក្តីឧស្សាហ៍ ដោយសេចក្តី

ព្យាយាមឥតធុញទ្រាន់នៃព្រះតេជព្រះគុណព្រះសពនេះឯង ដែលលោកមានសេចក្ដីប្រាថ្នាតែម៉្យាងក្នុង ១ ជាតិលោក គឺធ្វើដូចម្ដេចឲ្យតែខាងបានពុទ្ធសាសនារុងរឿងប៉ុណ្ណោះ គ្មានកិច្ចអ្វីដទៃផ្សេងក្រៅពីនេះទៀតឡើយ ឯកិច្ចការដែលជាថ្វីដៃរបស់លោកនោះ តាមដែលយើងរាល់គ្នាបានដឹងថាមានជាច្រើន សុទ្ធតែជាការខាងផ្លូវសាសនាទាំងអស់ ដែលលោកខំសង្វាតព្យាយាមធ្វើ ដរាបដល់ទល់នឹងថ្ងៃដែលអាពាធជាទម្ងន់ ទើបឈប់ ការទាំងប៉ុន្មានដែលលោកបានធ្វើនោះ យើងមិនបាននាំយកឈ្មោះ មកពោលរៀបរាប់ក្នុងទីនេះឡើយ គ្រាន់តែរំឭកឲ្យឃើញជាសេចក្ដីប៉ុណ្ណោះ ។

យើងបានដឹងម៉្យាងទៀតថា ព្រះតេជព្រះគុណព្រះសពលោកមានអធ្យាស្រ័យស្រឡាញ់ រាប់អានដល់សិស្សានុសិស្សពន់ពេកណាស់បណ្ដាសិស្សដែលសិក្សាក្នុងសាលាបរិយត្តិ ដែលខ្លួនលោកជាចាងហ្វាងមានសេចក្ដីស្រឡាញ់ គោរពប្រតិបត្តិដល់លោកឥតវៀស ទាំងគណៈធម្មយុត្តិ ទាំងគណៈមហានិកាយ ។

ក្នុងពេលដែលរោគាពាធ កំពុងប្រយុទ្ធជាខ្លាំង ហើយដែលលោកបានច្បាស់ក្នុងព្រះអង្គថា សេចក្ដីមរណៈកាន់តែមកជិតណាស់ហើយ នោះលោកផ្ដៀតផ្ដាំដល់សិស្សានុសិស្សទាំងពួង ដែលនៅជុំវិញលោកថា ឯរោគនោះកុំឲ្យគិតពេក ព្រោះមិនជាការធំអ្វីឡើយ គឺជាធម្មតាសម្រាប់លោកទេ ឯការដែលជាធំបំផុត, ធ្ងន់បំផុត ដែលត្រូវតែគិតខានមិនបាននោះ គឺការសាសនានោះឯង បើដូច្នេះ អំណើសឥតអំពីខ្លួនខ្ញុំទៅ

អ្នកទាំងឡាយកុំបីឡើយណាយញ្ញែក, ធុញទ្រាន់ ក្នុងការផ្សាយធម៌និងវិន័យឡើយ មានបណ្ដាំតទៅទៀតជាការផ្ដាំព្រះអង្គ អំពីធ្វើបុណ្យសព តែយើងមិនបានពោលក្នុងទីនេះ ។

ពាក្យបណ្ដាំខាងលើនេះ ជាបណ្ដាំមានតម្លៃដល់សិស្សានុសិស្សណាស់ នាំឲ្យចាំជាក់ក្នុងចិត្ត ហើយដុសដាប់ជានិច្ចក្នុងដួងហឫទយផង ព្រោះថា តែកាលណាទឹកឃើញពាក្យបណ្ដាំនេះហើយ ក៏នឹងឃើញដល់បណ្ដាំ ១ ទៀត ដែលជាបណ្ដាំរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ នៅវេលាដែលព្រះអង្គហៀបនឹងបរិនិព្វាន ។

គុណធម៌ទាំងប៉ុន្មាន ដែលបានពោលមកខាងលើនេះបណ្ដាលឲ្យយើងរាល់គ្នាព្រមព្រៀងរួមមូលគំនិត មកធ្វើកត្តកុងថ្ងៃនេះ វេរប្រគេនដល់ព្រះសង្ឃ ដើម្បីឧទ្ទិសផលានិសង្ស បញ្ជូនដល់ព្រះតេជព្រះគុណដែលនិមន្តចាកលោកនេះទៅកាន់សុគតិភពជាសុខស្ថាន ដើម្បីតបស្នងដល់គុណូបការ ដែលព្រះតេជព្រះគុណមាន ចំពោះដល់ព្រះរាជបណ្ណាល័យផង ចំពោះដល់អ្នកដែលគោរពធម៌វិន័យទាំងអស់គ្នា ដែលជាពុទ្ធសាសនូបត្ថម្ភក៏ផង ។

ដោយអំណាចពានានិសង្ស ដែលយើងខ្ញុំទាំងឡាយ ឧទ្ទិសចំពោះក្នុងថ្ងៃនេះ នឹងពានានិសង្សដែលបណ្ដាសិស្សានុសិស្សឯទៀត បានឧទ្ទិសពីថ្ងៃមុន ឬ នឹងឧទ្ទិសទៅថ្ងៃមុខនោះ សូមឲ្យព្រះតេជព្រះគុណញែកដល់ពុទ្ធសាសនាជានិច្ច កុំបីភ្លាំងភ្លេចឡើយ ហើយជួយឧបត្ថម្ភបណ្ដា

សិស្សានុសិស្ស ឲ្យខំសង្វាតព្យាយាមរៀនសូត្រផ្សាយធម៌វិន័យតទៅ ។

ទីបំផុតចប់នេះ យើងសូមប្រកាសឧទ្ទិសផលានិសង្សដល់ទេវតាទាំងឡាយ ដែលមានអានុភាពល្មមទទួលយកបានហើយនៅវេលាដែលបានទទួលផលដែលយើងឧទ្ទិសនេះ ត្រូវកុំព្រងើយកន្តើយមើលបំណាំឡើយ តោងជួយជ្រោមជ្រែងថែរក្សាព្រះពុទ្ធសាសនា ឲ្យបានរុងរឿងថ្កុំថ្កើងឡើង ។

ចប់

នៅបានឡើយ ក៏តែងអន្ទោលទៅរកភពថ្មីកើតទៀតដូចនោះឯង ។

រឿងនេះគួរកោត គួរសរសើរកម្លាំងសទ្ធា បញ្ញារបស់លោកណាស់ អម្បាលរោគគ្រប់សង្កត់ជាប់ជូន់ម្ល៉ឹងហើយ លោកនៅអាចប្រឹងសម្តែងធម៌ទេសនាតាមពុទ្ធភាសិត ទុកឲ្យយើងរាល់គ្នាស្តាប់បាន, - មិនមានអនុ-លោមបណ្តោយឲ្យសត្រូវវាត្រួតត្រាបានឡើយ ពិតមែនតែវាដណ្តើមចាប់យកព្រលឹងបាន តែគ្មានឃាត់គ្មានអង្វរសូកយកមកវិញទេ ។ ដល់ថ្ងៃទី ១៤ លោកបានហៅខ្ញុំចូលទៅជិតហើយលោកប្រាប់ថា នែលោក ៗ កុំព្រួយនឹងខ្ញុំពេកចុះ ការឈឺនិងស្លាប់នេះ ជាទោសសម្រាប់សំសារវដ្តទេ ឯចិត្តខ្ញុំក្នុងពេលនេះ ឥតមានតក់ស្លុតរញ្ជួយនឹងសេចក្តីស្លាប់នោះប៉ុន្មានទេ ធ្វើម្តេចថ្ងៃរះឡើងពីទិសខាងកើតតែងតែចុះទៅកាន់ទិសខាងលិច ជាធម្មតា សត្វកើតហើយតែងតែស្លាប់ទៅជាទំនៀមមិនខាន ហេតុហ្នឹងហើយបាន ជាខ្ញុំមិនតូចចិត្តប៉ុន្មានទេ ។ ប៉ុន្តែឥឡូវនេះលោក ចិត្តខ្ញុំកំពុងមូលស្រួលល្អណាស់ សូមលោកសម្តែងធម៌ត្រង់មរណាសន្នកាល ឲ្យខ្ញុំស្តាប់បន្តិច ខ្ញុំមុខជាខានស្តាប់ធម៌ពីរោះ អំពីសំណាក់អស់លោកទាំងឡាយហើយ ខ្ញុំបានឮហើយ ក៏មានចិត្តទោរទន់អន្ទង់អន្ទោចពេក តែខំអត់ទ្រាំដោយការចេះដឹង ហើយក៏ខំប្រឹងសម្តែងធម៌ទេសនាប្រគេនលោកក្នុងពេលនោះ ដោយសេចក្តីគោរពផ្ចិតផ្ចង់អស់ពីចិត្ត ដើមដំបូងឡើយខ្ញុំបានពិតលោកថា ព្រះតេជព្រះគុណ ព្រះសម្មាសម្ពុទ្ធ កាលដែលច្បាំងនឹងស្តេចមារព្រមទាំងសេនាដ៏ច្រើននោះ គួរព្រះអង្គជាបុគ្គលកំព្រាម្នាក់ឯង គង់លើរតនបល្ល័ង្ក

ក្រោមម្លប់ពោធិព្រឹក្ស ឥតមានញាតិមិត្រណាមួយនៅជួយកំដរផងឡើយ តែទ្រង់បានទឹកព្រេកដល់បារមីទាំង ១០ ប្រការ ហើយក៏បារមីទាំងនោះ សោតមិនព្រងើយកន្តើយឡើយ អាចមកប្រហារនូវពលក្រុងមារព្រមទាំង សេនាទាំងអស់ឲ្យវិនាសសាបសូន្យទៅដោយរហ័ស ទើបខ្ញុំបាច់សរសើរ អំពីបារមី ១០ ប្រការ មានទានបារមីជាដើមប្រគេនលោកស្តាប់ ដើម្បី នឹងឲ្យលោកទឹកព្រេកដល់ទាន ដែលលោកបានឲ្យដល់ជនទាំងឡាយ ច្រើន ដោយហោចទៅមានឲ្យដល់សត្វតិរច្ឆាន មានក្អែកជាដើមរាល់ ថ្ងៃមិនដែលដាច់ គុណសីលដែលលោកបានរក្សា គុណផ្នួសដែលលោក បានបួសក្នុងពុទ្ធសាសនា គុណបញ្ញាដែលលោកបានរៀនសូត្រចេះដឹង ធ្វើជាគ្រូអាចារ្យយ៉ាងធំជាដើម រហូតដល់ចប់បារមីទាំង ១០ ប្រការ ដោយ សេចក្តីសង្ខេប ។

សូមពិតព្រះតេជព្រះគុណ កាលព្រះសម្មាសម្ពុទ្ធសម្តែងធម៌ថ្វាយព្រះ វររាជបិតា ក្នុងកាលព្រះបិតាទៀបនឹងបរិនិព្វាននោះ ថាយ៉ាងនេះ សុណោ ហិ មហារាជ បពិត្រសម្តេចមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ ធម៌ទាំង ៣ ប្រការ គឺ អនិច្ចំ ទុក្ខំ អនត្តា ឈ្មោះថាត្រីពិធលក្ខណ ញាណ ធម៌នេះឯងហើយជាយានជំនិះ ជិះទៅកាន់ព្រះនិព្វាន របស់អ្នក ប្រាជ្ញទាំងឡាយ ជាស្ពានក្សេមក្សាន្តសម្រាន្តសុខ នឹងរកយានឯណា ឲ្យវិសេសជាងនេះមិនមានឡើយ ។

តពីនោះមក កម្លាំងលោកក៏កាន់តែថយចុះទៅ ពុំអាចមានពុទ្ធដីកា

ឲ្យពុទ្ធាំងបានឡើយ តែឯស្មាតីនោះនៅចាំដាក់ដកបដល់ផុតកិច្ច ។

ដល់វេលាយប់ថ្ងៃទី ១៥ លោកមានព្រះហឫទ័យប្រាថ្នាចង់ឲ្យសែង លោកព្រមទាំងគ្រែសម្ពីង ចេញទៅខាងក្រៅកុដិ ក៏អស់លោកទាំងឡាយបានធ្វើតាមបង្គាប់ លុះចេញទៅសឹងនៅធ្លៀងខាងក្រៅនោះដល់ម៉ោង ១២ យប់ ទើបនាំចូលមកកុដិវិញ ។

ដល់យប់ថ្ងៃទី ១៦ គឺថ្ងៃ អង្គារ ៤ កើត ខែស្រាពណ៍ ឆ្នាំថោះនព្វស័ក ពុទ្ធសករាជ ២៤៧០ ត្រូវនឹងឆ្នាំ ១៩២៧ ពេលនោះក៏កាន់តែមានកម្លាំងចម្រើនឡើងឯកម្លាំងរបស់លោកក៏ចេះតែថយចុះទៅ ដល់វេលាម៉ោង ១ យប់ឯអគ្រាគ្រលោកក៏តឿន ឲ្យលើកឡើងនឹងគង់ យើងពល់គ្នាក៏ធ្វើតាមបង្គាប់ដល់លើកហើយ ខ្យល់អស្សាសបស្សាសរបស់លោកនោះ ក៏ថយតិចទៅណាស់ហាក់ដូចជានឹងបាត់សូន្យទៅ ក៏មានសេចក្ដីភ័យគិតតែរៀងពល់គ្នា ក៏ដាក់លោកឲ្យសឹងពបទៅវិញ លុះសឹងទៅបន្តិច ក៏មានខ្យល់ស្រួលដូចដើមវិញ គឺសឹងផ្អៀងបែរព្រះកក្រូទៅខាងត្បូង យកសីសៈទៅខាងកើតហើយលោកសម្ងំការនោធមិដោយស្រួល ,ហាក់ដូចជាសឹងលក់ស៊ប់ឥតកម្រើក ដល់ម៉ោងមួយ ៣០ មីនុត ខ្យល់ក្នុងព្រះអង្គលោកក៏ប្រែបែរទៅជាដង្ហើមញឹកញាប់បន្តិច ទើបយើងគ្រប់គ្នាក៏ដឹងប្រាកដថា លោករៀបចំដំណើរនឹងនិមន្តធាប់ហើយ ហើយរៀបគ្នាអង្គុយព័ទ្ធជុំវិញពីខាងចុងព្រះបាទលោក ហើយសម្ងាត់សម្ងំមាត់ មិនឲ្យលាន់ឮសព្ទសូរអ្វីដល់តិចឡើយ ហើយតាំងសូត្រពុទ្ធគុណឡើងគ្រប់គ្នាទាំងអស់ ជាការអបអម

ដំណើរលោកឲ្យស្រួល និងជាគុណដើម្បីឃាត់បំបាត់នូវសព្វសូរសម្លេងទាំងពួងផង ឯខ្យល់ចេញចូលក៏ចេះតែថយតិចទៅ ៗ ដរាបដល់សម្រេចបុត្យាការកិច្ចរបស់លោក ក្នុងវេលាយប់ម៉ោងពីរ ១០ មីនុត ថ្ងៃអង្គារ ៤ កើត ខែស្រាពណ៍ ឆ្នាំ ថោះ នព្វស័ក ពុទ្ធសករាជ ២៤៧០ ត្រូវនឹងឆ្នាំ ១៩២៧ ។

លុះលោកដោះចិត្តចេញផុត អំពីខន្ធនេះ វេលាណាហើយ ព្រះភិក្ខុសង្ឃនិងសាមណេរគ្រប់រូបដែលនៅក្នុងទីនោះ ក៏កើតសេចក្តីក្រៀមក្រំជាទីសំវេគបម្លែកណាស់ និងរកអ្នកណា ១ ហារមាត់និយាយថាអ្វីមិនមានសោះឡើយ ក៏ស្ងៀមនៅតែពល់គ្នា ។

ឱអស់លោកសម្បុរសទាំងឡាយ សេចក្តីស្លាប់នេះជាសឹកសត្រូវនិងសត្វអ្វីខ្លាំងដល់ម្ល៉េះ ក៏ព្រះតេជព្រះគុណព្រះមហាវិមលធម្មអគ្គនេះ លោកជាទីពឹង ទីពប់អានរបស់យើងគ្រប់គ្នាពេកណាស់ យើងកំពុងតែធ្វើកិច្ចបូជា ពុំគួរសោះហើយនឹងមកប្ល័ន់មកដណ្តើមយករបស់តម្លៃនៃយើងពល់គ្នា នាំចេញទៅឥតមានកោតញញើតឡើយ ហេតុយ៉ាងហ្នឹងហើយបានជា ព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាថា ៖

យេ ចវុឍា ចទហរា　　យេ ចពាលា ចបណ្ឌិតា

អឌ្ឍា ចេវ ទលិទ្ទា ច　　សព្វេ មច្ចុបរាយណា

មត្តិកាភ្ជា យថា កតំ　　សុក្កកា រេ ឆកា ផនំ

បក្កាមក្កំ មហន្តញ្ញា　　ខុទ្ទកញ្ញា ភិការសំ

សព្វេ ភេទបរិយន្តា ឯវំ មច្ចាន ជីវិតំ

ប្រែថា សត្វទាំងឡាយឯណាចាស់ក្តី សត្វទាំងឡាយឯណាជាតិជាពាលក្តី ឬ បណ្ឌិតក្តី ក្មេងក្តី ជាអ្នកមានទ្រព្យស្តុកស្តម្ភ ឬ ខ្វះទ្រព្យក្តី សត្វទាំងឡាយទាំងពួងនោះ មានសេចក្តីចាស់ស្លាប់នូវស្ពាក់ខាងមុខគ្រប់ប្រាណ ។ ភាជនដីដែលជាងឆ្នាំងធ្វើហើយអំពីដី ទោះបីចាស់ក្តី ថ្មីក្តី ឬធំក្តីតូចក្តី ភាជនទាំងពួងនោះ ក៏គង់ដល់នូវកិរិយាបែកធ្លាយ ជាទីបំផុតរកលេសសល់គ្មានឡើយ សេចក្តីនេះគុណនាយ៉ាងណាមិញ ថាគុណនាដូចជីវិតសង្ខារនៃសត្វទាំងឡាយយ៉ាងនោះឯង ។

លុះដល់លោកទទួលមរណភាពកន្លងទៅបាន ១ ថ្ងៃ ក៏អ្នកស្រីស៊ុយសានការប៉ឺឡែប ដែលជាអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យកម្ពុជា ជាអ្នកគប់អានលោកមកយូរហើយនោះ ក៏បាននិមន្តនាលោកគ្រូអាចារ្យទាំងឡាយ ប្រមាណ ១០ រូប មានលោកគ្រូព្រះញាណបវរវិជ្ជា អែម ជាដើម ឲ្យរៀបសេចក្តីរំលឹករំលើកគុណលោក មានរឿងប្រវត្តិពង្សាវតារជាដើម ដើម្បីនឹងយកទៅបោះពុម្ពផ្សាយចេញជាប្រយោជន៍ ដល់អ្នកដែលត្រូវការ ។

## ឯសេចក្តីដែលតែងគ្រប់គ្នានោះគឺ :

១- ព្រះញាណបវរវិជ្ជា អែម រៀបសេចក្តី ១ ឲ្យឈ្មោះថា គុណូបការានុស្សរណសច្ចកិរិយា ។

២- ព្រះពុទ្ធវង្ស ម៉ី តែងសេចក្ដី ១ ឲ្យឈ្មោះថា គុណកថា ។

៣- ព្រះគ្រូសំសត្ថា ឈាត តែងសេចក្ដី ១ ឲ្យឈ្មោះថាសេចក្ដីប្រកាសគុណបដិការ ។

៤- ព្រះគ្រូសំវិជ្ជា តាត តែងសេចក្ដី ១ ឲ្យឈ្មោះថា សេចក្ដីថ្លែងគុណ ។

៥- ឧកញ៉ាកត្តិកជា យ៉ុង តែងសេចក្ដី ១ ឲ្យឈ្មោះថា កតវេទីកថា ។

៦- លោកអាចារ្យ អ៊ិត ហ័កា តែងសេចក្ដី ១ ឲ្យឈ្មោះថា កិត្តិគុណកថា ។

៧- ឧកញ៉ា សុធម្មប្រីជា កាង តែងសេចក្ដី ១ ឲ្យឈ្មោះថា កល្យាណមិត្តកថា ។

៨- ព្រះគ្រូវិមលបញ្ញា ស៊ូរ តែងសេចក្ដី ២ យ៉ាង ១ ឲ្យឈ្មោះថា ប្រវត្តិពង្សាវតារ ១ ទៀតឈ្មោះថា សេចក្ដីពណ៌នាមរណកិច្ច ។

៩- លោកអាំងស្ប៉ិកទ័រ ហ៊ឹម តែងសេចក្ដី ១ ឲ្យឈ្មោះថា វណ្ណកិត្តិកថា ។

១០- ព្រះញាណវីរិយ ឧ្យុង តែងសេចក្ដីពណ៌នាសរសើរគុណ ១ ។

១១- ក្រមការ ជុម ម៉ៅ តែងសេចក្ដីឧទ្ទិសផល ១ ។

# សេចក្តីថ្លែងគុណ

ព្រះមហាវិមលធម្ម ធាមហៀង ចាងហ្វាងសាលាបរិយត្តិជាន់ខ្ពស់

គឺ

*ព្រះគ្រូសំឃវិជ្ជា ហា. តាត*

អាចារ្យបង្រៀនសំស្ក្រឹត នៅសាលាបរិយត្តិជាន់ខ្ពស់ ភ្នំពេញ

*បានពណ៌នាដោយសង្ខេប*

# សេចក្ដីថ្លែងគុណ

ព្រះមហាវិមលធម្ម នាម ថោង ចាងហ្វាងសាលាបរិយត្តិដែលព្រះគ្រូសំឃវិជ្ជា នាគ អាចារ្យបង្រៀនសំស្ក្រឹត នៅសាលាបរិយត្តិ បាន ពណ៌នា ដោយសេចក្ដីដឹង ចំពោះខ្លួន ។

ព្រះតេជព្រះគុណមហាវិមលធម្ម នាម ថោង នាមកន្តិកិត្តិការ ព្រហ្មបណ្ឌិត ទីចាងហ្វាងសាលាបរិយត្តិ ដែលលោកទទួលអនិច្ចធម្មពី ថ្ងៃអង្គារ ៦ កើតខែស្រាពណ៍ ឆ្នាំថោះ ត្រូវនឹងថ្ងៃ ២ ខែអាគុស្តឆ្នាំ ១៩២៧ នេះ ខ្ញុំមានសេចក្ដីទុក្ខក្នុងចិត្ត នឹងសេចក្ដីស្ដាយលោកដោយក្រៃលែង ព្រោះលោកមានឧបការគុណចំពោះមកលើខ្លួនខ្ញុំ គួរឲ្យខ្ញុំមានកម្លាំងប្រឹង លើកដៃសរសេរ ពណ៌នាគុណរបស់លោក ដូចសេចក្ដីដែលមានតទៅ ក្នុងខាងក្រោយនេះ ។

ព្រះតេជព្រះគុណព្រះមហាវិមលធម្ម លោកជាគ្រូរបស់ខ្ញុំឈ្មោះ ធម្មាចារ្យ ឬឧទ្ទេសាចារ្យ ក្នុងអាចារ្យទាំង ៤ យ៉ាង ឯអាចារ្យ ៤ យ៉ាង នោះគឺ បព្វជ្ជាចារ្យ ១ ឧបសម្បទាចារ្យ ១ ធម្មាចារ្យ ឬ ឧទ្ទេសាចារ្យ ១ និស្សយាចារ្យ ១ សេចក្ដីអធិប្បាយថា លោកអង្គណាជាអ្នកឲ្យ នូវព្រះត្រៃសរណគមន៍ និងសិក្ខាបទដល់សាមណេរ លោកអង្គនោះ ឈ្មោះថាបព្វជ្ជាចារ្យ គឺអាចារ្យ ឬ គ្រូជាអ្នកបំបួសសាមណេរ ។

លោកអង្គណាជាអ្នកពោលនូវកម្មវាចា លោកអង្គនោះឈ្មោះថា ឧបសម្បទាចារ្យ គឺអាចារ្យក្នុងឧបសម្បទកម្ម ឬគ្រូសូត្រ ។

លោកអង្គណាជាអ្នកបង្ហាត់បង្ហាញនូវបាលីក្តី អដ្ឋកថាក្តី ឬពន្យល់ប្រាប់នូវបទធម៌ណាមួយ លោកអង្គនោះឈ្មោះថា ធម្មាចារ្យ គឺអាចារ្យ ឬគ្រូជាអ្នកបង្រៀនធម៌ ។ ភិក្ខុសាមណេរមកអង្គុយប្រណោងក្នុងទីចំពោះមុខ ហើយពោលសុំនិស្ស័យដោយពាក្យថា :

អាចរិយោ មេ ភន្តេ ហោហិ អាយស្មតោ និស្សាយ វច្ឆាមិ

បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាជាអាចារ្យនៃខ្ញុំ ខ្ញុំសូមនៅអាស្រ័យនឹងព្រះករុណាដ៏មានអាយុ ពោលដូចនេះ ៣ ដង ក្នុងសំណាក់លោកអង្គណា លោកអង្គនោះព្រមទទួលជាអាចារ្យហើយសម្តែងឲ្យដឹងដោយអាការនៃកាយឬវាចា លោកអង្គនោះ ឈ្មោះថានិស្សយាចារ្យ គឺអាចារ្យឬគ្រូជាអ្នកឲ្យនិស្ស័យ ។

ចំណែកខាងសិស្សក៏មាន ៤ ដូចគ្នា គឺសិស្សទី ១ ឈ្មោះបព្វជ្ជន្តេវាសិក គឺជាសិស្សនៃឧបសម្បទាចារ្យ, សិស្សទី ២ ឈ្មោះឧបសម្បទន្តេវាសិក គឺជាសិស្សនៃឧបសម្បទាចារ្យ សិស្សទី ៣ ឈ្មោះថា ធម្មន្តេវាសិក គឺជាសិស្សនៃធម្មាចារ្យ, សិស្សទី ៤ ឈ្មោះថានិស្សយន្តេវាសិក គឺជាសិស្សនៃនិស្សយាចារ្យ ។

មានគ្រូ ១ ពួកទៀតឈ្មោះថា ឧបជ្ឈាយ៍ ។ នោះមានសេចក្តីអធិប្បាយដូចនេះថា សាមណេរក្តី ភិក្ខុក្តី ដែលពោលពាក្យសូមនូវនិស្ស័យ គឺសូមទីអាស្រ័យនៅដោយពាក្យថា "ឧបជ្ឈាយោ មេ ភន្តេ ហោហិ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាជាឧបជ្ឈាយ៍នៃខ្ញុំ" ដូចនេះ ចំពោះទីនភិក្ខុអង្គឯណា ភិក្ខុអង្គនោះឈ្មោះថាជាឧបជ្ឈាយ៍ ។ រីឯសិស្សរបស់ឧបជ្ឈាយ៍នោះឈ្មោះថាជាសទ្ធិវិហារិក ។

រីឯព្រះតេជព្រះគុណមហាវិមលធម្ម លោកជាគ្រូរបស់ខ្ញុំឈ្មោះថា "ធម្មាចរិយ" ព្រោះលោកបានប្រាប់ពន្យល់អំពីរបៀបបាលីខុសនឹងត្រូវ ព្រមទាំងសេចក្តីដែលប្រែចេញពីបាលីដែលគ្រូ ១ នោះជាច្រើនកន្លែង និងអត្ថនៃធម៌ទាំងឡាយដែលជាពុទ្ធភាសិតនោះក៏ជាច្រើនកន្លែងណាស់ តែមិនបាច់នាំយកមកពណ៌នាក្នុងទីនេះឡើយ ចំណែកខ្លួនខ្ញុំត្រូវជាធម្មន្តេវាសិករបស់លោក ។

គុណរបស់លោកដែលមានចំពោះមកលើខ្លួនខ្ញុំនោះ មិនត្រឹមតែដោយហេតុ ដែលបានពណ៌នាដូចខាងលើនេះឡើយ មានក្រៅអំពីនេះច្រើនទៅទៀត ដូចកាលដែលខ្លួនខ្ញុំទើបនឹងបានឧបសម្បទាថ្មីៗគិតមកដល់ឥឡូវនេះ ចំនួន ១៦ ឆ្នាំមកហើយ កាលនោះលោកពុំទាន់ស្គាល់ខ្ញុំដោយជាក់លាក់នៅឡើយ លុះដល់សម័យ ដែលខ្ញុំបានចូលប្រឡងប្រ-

យោគ ប្រែបាលីនៅទីឧបោសថរតនារាមវិហារព្រះកែវមរកតបាន ៤ ប្រ· យោគ លោកក៏បានស្គាល់ខ្ញុំជាក់លាក់ហើយមានព្រះទ័យរាប់អានខ្ញុំតាំងពីនោះរៀងមក លោកទំនុកបម្រុងសង្គ្រោះឲ្យខ្ញុំមានកម្លាំងក្នុងការរៀនសូត្របំពោះវិជ្ជាខាងផ្លូវព្រះពុទ្ធសាសនា ថែមចម្រើនៗឡើង ដោយលំ-ដាប់រៀងមក ។ កាលពីព្រះពុទ្ធសករាជ ២៤៦៥ ដល់ ២៤៦៦ គ្រិស្តសករាជ ១៩២២ ដល់ ១៩២៣ រាជការបានចាត់ខ្លួនខ្ញុំ និងព្រះគ្រូសំសត្តា ជ· ឃា ត ទៅនៅរៀនសំស្ក្រឹត, អក្សរៈថ្នបុរាណនិងពង្សាវតារសាសនា ឯក្រុងហាណូយក្នុងសំណាក់លោក ល្វី ហ្វីណូត៍ ជាដើម នោះព្រះតេជព្រះគុណព្រះមហាវិមលធម្ម លោកក៏មានព្រះទ័យត្រេកអរណាស់ បានទំនុកបម្រុងដល់ខ្ញុំដោយកិច្ចសង្គ្រោះផ្សេងៗ ។

តាមដែលខ្ញុំសង្កេតមើលទៅឃើញថា ដែលលោករាប់អាននិងសង្គ្រោះទំនុកបម្រុងឲ្យរៀនសូត្រនោះ មិនមែនតែខ្លួនខ្ញុំ ១ នេះទេ មានច្រើនណាស់ ដែលលោកទំនុកបម្រុងយ៉ាងនេះ ហើយលោកនឹងត្រូវការចង់បានអ្វីអំពីអ្នកណា ដែលលោកទំនុកបម្រុងនោះ មិនឃើញមានឡើយ គុណរបស់លោកដែលខ្ញុំនាំមកថ្លែងត្រង់នេះ ឃើញត្រូវគ្នានឹងពាក្យសុភា-សិតខ្លះ ក្នុងគម្ពីរសំស្ក្រឹតថា “ព្រះអាទិត្យមែងធ្វើស្រះឈូកឲ្យរុងរឿង ព្រះចន្ទមែងធ្វើស្រទាប់ផ្កាឈូកឲ្យរីកស្គុះស្គាយ មេឃមិនបាច់អ្នកណាមួយអង្វរគេសុំឡើយ ក៏អាចញុំាងទឹកភ្លៀង ឲ្យធ្លាក់ចុះមកដោយខ្លួនឯង

សប្បុរសទាំងឡាយ រមែងបម្រុងខ្លួន ទំនុកបម្រុងសង្គ្រោះអ្នកដទៃក៏ដូចនោះ” មានសុភាសិត ១ ទៀតក្នុងគម្ពីរសំស្ក្រឹតដូចគ្នាថា “ដើមឈើទាំងឡាយកាលបើមានផ្លែច្រើន ក៏រមែងទន់មែកចុះមកឯង ផ្ទៃមេឃកាលបើមានទឹកដក់នៅថ្មី ៗ ក៏រមែងសំយុងចុះមកពីចម្ងាយ ជនជាសប្បុរសកាលបើមានកម្លាំងច្រើន ក៏មិនដែលត្រឡប់ទៅជាឥតផលសោះសូន្យទេឡើយនេះជាសភាពរបស់បណ្ដាជនអ្នកធ្វើឧបការដល់អ្នកដទៃ ” ។

ចំណែកខាងខ្លួនខ្ញុំសោត តាំងពីបានចូលទៅជ្រកកោននៅក្នុងសេចក្ដីទំនុកបំរុងនិងសង្គ្រោះរបស់លោកក៏បានចម្រើនចំណេះវិជ្ជា និងកេរ្ដិ៍ឈ្មោះឡើងដោយលំដាប់ តាមដែលខ្លួនខ្ញុំឃើញពិតនោះមិនមែនតែខ្លួនខ្ញុំ ១ នេះទេ មានអ្នកឯទៀតជាច្រើនរូប ដែលស្ថិតនៅក្នុងសេចក្ដីទំនុកបម្រុងលោក ហើយបានចម្រើនដោយគុណសម្បត្តិទាំងឡាយមានចំណេះវិជ្ជាជាដើម តែគ្រន់ចម្រើនតិចនិងច្រើននោះតាមវាសនាឧបនិស្ស័យអ្នកកសាង ឧបមាដូចរុក្ខជាតិទាំងឡាយ ដែលជាពូជឈើមានផ្លែ ពូជឈើខ្លះមានផ្លែតិច ពូជឈើខ្លះមានផ្លែច្រើន ពូជឈើទាំងនោះ កាលដែលគេយកទៅបណ្ដុះដាំនឹងទីដី ១ កន្លែង ដែលមានដីជាតិល្អ វេលាដែលដុះលូតលាស់ល្អឡើងហើយ មានផ្លែនោះមានផ្លែច្រើន និងតិចទៅតាមពូជ ឯទីដីគ្រាន់តែជួយឧបត្ថម្ភឲ្យជាតិឈើជាតិដំណាំមានកម្លាំងលូត

លាស់ផុះបម្រើនល្អឡើងប៉ុណ្ណោះ ត្រូវគ្នានឹងពាក្យសុភាសិតពីបុរាណ ជាភាសាបាលីមួយគាថា ថា:

រុក្ខោ សុភូមិ និស្សាយ    បុប្ផ ផលំ បវឌ្ឍតិ
សប្បុរិសូប និស្សាយ    មហាបុញ្ញំ បវឌ្ឍតិ

ប្រែថា ដើមឈើកាលបើអាស្រ័យនូវទីដីល្អហើយ ក៏រមែងលូតលាស់មានផ្លែផ្កាបម្រើនឡើងល្អ អ្នកដែលចូលទៅអាស្រ័យនឹងសប្បុរស ក៏រមែងមានសេចក្តីល្អបម្រើនឡើងយ៉ាងធំ ដូចនោះ ។

ម្យ៉ាងទៀតពីព្យាយាម និងការផ្សាយសេចក្តីអនុគ្រោះ ដល់អ្នកដទៃរបស់លោកនោះ ដូចនេះ ៖

១- បង្ហាត់បង្រៀនប្រែព្រះត្រៃបិដកពីបាលីជាខ្មែរ ថ្វាល់ព្រះអគ្គលោក ។

២. បង្ហាត់បង្រៀនឲ្យចេះពោលភាសាបាលីឲ្យត្រឹមត្រូវ ។

៣. កសាងគម្ពីរព្រះត្រៃបិដក ដោយចំណាយទ្រព្យរបស់លោកកសាង និងទទួលភារៈជួយក្នុងការកសាងរបស់អ្នកមានសទ្ធាចំណាយទ្រព្យកសាងព្រះត្រៃបិដកនោះ ឲ្យបានសម្រេចតាមសេចក្តីប្រាថ្នារបស់អ្នកមានសទ្ធានោះ ។ ។

៤- បានប្រែសេចក្តីធម៌ពីបាលីមកជាភាសាខ្មែរ ប្រយោជន៍នឹងឲ្យអ្នកដែលមិនចេះភាសាបាលី បានដឹងអត្ថរសរបស់ព្រះពុទ្ធសាសនាផង ។

៥- បានផ្ទៀងផ្ទាត់សេចក្តីប្រែ ដែលអស់លោកទាំងឡាយបានប្រែពីបាលីមកជាខ្មែរ ហើយយកទៅប្រគេនលោកសុំឲ្យលោកផ្ទៀងផ្ទាត់ឲ្យ លោកក៏ខំឆ្លៀតពេលផ្ទៀងឲ្យជាប់ដល់ហើយស្រេចៗ

៦- ទំនុកបម្រុងបិណ្ឌមភិក្ខុសាមណេរជាច្រើន ក្នុងសំណាក់លោក គឺលោកចំណាយប្រាក់ដែលពុជការ ប្រគេនរាល់ខែនោះ ជាតម្លៃនៃភោជនាហារ ប្រគេនភិក្ខុសាមណេររាល់ថ្ងៃ លោកឥតមានសន្សំទុកដាក់ឡើយ នេះជាសេចក្តីពិត ប្រមូលសេចក្តីទាំងអស់នេះឃើញថាព្រះតេជព្រះគុណ មហាវិមលធម្ម លោកប្រកបកិច្ចតែខាងបំណែកផ្លូវព្រះពុទ្ធសាសនាទាំងអស់ គួរឲ្យមានសេចក្តីស្ងើចសរសើរលោក សូម្បីរបស់ដូចជាហិរញ្ញវត្ថុ ដែលគេរមែងនឹងឲ្យសម្រេចប្រយោជន៍ ប្រកបទៅខាងទ្រព្យរបស់ជាគ្រឿងប្រើប្រាស់ឲ្យរុងរឿង ឲ្យហ៊ុកហាក់នៅនាលោកិយនេះ បំណែកព្រះអង្គលោក ៗ ចំណាយឲ្យសម្រេចទៅខាងផ្លូវព្រះពុទ្ធសាសនាទាំងអ.ស់ សេចក្តីត្រង់នេះនាំឲ្យឃើញច្បាស់ថា ព្រះអង្គលោកជាសប្បុរសពិត ដូចមានសុភាសិតពីបុរាណក្នុងគម្ពីរបាលី ១ គាថាថា:

អម្ពុំ បិវន្តិ នោ នជ្ជោ    រុក្ខា ខាទន្តិ នោ ផលំ
មេឃោ ភាទាចិ នោ សស្សំ    បរត្ថាយ សតំ ធនំ

ប្រែថា ស្ទឹងបួរទន្លេមិនដែលផឹកទឹកដោយខ្លួនឯងឡើយ ឈើទាំងឡាយ ក៏មិនដែលបរិភោគផ្លែដោយខ្លួនឯងឡើយ ភ្លៀងដែលធ្លាក់

ចុះមក ក៏មិនដែលស៊ីនូវសន្ទូងរបស់អ្នកស្រុកដល់ម្តងឡើយ ទ្រព្យរបស់សប្បុរសទាំងឡាយ ក៏រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់អ្នកដទៃដូចនោះឯង ។

សូមថ្លែងគុណ ព្រះតេជព្រះគុណមហាវិមលធម្ម ដោយសង្ខេបប៉ុណ្ណោះ

ព្រះគ្រូសំឃវិជ្ជា ហ. តាត

អាចារ្យបង្រៀនសំស្រ្កឹត នៅសាលាបរិយត្តិជាន់ខ្ពស់ ភ្នំពេញ

សេចក្តីប្រកាសគុណាបដិការ

---

របស់ព្រះមហាវិមលធម្មនាម ថោង ចាងហ្វាងសាលាបាលីជាន់ខ្ពស់

ក្រុងភ្នំពេញ

គឺ

ព្រះគ្រូសិសត្ថា ជ. ឈសាត អាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់

ពណ៌នាសរសើរ

# សេចក្ដីប្រកាសគុណាបដិការ

ព្រះតេជព្រះគុណព្រះមហាវិមលធម្ម ហៀង ល្វង នាមដើមថោង នាមគន្ថិកការ ព្រហ្មបណ្ឌិត ជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ ។ លោកជាធម្មាចារ្យរបស់ខ្ញុំ ខ្ញុំជាធម្មន្តេវាសិករបស់លោក ។ លោកមានឧបការគុណលើខ្លួនខ្ញុំច្រើនក្រៃពេកមិនល្មម ខ្ញុំនឹងថ្លែងដោយសេចក្ដីសង្ខេបក្នុងទីនេះបានឡើយ ព្រោះហេតុនោះក្នុងទីនេះ ខ្ញុំសូមថ្លែងនូវសេចក្ដីដោយឡែក ចំពោះបដិការកិច្ចក្នុងកាលដែល លោកចាប់មានអាពាធរហូតដល់លោកទទួលអនិច្ចធម្មដល់នូវមរណភាពទៅ ។

លោកចាប់មានអាពាធជាទម្ងន់ពីថ្ងៃច័ន្ទ ៤ កេីត ខែអាសាឍ ឆ្នាំថោះនព្វស័ក ត្រូវនឹងថ្ងៃ ១៨ ខែជូះយេត ឆ្នាំ ១៩២៧ ដល់មកថ្ងៃអង្គារ ៤ កើត ខែស្រាពណ៍ ឆ្នាំថោះនព្វស័ក ព្រះពុទ្ធសករាជ ២៤៧០ ត្រូវនឹងថ្ងៃ ២ ខែអាគុត ឆ្នាំ ១៩២៧ លោកទទួលអនិច្ចធម្មទៅនៅវេលាម៉ោង ២ និង ១០ នាទីយប់ ក្នុងកាលអាយុសង្ខារលោកគម្រប់ ៦៨ ឆ្នាំ ។

អាពាធនោះជាភេទបង្អោរ ឆាន់បង្អាន់មិនបាន ក្នុងកាលដែលលោកកំពុងមានអាពាធនោះ បណ្ដាសិស្សានុសិស្សទាំងអស់ក៏សឹងតែឈ្លូងនរ យកចិត្តទុកដាក់ខំប្រឹងថែទាំព្រាំជម្ងឺលោកដោយសេចក្ដីគោរព និងសេចក្ដីខ្នះខ្នែងខ្វល់ខ្វាយតែរាល់គ្នា ឥតមានលោកណា អ្នកណាមួយព្រងើយកន្តើយឡើយ អាពាធលោកនោះក៏ចេះតែធ្ងន់ចុះជាដរាប ។

លុះដល់មកថ្ងៃពុធ ១៣ រោច ខែអាសាឍ ឆ្នាំថោះនព្វស័ក ត្រូវនឹងថ្ងៃ ២៧ ខែស៊ុយយេត ឆ្នាំ ១៩២៧ អស់សិស្សានុសិស្សទាំងអស់ប្រឹក្សាព្រមព្រៀងគ្នា ថានឹងនិមន្តព្រះភិក្ខុសង្ឃឲ្យបម្រើនព្រះបរិត្តប្រគេនលោក តាមសណ្តាប់ធ្នាប់ទំនៀមនៃពុទ្ធសាសនិកជន ក៏បានចូលទៅពិតលោកថា យើងខ្ញុំព្រះករុណាទាំងអស់គ្នា នឹងនិមន្តព្រះភិក្ខុសង្ឃឲ្យបម្រើនព្រះបរិត្តប្រគេនព្រះតេជព្រះគុណបាន ៣ ថ្ងៃ គឺតាំងពីថ្ងៃ ១៣ រោចនេះទៅដល់ថ្ងៃ ១៥ រោចខែអាសាឍនេះ តើព្រះតេជព្រះគុណសព្វព្រះទ័យ និងនិមន្តលោកឲ្យបម្រើនព្រះបរិត្តណា លោកមានព្រះពុទ្ធដីកាថា ខ្ញុំពេញចិត្តចង់ស្តាប់ពោជ្ឈង្គបរិត្តនិងគិរិមានន្ទសូត្រ បើលោកទាំងអស់គ្នាថា នឹងនិមន្តលោកឲ្យបម្រើនដល់ ៣ ថ្ងៃដូច្នោះខ្ញុំមានអំណរណាស់ ក្នុងថ្ងៃដំបូងនេះ សុំនិមន្តលោកឲ្យបម្រើនមហាចុន្ទពោជ្ឈង្គបរិត្តចុះ ដល់ថ្ងៃជាគម្រប់ ២ សុំឲ្យលោកបម្រើនមហាកស្សបពោជ្ឈង្គបរិត្ត និង មហាមោគ្គល្លានពោជ្ឈង្គបរិត្តដល់ថ្ងៃជាគម្រប់ ៣ ឲ្យលោកបម្រើនគិរិមានន្ទសូត្រ ៗ អស់សិស្សានុសិស្សទាំងអស់ ក៏ទទួលតាមសេចក្តីពេញព្រះទ័យរបស់លោក ៗ នោះខ្ញុំក៏បានតែងបាលីជាគាថាហៅថា "សច្ចកិរិយាគាថា" ជាសេចក្តីប្រកាសសច្ចកិរិយាតាមសណ្តាប់នៃអ្នកប្រាជ្ញ ចំពីបុរាណរៀងមក ដោយតាំងចិត្តប្រតិស្ឋអធិដ្ឋានថា សូមឲ្យលោកបានជាសះស្បើយ ៗ សច្ចកិរិយាគាថានោះ មានសូត្រគ្រប់ទាំង ៣ ថ្ងៃខ្ញុំសូត្រខ្លួនខ្ញុំ ក្នុងវេលាដែល

បម្រើនព្រះបរិត្តចប់ហើយ ពីព្រោះខ្ញុំក៏ជាអ្នកសូត្របម្រើនព្រះបរិត្តគ្រប់តាំង ៣ ថ្ងៃជាមួយនឹងអស់លោក អ្នកសូត្របម្រើននោះថែរ ។

សច្ចកិរិយាគាថាតាំងអស់នោះ ដូចមានក្នុងខាងក្រោយតទៅនេះ ៖

## សច្ចកិរិយាគាថាក្នុងថ្ងៃដំបូង

កកុធោ លោកនាថោយំ ចុន្ទត្ថេរស្សសន្តិកា
សុត្វាតស្មិំខណេយេវ អហោសិនិរុបទ្ទវោ
ពោជ្ឈង្គពលសំយុត្តំ ឥធានិតំសុសាវិតំ
ឥមស្មាបិបរិត្តស្ស សុសាវិតស្សតេជសា
អញាតិកោមហាថេរោ ណាមេនព្រហ្មបណ្ឌិតោ
មហាវិមលធម្មោវ ភជាគណោតិវិស្សុតោ
និន្ទុក្ខោរោគមុត្តោច សុខិតោហោតុសព្វទា
ទីឃាយុកោអនាមយោ និត្ភយោនិរុបទ្ទវោ
ចិរំជីវតុធោថេរោ រក្ខិតុំធោចអាយតី
ឯតេនសច្ចវជ្ជេន មាហោន្តុសព្វុបទ្ទវា
ឯតេនសច្ចវជ្ជេន សុវត្ថិហោតុសព្វទា

ប្រែ ៖ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ជាទីពឹងពំនាក់នៃសត្វលោក មានកាលមួយថ្ងៃ ព្រះអង្គមានព្រះរោគាពាធជាទម្ងន់ បានទ្រង់ព្រះសណ្តាប់នូវពោជ្ឈង្គបរិត្តឯណា អំពីសំណាក់នៃព្រះចុន្ទត្ថេរ ហើយ

ទន់បានជាសះស្បើយក្នុងខណៈដែលចប់ព្រះបរិត្តនោះ ៗ ព្រះបរិត្តនោះ ជៈធម៌ប្រកបដោយកម្លាំងនៃសត្តពោជ្ឈង្គ យើងបានសូត្រហើយក្នុងកាលអម្បាញ់មិញនេះ ដោយតេជៈនៃព្រះបរិត្ត ដែលយើងសូត្រហើយនេះ ក៏សូមឲ្យព្រះតេជព្រះគុណព្រះមហាវិមលធម្ម ព្រហ្មបណ្ឌិត ជាកជាគណៈ ដែលលោកមានអាពាធនេះ បានជាសះស្បើយពាកជម្ងឺនេះ កុំឲ្យមានសេចក្តីទុក្ខក្រវល់ក្រវាយ សូមឲ្យបានប្រកបដោយសេចក្តីសុខ ឲ្យមានទីឃាយុ កុំឲ្យមានជម្ងឺតម្កាត់ កុំឲ្យមានភ័យ កុំឲ្យមានឧបទ្រពអ្វី មកបៀតបៀនឡើយ ឲ្យបានសព្វកាលរៀងទៅ ៗ សូមឲ្យព្រះតេជព្រះគុណជាថេររបស់យើង លោកមានជីវិតទៅ ឲ្យបានអស់កាលយូរអង្វែងទៅ ដើម្បីនឹងបានបីបាច់រក្សាអស់យើងខ្ញុំតរៀងទៅ ។

ដោយកិរិយាពោលនូវពាក្យសត្យនេះ ឧបទ្រពទាំងពួងចូរកុំបីមានឡើយ ។ ដោយកិរិយាពោលនូវសត្យនេះ សុខសួស្តីចូរមានឲ្យបានសព្វ ៗ កាលទៅហោង ។

## សច្ចកិរិយាគាថាក្នុងថ្ងៃជាគំរប់ ២

កស្សបោ មោគ្គល្លានោ ច  ថេរេ អាពាធិកា តទា
ទុក្ខិតា ពាឡ្ហគិលានាយំ  បរិត្តំ មុនិសន្តិកា
សុត្វា តស្មឹ ខណេ យេវ  អហោសុំ និរុជ្ជកា

ពោជ្ឈង្គផលសំយុត្តំ ឥណានិតំសុសារិតំ
ឥមស្សាបិបរិត្តស្ស សុសារិតស្សតេជសា
អាពាធិកោមរាជេក ណាមេនព្រហ្មបណ្ឌិតោ
មហាវិមលធម្មោវ ភជាតលោកិតិវិស្សុតោ
ធិន្ទុក្ខោភេគមុត្តោច សុខិតោហោតុសព្វទា
ទីឃាយុកោអនាមយោ និព្ភយោ និរុបទ្ទវោ
ចិរំជីវតុសោជេភោ រក្ខិតុំធោចអាយតិ
ឯតនសច្ចវជ្ជេន មាហោន្តុសព្វុបទ្ទវា
ឯតេនសច្ចវជ្ជេន សុវត្ថិហោតុសព្វទា

ប្រែ : ព្រះមហាថេរទាំងឡាយ ២ អង្គ គឺព្រះមហាកស្សប ១ ព្រះមហាមោគ្គល្លាន ១ មានកាលសម័យមួយ ។ នោះ លោកមានអាពាធជាទម្ងន់ ប្រកបដោយសេចក្តីទុក្ខក្រៃល់ក្រៃយដូចគ្នា លោកបានស្តាប់នូវព្រះបរិត្តឯណា អំពីសំណាក់នៃព្រះសក្យមុនីជាម្ចាស់ ហើយបានជាសះស្បើយ ក្នុងខណៈដែលចប់ព្រះបរិត្តនោះ ។ ព្រះបរិត្តនោះជាធម៌ប្រកបដោយកម្លាំងនៃសត្តពោជ្ឈង្គយើងបានរៀនហើយក្នុង កាលអម្បាញមិញនេះ ។ល។ សេចក្តីប្រែតពីត្រឹមនេះរៀងទៅ ដូចគ្នានឹងសច្ចកិរិយាគាថាក្នុងថ្ងៃដំបូង ។

# សច្ចកិរិយាគាថាក្នុងថ្ងៃជាគម្រប់ ៣

ថេរោ យំ គិរិមានន្ទោ អានន្ទត្ថេរសន្តិកា
សុត្វា តស្មឹ ខណេយេវ អហោសិ និរុបទ្ទវោ
ទសសញ្ញាបសំយុត្តំ ឥទានិ តំ សុភាសិតំ
ឥមស្សាបិ បរិត្តស្ស សុភាសិតស្ស តេជសា
អាពាធិកោ មហាថេរោ ធាមេន ព្រហ្មបណ្ឌិតោ
មហាវិមលនម្មោ ភជាតណោតិ វិស្សុតោ
និទ្ទុក្ខោ រោគមុត្តោ ច សុខិតោ ហោតុ សព្វទា
ទីឃាយុកោ អនាមយោ និព្ភយោ និរុបទ្ទវោ
ចិរំ ជីវតុ សោ ថេរោ រក្ខិតុំ សោ ច អាយតឹ
ឯតេន សច្ចវជ្ជេន មា ហោន្តុ សព្វុបទ្ទវា
ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា

ប្រែ : ព្រះគិរីមានន្ទត្ថេរ មានកល ១ ថ្ងៃនោះ មានអាពាធជាទម្ងន់ ប្រកបដោយសេចក្តីទុក្ខក្រៃល់ក្រៃយ លោកបានស្តាប់ព្រះបរិត្តឈ្មោះ ថា គិរិមានន្ទសូត្រឯណា អំពីសំណាក់នៃព្រះអានន្ទត្ថេរ ហើយលោកបាន ជាសះស្បើយក្នុងខណៈដែលចប់គិរិមានន្ទសូត្រនោះ ៗ គិរីមានន្ទសូត្រ នោះ ជាធម៌ប្រកបដោយសញ្ញាទាំង ១០ យ៉ាង យើងបានសូត្រហើយ

ក្នុងកាលសម្បាលមិញនេះ ។ល។ សេចក្ដីប្រែតពីត្រឹមនេះរៀងទៅ ដូចគ្នានឹងសច្ចកិរិយាគាថាក្នុងថ្ងៃដំបូង ។

ពល់ថ្ងៃទាំង ៣ កាលដែលខ្ញុំបានសូត្រ ប្រកាសសច្ចកិរិយាគាថាទាំងនេះរួចហើយ ព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម លោកបានទទួលអនុមោទនាថា សាធុ លាន់ឮខ្លាំងដូចមនុស្សមិនមានជម្ងឺ ព្រមជាមួយនឹងអស់លោកព្រះថេរានុថេរ ភិក្ខុសាមណេរ នូវអស់ឧបាសកទាំងឡាយដែលមកប្រជុំក្នុងទីនោះ សច្ចកិរិយានោះ មិនមែនតែរបស់ខ្ញុំម្នាក់ឯងនេះទេ សច្ចកិរិយារបស់ព្រះថេរានុថេរ នូវអស់សិស្សានុសិស្សឯទៀតរបស់លោកជាច្រើនរូបក៏សឹងមាន សុទ្ធតែប្រកាសដោយសេចក្ដីផ្សេងៗគ្នា តែឯសេចក្ដីបំណងដូចគ្នាតែមួយ ១ ។ ក្រោយពីនោះមក ក៏ឃើញអាការដូចជាមានកម្លាំងពលំគ្រាន់បើ គួរនឹងឲ្យមានសង្ឃឹមទុកចិត្ត ថាលោកមុខជានឹងបានជាសះស្បើយពុំខាន ។

លុះដល់មកថ្ងៃ២ កើតខែស្រាពណ៍ អាពាធនោះ ក៏ប្រែកើតធ្ងន់ជាងដើមបន្តិចឡើងវិញ ចេះតែកើតធ្ងន់ឡើងជាដរាប លុះដល់មកថ្ងៃអង្គារ ៤ កើតខែស្រាពណ៍ លោកក៏ទទួលអនិច្ចធម្មទៅ ។

លុះលោកទទួលអនិច្ចធម្មទៅហើយ អស់សិស្សានុសិស្សទាំងឡាយ ក៏តម្កល់សពលោកក្នុងកុដិធំ ជាទីនៅរបស់លោក ហើយបានធ្វើទក្ខិណានុប្បទានដោយកិច្ចមានប្រគេនចង្ហាន់ដល់ព្រះភិក្ខុសង្ឃ សាមណេរព្រមទាំង

និមន្តលោកជាធម្មកថិកសម្ដែងធម៌ទេសនាជាដើម រាល់ថ្ងៃរៀងមក ។ បានប្រឹក្សាយល់ព្រមគ្នាថា នឹងធ្វើឈាបនកិច្ចបូជាសពលោកនៅថ្ងៃអាទិត្យ ៨ កើតខែកត្តិកឆ្នាំថោះនព្វស័កនេះ ។

ខ្ញុំបានតែងគាថាជាភាសាបាលី ហៅថា "បតិទានគាថា" ព្រមទាំងសេចក្ដីប្រែជាសម្រាយ សម្រាប់សូត្រឧទ្ទិសផលផ្សាយជូនចំពោះទៅដល់លោក ក្នុងវេលាដែលបានធ្វើទក្ខិណានុប្បទានរាល់ថ្ងៃ ក្នុងឱកាសដែលសពលោកនៅតម្កល់នេះ ។ លុះតែងគាថានោះរួចស្រេចហើយ ខ្ញុំបានបង្ហាញព្រមទាំងពិគ្រោះប្រឹក្សាជាមួយនឹងព្រះថេរានុថេរទាំងឡាយ ដែលនិមន្តមកជួបជុំក្នុងទីតម្កល់សពនោះ អស់លោកទាំងអស់ ក៏យល់ព្រមថា ត្រូវទុកសម្រាប់ឱ្យសូត្រឧទ្ទិសទក្ខិណានុប្បទានរាល់ថ្ងៃរៀងទៅ ។

## នេះគាថាព្រមទាំងសម្រាយដែលខ្ញុំតែង

## បតិទានគាថា

មហាវិមលថេរស្ស កាលកតស្សិទំ ជលំ
ព្រហ្មបណ្ឌិតនាមស្ស មហាថេរស្សវិញ្ញុនោ
សទ្ធាចិត្តេន អម្ហេហិ ឧទ្ទិសិតំ សមិជ្ឈតុ
យត្ថជាតោបិ សោ ថេរោ តត្រិមំ សម្បដិច្ឆតុ
ឥមិនា បតិទានេន ឧទ្ទិសិតេន សត្ថុតោ

កិំយេ្យាកិំយេ្យាមយំបុញ្ញំ លកាមសុខនាយកំ
ឥមំនេភនុមោទន្តុ សព្វសម្បត្តិសាធកំ
សចេបិសោធជាជាតិ តស្សនេភិៈវេទយុំ
តវេ្ថភសិកាចេវ សទ្ធីវិហារិកាធយោ
អជ្ជេវកិក្ខុសំយស្ស អាជំនេន្តិសតារភ
សព្វំបុញ្ញបតីតុយ្យុំ ឧទ្ទិស្សុស្សទ្ធចិត្តកា
អនុមោទតុតំសព្វំ កវិបសន្នចេតសា
តយាតិណ្ណម្បិយំបុព្វេ បុញ្ញំតំសរតុមាវិសរ
យជ្ជិត្តស្សុខេនេវ សមិជ្ឈតុកិរិសធាតិ
យជាឋុទ្ទិសិតាភថា បុញ្ញភាគេ្យាវបោរតុសោ
អម្ហចអភិធាលេតុ រក្ខតុពុទ្ធសាសនំ

ប្រែ : ផលនៃបុណ្យ ដែលអស់យើងទាំងឡាយ ឧទ្ទិសផ្សាយចំពោះទៅដោយចិត្ត ដ៏ប្រកបដោយសទ្ធានេះ សូមឲ្យបានសម្រេចដល់ព្រះតេជព្រះគុណព្រះមហាវិមលធម្មនាមក្នុងកិត្តិការ ជាព្រហ្មបណ្ឌិត នាមដើម ថោង ជាមហាថេរ ជាអ្នកប្រាជ្ញ ដែលទទួលអនិច្ចធម្មទៅកាន់បរលោកហើយនោះ បើព្រះតេជព្រះគុណ ទៅចាប់កំណើតកើតក្នុងគតិណា សូមព្រះតេជព្រះគុណទទួលនូវផលបុណ្យដែលយើងឧទ្ទិស ផ្សាយចំពោះទៅនេះ ក្នុងទីនោះៗ ដោយបត្តិទាន គឺកិរិយាជូននូវចំណែក.

បុណ្យដែលយើងឧទ្ទិសផ្សាយទៅដោយគោរពនេះ យើងទាំងឡាយឈ្មោះថាបានជូននូវបុណ្យដែលអាចឲ្យនូវសេចក្ដីសុខ ដោយច្រើនៗ ក្រៃលែង ៗ សូមទេវតាទាំងឡាយទទួលអនុមោទនានូវបុណ្យ ដែលអាចឲ្យសម្រេចនូវសម្បត្តិទាំងពួងនេះ ៗ បើព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម លោកមិនជ្រាបនូវសេចក្ដីឧទ្ទិសនេះទេ កំសូមឲ្យទេវតាទាំងឡាយនាំនូវដំណឹងនេះ ទៅពិតដល់លោកឲ្យបានជ្រាបផងថា ជនទាំងឡាយមានភិក្ខុសាមណេរ ដែលជាអន្តេវាសិក និងសទ្ធិវិហារិករបស់លោកជាដើម ជាអ្នកប្រកបដោយសេចក្ដីគោរព ជាអ្នកប្រកបដោយចិត្តសទ្ធា បានប្រគេនទានដល់ព្រះភិក្ខុសង្ឃក្នុងថ្ងៃនេះ ហើយគេឧទ្ទិសផ្សាយនូវផលបុណ្យទាំងអស់ចំពោះដល់មកលោក សូមលោកទទួលអនុមោទនានូវផលបុណ្យទាំងអស់នោះ ដោយចិត្តជ្រះថ្លាចុះ ៗ ម្យ៉ាងទៀតបពិត្រលោកអ្នកនិទ្ទិក បុណ្យឯណាដែលលោកបានសាងសន្សំមកហើយ ក្នុងកាលពីមុន សូមលោកកុំភ្លេចឡើយ សូមលោករំឭកដល់បុណ្យនោះ ហើយសូមឲ្យលោកបានសម្រេច សមប្រកបដោយសេចក្ដីសុខ តាមគួរដល់សេចក្ដីប្រាថ្នា របស់លោក ឲ្យបានសព្វៗ កាលកុំបីឲ្យឃ្លាតឡើយ ៗ

កំពាដែលយើងទាំងឡាយឧទ្ទិសផ្សាយនៅនេះ យ៉ាងណាមិញ សូមព្រះតេជព្រះគុណព្រះមហាវិមលធម្មអង្គនោះ លោកបាននូវចំណែកបុណ្យ ឲ្យដូចជាពាក្យដែលយើងឧទ្ទិសនេះយ៉ាងនេះ កុំបីឲ្យឃ្លាត

ឡើយ ហើយសូមឲ្យព្រះតេជព្រះគុណលោកអភិបាលរក្សាព្រះពុទ្ធសាស-នាផង សូមឲ្យរក្សាអស់យើងទាំងអស់គ្នាផង ឲ្យបានប្រកបដោយសេចក្តីបម្រើន និងសេចក្តីសុខសម្រាន្តរៀងទៅហោង ។

ម្យ៉ាងទៀត កាលដែលលោកនៅមិនទាន់មានអាពាធឈឺចាប់នូវឡើយលោកតែងមានព្រះពុទ្ធដីកាចំពោះនឹងខ្ញុំរឿយ ៗ ថា លោកសំគាល់ខ្ញុំមានសេចក្តីពេញចិត្តស្រឡាញ់អបរិហានិយធម៌ ៧ យ៉ាង ជាពុទ្ធភាសិតដែលមានក្នុងគម្ពីរអង្គុត្តរនិកាយនោះអំម៉្លេះ ប្រសិនបើយើងអ្នកបួសទាំងអស់គ្នាសព្វថ្ងៃនេះយកចិត្តទុកដាក់ប្រព្រឹត្តឲ្យត្រូវតាម អបរិហានិយធម៌ទាំង ៧ យ៉ាងនេះ នោះព្រះពុទ្ធសាសនានឹងចម្រើនរុងរឿងណាស់ ប៉ុន្តែសព្វថ្ងៃនេះយើងទៅជាមិនអើពើ មិនយកចិត្តទុកដាក់នឹងអបរិហានិយធម៌ទាំង ៧ យ៉ាងនោះសោះព្រោះហេតុហ្នឹងបានជាយើងអ្នកបួសទាំងអស់គ្នាសព្វថ្ងៃនេះតែកាំកូសនឹងគ្នា ខ្លះពេញចិត្តស្រឡាញ់ការរៀនសូត្រ ខ្លះមិនសូវពេញចិត្ត ក៏មិនសូវសង្វាតរៀនសូត្រ ហើយមានខ្លះថែមទាំងស្អប់អ្នករៀនសូត្រនោះទៅទៀត បើស្អប់អ្នករៀនធម៌របស់ព្រះហើយ ក៏ឈ្មោះថាស្អប់ដល់ព្រះដែរ បើថាស្អប់ក៏ស្អប់តែមនុស្សទៅចុះអេះ នេះមានថែមទៅស្អប់ទាំងធម៌ផង ហើយមានថែមទាំងពោលពាក្យតិះដៀល ដល់ធម៌របស់ព្រះទៅទៀត តិះដៀលធម៌ព្រះរួចខំប្រឹងសំពះព្រះថាយកបុណ្យ ខ្ញុំសព្វថ្ងៃដែលបានរៀនសូត្រចេះដឹងប៉ុណ្ណឹង ការប្រព្រឹត្តរបស់ខ្ញុំដូរថយទេ

ខុសខ្លះត្រូវខ្លះ ប៉ុន្តែឲ្យលោកសង្កេតមើលចិត្តខ្ញុំចុះ ខ្ញុំមិនដែលតាំងចិត្ត ស្អប់ ឬ ព្យាបាទប្រទូស្តឥតញាណ្ហាទីសដល់អ្នករៀនធម៌វិន័យ មិនដែល ហ៊ានពោលពាក្យតិះដៀលធម៌ព្រះដល់ម្តងទេ ខ្ញុំស្រឡាញ់ព្រះត្រៃបិដក ណាស់ ពីព្រោះហេតុហ្នឹងបានជាខ្ញុំខំប្រឹងកសាងគម្ពីរព្រះត្រៃបិដកមិន ដែលខានឆ្នាំណាមួយទេ ដូចលោកឃើញខ្ញុំស្រាប់ ៗលៗ

កាលដែលលោកមានព្រះពុទ្ធដីកាចំពោះទីងខ្ញុំដូច្នេះ ខ្ញុំក៏រំពឹងពិត ព្រះពុទ្ធដីកាទៅវិញដោយការពក់ពាក់ជាច្រើន ៗ ដែលលោកមានព្រះ ពុទ្ធដីកាចំពោះទីងខ្ញុំយ៉ាងនេះ មិនតែម្តងពីរដងឡើយ ច្រើនដងណាស់ ៗ ព្រោះហេតុនោះ ខ្ញុំសូមស្រង់យកអបរិហានិយធម៌ទាំង ៧ យ៉ាងនោះ ពី ក្នុងព្រះសុត្តន្តបិដក ឈ្មោះគម្ពីរអង្គុត្តរនិកាយសត្តកនិបាតបាលី ក្នុងវគ្គ ជាគំរប់ ៣ នៃបឋមបណ្ណាសក ដែលជាព្រះពុទ្ធភាសិត មកប្រែជាសេចក្តី សម្រាយសុទ្ធប្រតិស្ឋានទុកក្នុងទីនេះ ដើម្បីនឹងបំពេញសេចក្តីបំណងរបស់ ព្រះតេជព្រះគុណព្រះមហាវិមលធម្ម ជាធម្មាចារ្យរបស់ខ្ញុំផង ដើម្បីប្រ យោជន៍ក្តីប្រតិបត្តិដល់អស់លោកសាធុជនជាអ្នកបួសទាំងឡាយផង ៗ

## អបរិហានិយធម៌ ៧ យ៉ាង

សេចក្តីថា ក្នុងសម័យមួយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់គង់ នៅនាភ្នំគិជ្ឈកូដជិតក្រុងរាជគ្រឹះ ព្រះអង្គត្រាស់ហៅភិក្ខុទាំងឡាយមកជួបជុំ ហើយទ្រង់ត្រាស់សម្តែងនូវ អបរិហានិយធម៌ ថា ម្នាលភិក្ខុទាំងឡាយ

តថាគតនឹងសម្ដែងនូវ អបរិហានិយធម៌ ៧ ដែលនាំមិនឲ្យសាបសូន្យចាក ប្រយោជន៍ ៧ យ៉ាង ឲ្យអ្នកទាំងឡាយស្ដាប់ អ្នកទាំងឡាយចូរប្រុងស្ដាប់ ចូរយកចិត្តទុកដាក់ស្ដាប់ដោយប្រពៃ តថាគតនឹងសម្ដែងឲ្យស្ដាប់ ៗ ភិក្ខុទាំងឡាយក៏ទទួលព្រះពុទ្ធភាសិតថា "ឯវំភន្តេ" ដូច្នេះហើយព្រះអង្គក៏ត្រាស់សម្ដែងថា ម្នាលភិក្ខុទាំងឡាយ អបរិហានិយធម៌ ៧ យ៉ាងនោះ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ អបរិហានិយធម៌ ៧ យ៉ាងនោះដូច្នេះគឺ:

១- កាលណាបើភិក្ខុទាំងឡាយ ឧស្សាហ៍ប្រជុំពិគ្រោះគ្នាអំពីធម៌វិន័យ អំពីការខុសត្រូវរឿយៗនោះ សេចក្ដីចម្រើននឹងកើតមានដល់ភិក្ខុទាំងឡាយ មិនមែនជាសេចក្ដីវិនាសសាបសូន្យឡើយ ៗ

២. កាលណាបើភិក្ខុទាំងឡាយ មានសេចក្ដីសាមគ្គីសេស្មោះសរ ព្រមព្រៀងគ្នា គឺព្រមព្រៀងគ្នាចូលកាន់ទីប្រជុំ ព្រមព្រៀងគ្នាក្រោកចាកទីប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចការដែលសង្ឃត្រូវធ្វើនោះ សេចក្ដីចម្រើននឹងកើតមានដល់ភិក្ខុទាំងឡាយ មិនមែនជាសេចក្ដីវិនាសសាបសូន្យឡើយ ៗ

៣- កាលណាបើភិក្ខុទាំងឡាយ មិនបញ្ញត្តបន្ថែមសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តឡើយ គឺថាមិនបញ្ញត្តបន្ថែមសិក្ខាបទ ឲ្យហួសលើសពីសិក្ខាបទ ដែលតថាគតបញ្ញត្តហើយនោះឡើយ មិនបន្ថយ មិនដកសិក្ខាបទ ដែលតថាគតបានបញ្ញត្ត ហាមប្រាមជាស្រេចហើយ នាំគ្នាប្រព្រឹត្តកាន់តាមតែសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយទាំង

ប៉ុន្មាន នោះសេចក្ដីចម្រើន នឹងកើតមានដល់ភិក្ខុទាំងឡាយ មិនមែនជាសេចក្ដីវិនាសសាបសូន្យឡើយ ។

៤-កាលណា បើភិក្ខុទាំងឡាយឯណា ដែលជាថេរៈមានវស្សាចាស់ជាអ្នកចេះដឹងជ្រៅជ្រះ ស្គាល់ខុសស្គាល់ត្រូវ ប្រាកដមានវត្តប្រតិបត្តិប្រព្រឹត្តល្អតាមធម៌វិន័យ ទុកដូចជាបីតារបស់សង្ឃ ជាអ្នកណែនាំប្រាប់ពន្យល់ការខុសត្រូវដល់សង្ឃ ហើយភិក្ខុទាំងឡាយទាំងអស់គ្នា នាំគ្នាគោរពប្រតិបត្តិបូជាកប់អាន កោតក្រែងស្ដាប់ធម៌វិន័យ ជាឱវាទរបស់ភិក្ខុចាស់ទាំងនោះ នោះសេចក្ដីចម្រើន នឹងកើតមានដល់ភិក្ខុទាំងឡាយមិនមែនជាសេចក្ដីវិនាសសាបសូន្យឡើយ ។

៥- កាលណាបើ ភិក្ខុទាំងឡាយ នាកាលតណ្ហាដែលជាពូជជាតិនាំឲ្យកើតក្នុងភពថ្មីៗ ទៅទៀត កើតឡើងក្នុងចិត្តហើយ មិនលុះលង់នៅក្នុងអំណាចនៃតណ្ហានោះ នោះសេចក្ដីចម្រើននឹងកើតមានដល់ភិក្ខុ-ទាំងឡាយ មិនមែនជាសេចក្ដីវិនាសសាបសូន្យឡើយ ។

៦- កាលណាបើភិក្ខុទាំងឡាយពេញចិត្ត នៅក្នុងទីសេនាសនៈទាំង-ឡាយដែលមាននៅក្នុងព្រៃ នោះសេចក្ដីចម្រើននឹងកើតមានដល់ភិក្ខុទាំង-ឡាយ មិនមែនជាសេចក្ដីវិនាសសាបសូន្យឡើយ ។

៧- កាលណាបើភិក្ខុទាំងឡាយតាំងចិត្តគិតថា ភិក្ខុទាំងឡាយដែលជាអ្នកមានសេចក្ដីប្រព្រឹត្តស្មោះស្មើ ត្រូវត្រង់តាមធម៌វិន័យ ជាអ្នកមាន

សេចក្តីពេញចិត្តនឹងសីលសិក្ខា ដែលលោកមិនទាន់បានមកក្នុងទីនេះ ធ្វើម្តេចហ្ន៎ ឲ្យលោកបានមកក្នុងទីនេះទៅអេះ លោកដែលបានមកក្នុងទីនេះហើយ ក៏សូមឲ្យលោកគង់នៅជាសុខសប្បាយ កុំបីមានជម្ងឺតម្កាត់ ឬសេចក្តីអផ្សុកឡើយ ដូច្នេះ នោះសេចក្តីចម្រើននឹងកើតមានដល់ភិក្ខុទាំងឡាយ មិនមែនជាសេចក្តីវិនាសសាបសូន្យឡើយ ។

ម្នាលភិក្ខុទាំងឡាយ អបរិហានិយធម៌ទាំង ៧ យ៉ាងនេះ នៅមានដល់ភិក្ខុទាំងឡាយ ។ ក៏មានសេចក្តីពេញចិត្ត នឹងអបរិហានិយធម៌ទាំង ៧ យ៉ាងនេះផង ត្រឹមណា សេចក្តីចម្រើនក៏នឹងកើតមានដល់ភិក្ខុទាំងឡាយ មិនមែនជាសេចក្តីវិនាសសាបសូន្យឡើយ ត្រឹមណោះ ។

— ចប់ —

# គុណូបការានុស្សរណាសព្វកិរិយា

របស់ព្រះញាណបវរវិជ្ជា ខំនេម វត្តលង្កា

ក្រុងភ្នំពេញ

ប្រកាសរំលឹកឧបការគុណព្រះតេជព្រះគុណមហាវិមលធម្មនាម ថោង

ចាងហ្វាងសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ

# គុណូបការានុស្សរណសច្ចកិរិយា

## របស់ព្រះញាណបវរវិជ្ជា នំ អែម វត្តលង្កា ក្រុងភ្នំពេញ

ខ្ញុំព្រះករុណាសូមធ្វើនូវសច្ចកិរិយា ដោយមានសតិនឹករលឹកដល់គុណូបការរបស់ព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម ថាង ហ្វាង សាលាបាលីជាន់ខ្ពស់ គឺចាប់ដើមតាំងតែអំពីខ្ញុំព្រះករុណានៅក្មេង ដែលបានចូលមកអាស្រ័យជ្រកកោនក្រោមម្លប់បុណ្យព្រះតេជព្រះគុណ ៗ ក៏មានព្រះហឫទ័យមេត្តាទុកដាក់ជួយទំនុកបម្រុងបង្ហាត់បង្ហាញធម៌វិន័យ ហើយបាននិមន្តសម្ដេចព្រះមហាសង្ឃរាជបំបួសខ្ញុំព្រះករុណាជាសាមណេរ រួចហើយព្រះតេជព្រះគុណបានបង្រៀនព្រះវិយត្តិធម៌គ្មានដាច់ និង ចាត់ឲ្យខ្ញុំព្រះករុណាឲ្យទៅសូមរៀននឹងលោកគ្រូអាចារ្យដទៃជាច្រើន មានលោកគ្រូឧកញ៉ាសុធម្មមេធាចារ្យព្រះនាម រ៉ត ជាដើម លុះបាន ៤ ព្រះវស្សា ខ្ញុំព្រះករុណារៀនបានចេះដឹងច្រើនហើយ ព្រះតេជព្រះគុណ ក៏បានចាត់ឲ្យបង្រៀនភិក្ខុសាមណេរតៗទៅទៀត ដោយព្រះកដហឫទ័យសង្គ្រោះចង់ឲ្យចេះឆាប់ ដល់ខ្ញុំព្រះករុណាអាយុបាន ២១ ឆ្នាំ ព្រះតេជព្រះគុណរៀបចំចាត់ចែងឲ្យឧបសម្បទ លោកអ្នកឧកញ៉ា មហាមន្ត្រី ឌុច បានជួយទំនុកបម្រុងគ្រឿងបរិក្ខារ មានត្រៃចីវរជាដើម ហើយព្រះតេជព្រះគុណបានឲ្យនិមន្តសម្ដេចព្រះមហាសង្ឃរាជព្រះនាម ទៀង ជាព្រះឧបជ្ឈាយ៍ ព្រះមង្គលវិទ្យាចារ្យព្រះនាម ក្រុយ ព្រះពុទ្ធវង្សព្រះនាម ឆក្ដ ជាឧប-

សម្បទាចារ្យ ព្រមទាំងដំនុំសង្ឃ ២១ អង្គ បានឲ្យឧបសម្បទជាភិក្ខុការ ក្នុងព័ទ្ធសីមាវត្តឧណ្ណាលោម ក្រុងភ្នំពេញ ហើយខ្ញុំព្រះករុណានៅសិក្សា រៀនសូត្រ ក្នុងសំណាក់ព្រះតេជព្រះគុណបាន ១ ឆ្នាំទៀត លុះដល់ព្រះពុទ្ធសករាជ ២៤៤៥ ឆ្នាំឆ្លូវត្រីស័ក គ្រិស្តសករាជ ១៩០១ មានអាចារ្យ និងឧបាសកដើងវត្តស៊ីធរ ខណ្ឌស៊ីធរ ស្វាយរមៀត ជាវត្តបូរាណ តែដាច់ជោចហោចលោកសង្ឃណា ប់ បានចូលមកកាន់សំណាក់ព្រះតេជព្រះគុណ សូមឲ្យជ្រើសរើសរកលោកដែលចេះព្រះត្រៃបិដក ទៅធ្វើជាចៅអធិការវត្តនោះ ព្រះតេជព្រះគុណក៏បានទទួលដោយមានព្រះហឫទ័យបង្ផ្សាយព្រះពុទ្ធសាសនាឲ្យបានថ្កុំថ្កើងរុងរឿងត ៗ ទៅ ក៏បានយកសេចក្តីក្រាបទូល ដល់សម្តេចព្រះមហាសង្ឃរាជ ទ្រង់ក៏បានយល់ព្រមផង ហើយបានចាត់ខ្ញុំព្រះករុណាឲ្យទៅគ្រប់គ្រងថែរក្សាវត្តនោះ មិនតែប៉ុណ្ណោះ កាលដែលរៀបទៅ ព្រះតេជព្រះគុណក៏បានឲ្យឱវាទ ប្រាប់អំពីធម៌ដែលនឹងធ្វើជាមេបាត្រួតត្រាលើគេ ដោយសេចក្តីសព្វគ្រប់នោះ ខ្ញុំព្រះករុណាក៏បានប្រព្រឹត្តតាមឱវាទរបស់ព្រះតេជព្រះគុណទាំងអស់ វត្តនោះក៏បានប្រែទៅជាវត្តធំថ្កុំថ្កើងរុងរឿង មានទាំងភិក្ខុនិងសាមណេរនៅកុះកររៀនសូត្រធម៌វិន័យជាច្រើន ទាំងឧបាសកឧបាសិកាទៀត ក៏បរិបូណ៌កុះកររុងរឿងតរៀងមក ដល់ពុទ្ធសករាជ ២៤៥៣ ឆ្នាំចទោស័ក គ្រិស្តសករាជ ១៩១០ ព្រះតេជព្រះគុណបានតាំងខ្ញុំព្រះករុណាជាព្រះគ្រូវិមល-បញ្ញា ហើយយកសេចក្តីក្រាបបង្គំទូលសម្តេចព្រះមហាសង្ឃរាជ ៗ ក៏បាន

ចេញប្រកាសនិយប័ត្រ លេខ ៤០៦ ដល់ខ្ញុំព្រះករុណាឲ្យមានអំណាចជា ភ្នាក់ងាររៀនហ្លួងរំលឹកដាស់តឿនភិក្ខុ និង សាមណេរ គ្រប់វត្តក្នុងខេត្ត ក្រៅឲ្យសិក្សាធម៌វិន័យឲ្យបានត្រឹមត្រូវតាមពុទ្ធានុញ្ញាត ខ្ញុំព្រះករុណាក៏ បានទទួលប្រតិបត្តិតាម ហាត់ធម៌វិន័យភិក្ខុនិងសាមណេរ ក្នុងខណ្ឌស៊ុធរ ស្វាយរមៀត ខេត្តកំពង់ចាម ភិក្ខុនិងសាមណេរ ក៏បានស្វូត្រធម៌ប្រតិបត្តិ តាមវិន័យត្រឹមត្រូវគ្រាន់បើឡើង ដោយតេជៈព្រះតេជព្រះគុណ ដែលមាន ព្រះហឫទ័យសង្គ្រោះព្រះពុទ្ធសាសនា ដល់ពុទ្ធសករាជ ២៤៥៦ ឆ្នាំឆ្លូវ បញ្ចស័កគ្រិស្តសករាជ ១៩១៣ ព្រះតេជព្រះគុណមានព្រះហឫទ័យមេត្តា សង្គ្រោះខ្ញុំព្រះករុណា ព្រោះថាមិនទាន់បានកេរ្តិ៍ឈ្មោះថ្កុំថ្កើងសមរម្យនឹង ចំណោះនៅឡើយ ហើយបានចាត់ខ្ញុំព្រះករុណាឲ្យត្រឡប់មកនៅ គ្រប់ គ្រងរក្សាវត្តលង្កា ក្រុងភ្នំពេញនេះវិញ កាលនោះមានភិក្ខុនិងសាម-ណេរប្រហែល ១៨ រូប នោះខ្ញុំព្រះករុណាក៏យកចិត្តទុកដាក់តាមឱវាទ ព្រះតេជព្រះគុណ ខំបង្ហាត់បង្រៀនរៀបចំវត្តនោះរៀងរាបដរាបមកដល់ ឥឡូវនេះ ចម្រើនបានភិក្ខុនិងសាមណេរ ចំនួន ៤៩១ រូប សុទ្ធតែជា អ្នករៀនព្រះបរិយត្តិទាំងអស់ និងទីវត្តអារាមទៀត ក៏បានថ្កុំថ្កើងរុងរឿង ឡើង គឺកើតដោយសេចក្តីទំនុកបម្រុងរបស់ព្រះតេជព្រះគុណដោយពិត ។

ម្យ៉ាងទៀត ខ្ញុំព្រះករុណាដែលបានជ្រកកោនក្រោមម្លប់បុណ្យព្រះ តេជព្រះគុណ មិនដែលឃើញព្រះតេជព្រះគុណ មានអាពាធឈឺជាទម្ងន់ ដល់ម្តងទេ ចំនួន ៣០ ប្លាយឆ្នាំមកហើយ ទើបតែឥឡូវនេះព្រះតេជព្រះ

គុណ មានពាក្យពោះធបៀតបៀនព្រះអង្គជាទម្ងន់ ហេតុនេះខ្ញុំព្រះករុណាព្រមទាំងសិស្សានុសិស្ស មានសេចក្តីបារម្ភណ៍ នឹងព្រះតេជព្រះគុណពេកណាស់ ឥឡូវនេះខ្ញុំព្រះករុណាព្រមទាំងសិស្សានុសិស្ស សូមឧទិសផ្សាយផលានិសង្ស គឺផលដែលខ្ញុំព្រះករុណាបានចាត់ចែងធ្វើទានកសាងវត្តអារាមជាដើម ជាផលានិសង្សទី ១ សេចក្តីប្រព្រឹត្តបង្ហាត់បង្រៀនភិក្ខុនិងសាមណេរ ឲ្យរក្សាសីលសមគួរតាមពុទ្ធានុញ្ញាតនិងពុទ្ធបញ្ញត្តិ និងការដែលរៀនសូត្រផ្សាយវិន័យ និងចម្រើនព្រះបរិត្ត ជាផលានិសង្សទី ២ ភាវនា ដែលខ្ញុំព្រះករុណាបានរៀន និងបម្រើនព្រះកម្មដ្ឋានចំនួន ១៧ ឆ្នាំមកហើយ ព្រមទាំងបានបង្រៀនសិស្សានុសិស្សតទៅទៀតជាច្រើន ជាផលានិសង្សទី ៣ ។

ផលានិសង្សទាំង ៣ យ៉ាងនេះ សូមសម្រេចដល់ព្រះតេជព្រះគុណ បីដូចជាថ្នាំទិព្វឧសថវិសេស រំលត់បង់នូវរោគាព្យាធិជាទម្ងន់ ដែលមានក្នុងព្រះអង្គ ឲ្យបានជាជ្រះស្រឡះសះស្បើយតាំងអំពីថ្ងៃនេះទៅ ។

ម្យ៉ាងទៀត ខ្ញុំព្រះករុណាព្រមទាំងសិស្សានុសិស្សទាំងអស់ដែលបានរៀនសូត្រ រក្សាសីល ចម្រើនមេត្តាភាវនា តែងផ្សាយផលានិសង្សជូនទៅទេវតាទាំង ១ ហ្មឺនលោកធាតុ ជារឿយ ៗ ហើយមិនដែលមានកិច្ចអ្វីជាទម្ងន់ ទីនឹករកដល់ទេវតាបានម្តងក៏ទេ ទើបតែឥឡូវនេះ មានកិច្ចជាធំបំផុត សូមរំលឹកនឹកដល់ទេវតាទាំងឡាយដែលមានទិព្វចក្ខុទិព្វសោត សូមឲ្យទេវតាទាំងអស់នោះជួយឈឺឆ្អាល យកព្រះហឫទ័យ ទុកដាក់ចុះបាកទិព្វវិមានមកទទួលយកផលានិសង្សទាំង ៣ យ៉ាងនេះ សូមទេវតាជួយ

ប្រសិទ្ធិជាថ្នាំទិព្វឧសថវិសេស ឲ្យបានសម្រេចនូវពរទាំង ៤ យ៉ាង គឺ ឲ្យមានព្រះជន្មចម្រើនច្រើនតទៅទៀត ១ ឲ្យមានពណ៌សម្បុរបាំជាប្រក្រតី ១ ឲ្យបានសេចក្ដីសុខកាយសុខចិត្ត ១ ឲ្យមានកម្លាំងកាយ កម្លាំងស្មារតី កម្លាំងប្រាជ្ញា ចម្រើនជាប្រក្រតី ១ ឲ្យមានអានុភាពជាអធិបតីចម្រើនយសសក្តិ ១ ពរទាំង ៤ ប្រការនេះ សូមទេវតាជួយប្រសិទ្ធិឲ្យបានសម្រេចផុតឆាប់ដល់ព្រះតេជព្រះគុណកុំឲ្យឃ្លៀងឃ្លាតឡើយ ដោយតេជៈសច្ចកិរិយានៃខ្ញុំព្រះករុណា ព្រមទាំងសិស្សានុសិស្សទាំងឡាយនេះឯង ។

សច្ចកិរិយានេះបានសូត្រក្នុងប្រជុំបរិស័ទមានភិក្ខុសង្ឃជាដើមផ្សាយផលដល់ព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម ដែលមានអាពាធជាទម្ងន់គន់ព្រះជន្មទៅឡើយ ។ ចប់តែប៉ុណ្ណោះ ។

ពីនេះខ្ញុំនឹងអធិប្បាយអំពីមធុរកថា គឺពាក្យពោលដ៏ពិរោះរបស់ព្រះតេជព្រះគុណ ព្រះមហាវិមលធម្មតទៅទៀត កាលលោកចាប់ជម្ងឺឈឺតាំងពីថ្ងៃអង្គារ ៤ កើត ខែអាសាឍ ឆ្នាំថោះនព្វស័ក ខ្ញុំបានទៅថែទាំរក្សាជម្ងឺលោករាល់ ៗ យប់ពុំដែលដាច់ ហើយបានសង្កេតកំណត់គុណសម្បត្តិរបស់លោក ឃើញជាអស្ចារ្យពេកណាស់ ត្បិតខ្ញុំជាអន្តេវាសិករបស់លោកពិត តែគំនិតខ្ញុំនៅគិតសង្ស័យថាព្រះតេជព្រះគុណ ព្រះមហាវិមលធម្មនេះ ដែលខំខ្វល់ខ្វាយចាត់ការទាំងឡាយមានការរៀនសូត្រជាដើម ប្រហែលជាមានព្រះហឫទ័យធ្ងន់ទៅក្នុងបច្ចុប្បន្ន មានប្រាជ្ញាបុណ្យសក្តិជាដើម ដល់ខ្ញុំបានទៅថែរក្សាជម្ងឺលោកតាំងតែពីថ្ងៃទី ១ដកប

ដល់ថ្ងៃទី ១៦ ដែលលោកទទួលអនិច្ចធម្មទៅ ទើបខ្ញុំបានដឹងច្បាស់ថា លោកគ្មានព្រះហឫទ័យធ្ងន់ទៅក្នុងបច្ចុប្បន្នទេ គឺលោកមានព្រះហឫទ័យធ្ងន់ ទៅក្នុងព្រះពុទ្ធសាសនាពិតមែន ព្រោះខ្ញុំបានសង្កេតគតិនិមិត្តរបស់លោក មិនខុសអំពីគតិនិមិត្តរបស់អ្នកប្រាជ្ញអំពីបុរាណ ដែលខ្ញុំទៅរក្សាជម្ងឺរាល់ថ្ងៃពុំដែលព្រះពុទ្ធដីកាលោកពោលរឿងអ្វី ដែលជាប្រយោជន៍ក្នុងបច្ចុប្បន្នដល់ម្តងបានព្រះពុទ្ធដីកាលោកពោលតែអំពីរឿងពុទ្ធសាសនារឿយៗ ប្រកបដោយមធុរកថាដ៏ពិរោះច្រើនដង ។

១- ខ្ញុំបានចូលទៅជិត បម្រើជម្ងឺលោក ៗ មានពុទ្ធដីកាថាខ្ញុំតាំងតែបានបួសមកកាលណា នឹងមានចិត្តគិតចង់សឹកជាគ្រហស្ថដល់ម្តងក៏ទេ កាលនៅក្មេងនៅឡើយ សម្តេចព្រះអគ្គ យៃ ព្រះអគ្គ ឈយ ជាព្រះញាតិលោកបាននិយាយល្បួងលួងឲ្យសឹកថាចង់ធ្វើមន្ត្រីអ្វី ជាបាឡាត់ ឬចៅហ្វាយស្រុក នឹងទូលព្រះករុណាសុវណ្ណកោដ្ឋ ឲ្យទ្រង់ប្រោសប្រទានយសសក្តិនោះ ឲ្យតាមគាប់ចិត្តនោះ ខ្ញុំក៏ពុំព្រមសឹក ឬនឹងមានដវនចិត្តណាមួយចង់សឹកក៏ទេ ខ្ញុំមានចិត្តស្រឡាញ់ ចង់តែទំនុកបម្រុងព្រះពុទ្ធសាសនាឲ្យបានរុងរឿងឡើង តែប៉ុណ្ណោះ ។

២- លោកមានពុទ្ធដីកាថា ខ្ញុំនឹងមានចិត្តតក់ស្លុតនឹងមច្ចុរាជឬមានចិត្តអាឡោះអាល័យអាយុជីវិតប៉ុន្មានទៅក៏ទេ ព្រោះខ្ញុំមានអាយុ ៦៥ ឆ្នាំក៏ល្មមសមគួរហើយ តែខ្ញុំនៅមានចិត្តចង់នៅ ឲ្យបានយូរបន្តិចទៀត ត្បិតលោកដែលជាកូនសិស្សទាំងឡាយមានចំណេះវិជ្ជា ក៏ពេញបរិបូណ៌

ជាច្រើនហើយ តែនៅពុំទាន់បានរឹងប៉ឹងនៅឡើយ នឹងទ្រទ្រង់ព្រះពុទ្ធសាសនាឲ្យបានមាំមួនទៅពុំទាន់បាន ។

១ ទៀតខ្ញុំបានព្ថាពជការនឹងជួយទំនុកបម្រុង ព្រះពុទ្ធសាសនាឲ្យបានថ្កុំថ្កើងរុងរឿងឡើង ខ្ញុំចង់ឲ្យមានអាយុជីវិតរស់នៅយូរបន្តិចតទៅទៀត ដើម្បីនឹងឃើញជាក់ច្បាស់នឹងភ្នែកខ្លួនដោយពិត ។

៣- ដល់លោកអាពាធកន្លងទៅបាន ៩ ថ្ងៃ បានហៅខ្ញុំចូលទៅជិតហើយមានពុទ្ធដីកាថា លោកជម្ងឺខ្ញុំធូរស្រួលបន្តិចហើយដល់យប់ក្រោយលោកមិនទិមន្តមកក៏បាន ត្បិតលោកមានកិច្ចធុរៈច្រើនចំពូកណាស់រវល់សិក្សាប្រៀនប្រដៅធម៌វិន័យដល់ភិក្ខុសាមណេរ ហើយលោកបានឲ្យនុកទដល់ខ្ញុំថា កុំឲ្យសម្គាល់ព្រះអង្គលោកដែលមានជម្ងឺ ថាជាធំជាងព្រះពុទ្ធសាសនា ត្រូវសម្គាល់ព្រះពុទ្ធសាសនានិងការរៀនសូត្រថាជាធំជាទម្ងន់ជាងព្រះអង្គលោកដែលមានជម្ងឺ ព្រោះព្រះពុទ្ធសាសនាដែលនឹងរុងរឿងឡើងបាន មកពីការរៀនសូត្រនូវធម៌វិន័យ និងសេចក្ដីប្រតិបត្តិតាម ខ្ញុំក៏បានទូលពុទ្ធដីកាតបទៅវិញ ថាខ្ញុំព្រះករុណាដែលបានមកបម្រើជម្ងឺព្រះតេជព្រះគុណនេះ ការដែលរៀនសូត្រធម៌វិន័យទាំងប៉ុន្មាន ខ្ញុំព្រះករុណាបានចាត់ឲ្យមានគ្រូបង្រៀនគ្រប់កន្លែងអស់ហើយ តាំងពីព្រះតេជព្រះគុណមានជម្ងឺមកៗដល់ឥឡូវនេះការដែលរៀនសូត្រទាំងប៉ុន្មាន ក៏បានបង្រៀនគ្រប់កន្លែងទាំងអស់ ពុំមានឈប់កន្លែងណាមួយទេ លោកក៏ពេញព្រះហឫទ័យណាស់ ឲ្យសព្ទសាធុការដល់ខ្ញុំថា សាធុប្រពៃហើយលោកដែល

បានខ្វល់ខ្វាយចាត់ចែង ការរៀនសូត្រធម៌វិន័យយ៉ាងនេះ ទោះបីបើពុំបានមកបម្រើជម្ងឺខ្ញុំ ក៏ដូចជាបានមកបម្រើជម្ងឺខ្ញុំហើយ ត្រូវលោកកុំឈប់បង្ហាត់បង្រៀនធម៌វិន័យដល់ភិក្ខុ និង សាមណេរឡើយ កុំខ្វល់ខ្វាយមកបម្រើជម្ងឺខ្ញុំខ្លាំងពេក ។

៤- ដល់លោកមានជម្ងឺកន្លងទៅបាន ១១ ថ្ងៃ ខ្ញុំនិងលោកគ្រូព្រះពុទ្ធវង្ស ម៉ី បានចូលទៅបម្រើជម្ងឺលោក ៗ ក៏មានពុទ្ធដីកាថា អស់លោកទាំងឡាយ ដែលជាកូនសិស្សគណទាំងអស់ដែលមានចិត្តកតញ្ញូកតវេទី ស្រុះស្រួលបបួលគ្នាគឹកកងមកបម្រើជម្ងឺខ្ញុំនេះ ខ្ញុំមានសេចក្ដីពេញចិត្តណាស់ តែប៉ុណ្ណេះខ្ញុំក៏សប្បាយអស់ពីចិត្តហើយ ទោះបីបើនឹងស្លាប់នឹងរស់ក៏ល្មមគួរសមហើយ ខ្ញុំបានឮពាក្យនេះ ខ្ញុំស្លុតចិត្តនឹកអាណិត ព្រះគុណ ព្រះមហាវិមលធម្មពេកណាស់ អត់ទ្រាំពុំបាន ហើយខ្ញុំបានសរសេរអធិប្បាយសេចក្ដីនេះ ដើម្បីជាដំណឹងអស់លោក នូវអស់អ្នកទាំងឡាយបានដឹងពល់គ្នា ។

៥- ដែលលោកមានជម្ងឺតាំងពីឈឺតិចៗ ដរាបដល់ឈឺជាទម្ងន់ ស្មារតីរបស់លោកពុំបានវង្វេងភ្លេចដូចអ្នកដទៃ រាល់ដែលលោកពោលដំបូន្មានដល់កូនសិស្សទាំងប៉ុន្មាន សុទ្ធតែវាចាពីរោះត្រូវត្រង់តាមធម៌វិន័យទាំងអស់ដូចអធិប្បាយមកខាងលើនេះស្រាប់ ។

៦- ខណៈដែលលោកទទួលអនិច្ចធម្មទៅនោះ ក៏ជាទីអស្ចារ្យ លោកសឹងស្ងៀមស្ងាត់ ដង្ហើមចេញចូល ក៏ស្រួលល្អណាស់ អស់លោកកូន

សិស្សទាំងអស់ ក៏គ្មានធ្វេសប្រហែសស្មារតីដល់តិចឡើយ បានទាំងហាមប្រាមគ្នាឲ្យសម្ងំសម្ងាត់មាត់ ហើយឲ្យប្រុងចាំសូត្រពុទ្ធគុណ អមដំណើរលោកក្នុងពេលមុនដែលលោក និងអស់អស្សាសបស្សាស នោះចំនួន ៤០ មីនុត លុះដល់វេលាយប់ជាងពាក់កណ្ដាលអាធ្រាត្រ ស្រាប់តែមានខ្យល់ថយអំពីចុងដៃចុងជើងបន្តិច ៗ ត្រជាក់ជើងដៃរហូតដល់ផុតខ្យល់ទៅ ពុំមានវិការអន្ទះអន្ទែងកម្រើកដៃជើងដូចអ្នកដទៃវិស័យ ហាក់ដូចព្រះយោគាវចរបម្រើនព្រះកម្មដ្ឋាន រលត់កាយសង្ខារ ចូលកាន់បត្តដ្ឋាន ក្នុងវេលាម៉ោងពីរ ១០ មីនុត ថ្ងៃអង្គារ ៤ កើតខែស្រាពណ៍ ឆ្នាំថោះនព្វស័ក សេចក្ដីដែលអធិប្បាយមកនេះ ក៏ចប់តែប៉ុណ្ណោះ ។

ព្រះញាណបវរវិជ្ជា

**ឌិនម**

# គុណកថា

របស់ព្រះមហាវិមលធម្ម នាម ថោង

ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

ព្រះពុទ្ធវង្ស ម៉ី រៀបរៀង

# គុណកថា

ពោលសរសើរគុណព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម នាមក្នុងកិច្ចការថា ព្រហ្មបណ្ឌិត នាមដើម ថោង ជាធម្មាចារ្យរបស់ខ្ញុំ លោកទទួលអនិច្ចធម្ម នៅថ្ងៃអង្គារ ៤ កើត ខែស្រាពណ៍ ឆ្នាំថោះនព្វស័ក ត្រូវនឹងថ្ងៃ ២ ខែ អាគូិតឆ្នាំ ១៩២៧ វេលាម៉ោង ២ ដប់នាទី ។

ព្រះពុទ្ធវង្ស អ៊ឹង ឆេត ម៉ឺ ពណ៌នាគុណឧបការៈ ដែលលោកមានគុណតាំងពីខ្ញុំចូលសូមរៀនព្រះបរិយត្តិធម៌ និងព្រះនវលោកុត្តរធម៌ ក្នុងគម្ពីរព្រះធម្មបទនិងព្រះមង្គលទីបនី ហើយលោកបានបញ្ជូនខ្ញុំឲ្យទៅសិក្សាគម្ពីរសារត្ថសង្គហ និងលោកគ្រូឧកញ៉ាសុធម្មមេធាចារ្យ នាម រ៉ត និងអាចារ្យទាំងឡាយច្រើន ដរាបដល់ព្រះតេជព្រះគុណ ព្រះពោ.ធិវង្ស នាម អ៊ឹង អនុញ្ញាតឲ្យខ្ញុំធ្វើជាអាចារ្យបង្ហាត់បង្រៀនកូនសិស្សរៀនមក លុះដល់ព្រះពុទ្ធសករាជ ២៤៥១ ត្រូវនឹងឆ្នាំ ១៩០៩ នោះ លោកគ្រូវែរ-ណើរ យេណោរាល គុស្តឹ និងលោកឡឺរេស៊ីដង្តស៊ុប៉េរីយើរ ប៊ូលលុស និងអស់លោកកុង្សសេនាបតី យកសេចក្ដីក្រាបបង្គំទូលព្រះករុណា ជាម្ចាស់ជីវិត ស៊ីសុវត្ថិ និងសម្ដេចព្រះមហាសង្ឃរាជា ព្រះនាម ទៀង យល់ព្រមព្រៀងថា ព្រះពុទ្ធសាសនា បានរុងរឿងថ្កើងទាំងស្ដេចមន្ត្រីរាស្ត្រក្នុងនគរកម្ពុជាធិបតី ចម្រើនសេចក្ដីសុខសប្បាយ ដោយអំណាចអ្នករៀនព្រះត្រៃបិដក ជំនុំព្រមថាគួរគប្បីតាំងសាលាបាលីនៅនគរវត្ត ១

នៅទីវិហារព្រះកែវ ១ សម័យកាលកំណត់ដល់ថ្ងៃ ខែ ឆ្នាំ ហើយ ព្រះករុណាជាម្ចាស់ជីវិតទ្រង់ត្រាស់ប្រើព្រះអង្គម្ចាស់ សុទ្ធារវង្ស ទីអគ្គមហា-សេនា ឲ្យមកពិតព្រះមហាវិមលធម្ម ឲ្យរើសរកអាចារ្យទៅបង្រៀនព្រះត្រៃបិដកឯនគរវត្ត វេលានោះ ព្រះមហាវិមលធម្ម លោកក៏បានឡើងក្រាបបង្គំទូលសម្តេចព្រះមហាសង្ឃរាជជាម្ចាស់ថា សូមទ្រង់ព្រះរាជទានឲ្យព្រះពុទ្ធវង្ស ម៉ី ទៅនៅនគរវត្ត សម្តេចព្រះមហាសង្ឃរាជ ទ្រង់មានព្រះបន្ទូលថា ព្រះពុទ្ធវង្ស ហ្នឹងចេញព្រះរាជប្រកាស ឲ្យជាមេគ្រួគការវិហារអង្គរសៈហើយ ទៅម្តេចបាន ព្រះមហាវិមលធម្មក៏ក្រាបបង្គំទូលថា ព្រះអង្គម្ចាស់ សុទ្ធារវង្ស ផ្តាំផ្តាច់ថា លោកព្រះពុទ្ធវង្សខានពុំបានទេ ត្បិតស្រុករបស់លោកធ្លាប់ទៅរៀបចំជាបឋម ទ្រង់ត្រាស់ថា បើដូច្នោះ ស្រេចលើលោកនិងពុទ្ធវង្សចុះ ទើបលោកក្រាបថ្វាយបង្គំលាចូលដល់កុដិខ្ញុំ ហើយប្រាប់ថាពុទ្ធវង្ស ទ្រង់ឲ្យទៅធ្វើជាអាចារ្យឯនគរវត្ត ទើបខ្ញុំឆ្លើយថាមិនទទួលទេ តាមតែព្រះតេជព្រះគុណមេត្តា បើដកឆ្ការក៏ដកចុះ លោកតបថា ខ្ញុំសង្ឃឹមលោកថាជាសិស្សបម្រើស្ម័គ្រគ្រូបាន ឥឡូវនេះ លោកប្រកែកដដែកយ៉ាងដូចនេះ លោកនិងខ្ញុំកាត់លែងរាប់គ្នាជាគ្រូជាសិស្សតាំងពីថ្ងៃនេះរៀងទៅ ទើបខ្ញុំរំពឹងក្នុងចិត្តថាធម្មតាជាមនុស្សល្អ មិនត្រូវរឹងទទឹងនឹងគ្រូ នឹងម៉ែ-ឪ ជញ្ជឹងហើយ លើកហត្ថាប្រណម្យទូលថា សូមព្រះតេជព្រះគុណមេត្តា អត់ទោសានុទោស ប្រោសប្រណីសេចក្តីខុសឆ្គង សូមមេត្តាលើកលែង សត្វជាខ្ញុំទទួលទៅធ្វើជា

អាចារ្យ លោកថាអើបើដូចថាយ៉ាងនេះ ទើបជាតិជាអ្នកប្រាជ្ញប្រាកដពិតមែន ហើយលោកនិមន្តទៅថ្វាយព្រះពរព្រះអង្គម្ចាស់ សុទ្ធារង្ស ថាពុទ្ធវង្សទទួលព្រមទៅហើយព្រះអង្គម្ចាស់ត្រេកអរណាស់ចូលក្រាបបង្គំទូលព្រះករុណាជីវិត ។ ទ្រង់យល់ព្រម នឹងពងការ ក៏តាំងឲ្យធ្វើជាព្រះពុទ្ធវង្សចាងហ្វាងសាលាបាលីនៅទីនគរវត្តក្នុងឆ្នាំរកាឯកស័ក ព្រះពុទ្ធសករាជ ២៤៥១ ត្រូវនឹង ឆ្នាំ ១៩០៩ ព្រះករុណាជាម្ចាស់ជីវិតទ្រង់ប្រគល់ព្រះពន្ធាមុខនាគ មុខនគរវត្ត ឲ្យបង្រៀនព្រះបរិយត្តិបានពីរឆ្នាំ ។

លុះដល់មកឆ្នាំជូតចត្វាស័ក ពុទ្ធសករាជ ២៤៥៤ ត្រូវនឹងឆ្នាំ ១៩១២ លោកគូវែរណើរ យ៉េណេរ៉ាល បូលលុស និងលោក ឡឺរេស៊ីដង្តសុប៉េ-រីយើរ អែរណេស-អ៊ូត្រី ជំនុំទឹងក្នុងរយសេនាបតីថា អក្សរខ្មែរសរសេរឃ្លាតច្រើន ព្រោះហេតុអ្នកមិនចេះបាលី សំស្ក្រឹត ខេមរៈ ឲ្យប្រាកដទឹងកត់សម្គាល់ពល់ ទេត្តខណ្ឌ ឲ្យគាន់ត្រឹមត្រូវច្បាប់សណ្ដាប់បុរាណ ប្រមូលតួអក្ខរៈព្យញ្ជនៈ សិថិល ធនិត និយ រស្សៈ គរុ លហុ សន្ធិ វិវដ្ដិត និគ្គហិត វិមុត្ត ឃោសៈ អឃោសៈ បទ បាទ មាត្រា ត្រៃភាសាចេះដឹងយល់តិច គួរគប្បីរើសរកអ្នកប្រាជ្ញ អាចឆ្លាសឆ្លុះបុះក្នុងអក្ខរវិធីឋាធតារណា អក្ខរបភេទ សង្កត់សង្កេតឃើញជាក់ច្បាស់ច្បាប់ដាក់អក្សរទៀងពិតពិនិត្យវិនិច្ឆ័យត្រូវល្អ ជំនុំព្រមហើយឡើងក្រាបបង្គំទូលព្រះករុណាជាម្ចាស់ជីវិត ទ្រង់យល់ព្រមហើយ ទើបទ្រង់ត្រាស់បង្គាប់ព្រះអង្គម្ចាស់ សុទ្ធារង្ស ទីអគ្គសេនាធិបតី ឲ្យចូលក្រាបទូលសម្ដេច

ព្រះមហាសង្ឃរាជា ជាម្ចាស់ទ្រង់ស្រួលទទួលសោមនស្សត្រេកអរសរសើរថា បង្កើតមេត្រួតត្រាការសិក្សាអក្សរ នឹងបានជាប្រយោជន៍ ដល់កុល-បុត្រអ្នករៀនសូត្រធម្មវិន័យត្រឹមត្រូវប្រាកដកំណត់បទបាទ មាត្រា បានបរិបូណ៌ ។ ព្រះពុទ្ធចក្រនិងអាណាចក្រថ្កុំថ្កើងរុងរឿង ដោយអំណាចខ្លាចខុស ឃើញខុសហើយស្វែងរកត្រូវផ្លូវប្រតិបត្តិ កំចាត់បាបកម្ម កម្មពៀរកើតអំពីល្ងង់ខ្លៅ ព្រោះអក្សរជាមូល ហេតុបច្ច័យអាស្រ័យនៅក្នុងកុសលធម៌ជាប្ញសគល់ព្រះពុទ្ធសាសនា ។

ព្រះអង្គម្ចាស់ សុទ្ធារង្ស ជ្រាបសេចក្តីហើយ មានបីតិក្រាបបង្គំលាយាត្រាចូលទូលព្រះករុណាជាម្ចាស់លើត្បូងថា សូមទ្រង់ព្រះមេត្តាប្រោសសម្តេចព្រះមហាសង្ឃរាជព្រះរាជអំណរណាស់ ត្រាស់ជាកិច្ចវត្តប្រតិបត្តិប្រពៃ ព្រះករុណាទទួលថា សាធុ ។

ថ្ងៃព្រហស្បតិ៍ ១៥ កើតខែ ពិសាខ ឆ្នាំជូត បត្តាស័ក លោកម្សឺរស៊ីដង្គ សុប៉េរីយើរ អែរណេស-អ៊ូត្រី និងគុម៉ីសៀរដេឡគេ ប៉ូរិកប៉ាត់ដំបង ជួបជុំនៅក្នុងបុនគាឡូមុខនាគសួរថា លោកព្រះពុទ្ធវង្ស ឃើញព្រះរាជប្រកាសទេ បម្រើនពរ បានឃើញ សួរថាឃើញសេចក្តីដូចម្តេចឆ្លើយថាឃើញសេចក្តីពីររឿង គឺឲ្យលោកចៅអធិការនិងគ្រូសូត្របង្ហាត់បង្រៀនភិក្ខុសាមណេរ កុមារសិក្សាលិកិតនព្វក្តកអក្សរ ដែលកុលបុត្រគប្បីរៀនសូត្រ ត្រូវតាមមគធៈ សំស្ក្រឹត ខេមរៈ ឲ្យចេះដឹងច្បាស់ប្រាកដលោកម្សឺរស៊ីដង្គនិយាយថាមានសង្ឃគ្រហស្ថច្រើនជាងរយ សូមធ្វើជា

មេត្រួតនោះ ខ្ញុំមិនព្រមឲ្យ ខ្ញុំយល់ឃើញតែលោកសមគួរធ្វើបាន ត្បិតលោកធ្លាប់ធ្វើជាបាឡាត់សង្ឃវង្ស គ្រាដីការជំនួសសម្តេច ព្រះមហា-សង្ឃរាជាជម្រះអធិករណ៍សង្ឃក្នុងកម្ពុជា និងកូសាំងស៊ីន បានរម្ងាប់ស្រួលហើយសុខផង ហេតុនេះត្រូវយកលោកជាមេត្រួត ឆ្លើយថាអាត្មាភាពចាស់ហើយ សូមអង្វរលោកធំ លោកសួរថា លោកអាយុប៉ុន្មាន? ឆ្លើយថាអាយុ ៥៥ លោកសួរថា សម្តេចព្រះមហាសង្ឃរាជា ព្រះជន្មប៉ុន្មាន ឆ្លើយថាសម្តេចទ្រង់បានព្រះជន្ម ៨៧ លោកថាសម្តេចព្រះជន្ម ៨៧ ឆ្នាំហើយ ទ្រង់គង់ជួយរាជការ ឯលោកទើបតែអាយុ ៥៥ ឆ្នាំ ហេតុម្តេចគេចមិនជួយរាជការ ។

ខ្ញុំទាល់គំនិត បែរសួរតបទៅវិញថា លោកធំឲ្យត្រួតប៉ុន្មានខេត្រ? លោកប្រាប់ថា ត្រួតគ្រប់ខេត្រក្នុងនគរកម្ពុជា អាត្មាភាពម្នាក់ឯងនឹងដើរត្រួតមិនបាន ព្រោះទៅកាន់វត្តនីមួយ ៗ ផ្លូវជិតក៏មាន ផ្លូវឆ្ងាយក៏មាន លោកពោលថា លោកកុំព្រួយឡើយ ឲ្យតែលោកទទួលចុះ រាជការនឹងឲ្យប្រជុំក្នុងទីវត្តមេគណ ដែលនៅជិតសាលាខេត្រ ឬ វត្តឯណាមួយនៅទៀបសាលាខេត្រ ក៏ប្រជុំបានដែរ បើដូច្នោះនោះអាត្មាទទួលធ្វើមេត្រួតបាន លោករន្ធើនថាលោកទទួល? ចម្រើនពរទទួល! ទើបទះដៃស្រោកៗទាំងអស់គ្នា ។

ហើយលោកឡឺរេស៊ីដង់ សុប៉េរីយ៉ើរ បង្គាប់ម៉ុងស៊ីយ៉ើរមាកស៊ីសែហ្វប៉ុស្តិ៍ ខេត្រសៀមរាប រៀបទូកសណ្តពីរ មនុស្ស ៦ នាក់ ចែវជូនដល់

កំពង់ហ្លួង ឡើងចូលវត្ត សន្ធរគហបតីសិរីសុភាស ព្រែកប្រណាក ក្រាបថ្វាយបង្គំលោកគ្រូកម្មវាចារ្យថ្លែងសេចក្តីសព្វគ្រប់ប្រការ លោកសោមនស្សសោទរអំណរណាស់ និងកូនសិស្សទទួលធ្វើកដការ កេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់យសសក្តិចំរើនក្នុងនគរកម្ពុជា ទើបលោកប្រៀនប្រដៅថា មនុស្សកតញ្ញូដឹងគុណ លោកអ្នកមានគុណតិចច្រើនចម្រើនសេចក្តីសុខក្នុងលោកលក្ខណៈយោគយកសម្បត្តិសួគ៌ និព្វានបាន បុណ្យបណ្តុះធ្ងុះផ្លាសប្រាសចាកទុក្ខសោក រោគភ័យចង្រៃឧបទ្រព ពុំមានមន្ទិលសៅហ្មងធ្ងន់ផុតអស់ អស្វារ្យការខន្តីចិត្តអត់ អំណត់សង្កត់ទោសា ក្រោធខឹងប្រឹងប្រុងមិនក្រេវក្រោធ ក្រិត្យវត្តប្រតិបត្តិកំចាត់កំចាយអកុសល បញ្ចេញបញ្ចៀសឲ្យឆ្ងាយពីរនូវទសប្ចំ ពាក្យពេចន៍ពោលពិតទៀងត្រង់អង្គកាយចិត្តសុចរិតជិតជុំល្អប្រពៃ ។

ប្រពៃណីពីបូរាណបានប្រព្រឹត្តធម៌ទាំងបី សិរីសុខសួស្តីជ័យមង្គលចម្រើនឡើង ខ្ញុំទទួលតាមឱវាទ ហើយធ្វើបុណ្យសពលោកគ្រូអនុសាវ-នាចារ្យស្រេច សម្រេចការចូលដល់វត្តឧណ្ណាលោម រាជវិហារព្រះចេតិយ ក្នុំពេញ ឡើងក្រាបថ្វាយបង្គំគាល់ល្អងធូលីជាម្ចាស់ៗទ្រង់ត្រាស់ថារាជការដំនុំ ឲ្យលោកធ្វើការសិក្សាជំការអក្សរ ត្រូវលោកទទួល ត្បិតមុខពន្យល់អក្សរ ដាក់អក្សរត្រឹមត្រូវ ត្រូវមុខឆាន់ៗ ប្រគល់មុខឲ្យលោកត្រួតលើសង្ឃគ្រប់វត្តជំនួសឆាន់ ប៉ុន្តែ លោក ឡឺរេស៊ីដង្គ សុប៉េរយ៉ើរ និយាយនិងឆាន់ថា ច្បាប់អក្សរប្រើសព្វថ្ងៃនេះខុសច្រើន ច្រើនដាក់បែប

សៀម សូមប្រែកែតាមច្បាប់ខ្មែរបុរាណខ្លះ កែថ្មីខ្លះ ទុកជាច្បាប់ខ្មែរ ១ ច្បាប់ សម្រាប់ប្រើក្នុងនគរឲ្យត្រូវគ្នា ហេតុយ៉ាងនេះលោកជម្រះនឹងព្រះមហាវិមលធម្មផង និងអ្នកឧកញ៉ាចក្រីផង ទើបបានសម្រេចរៀងអក្សរនេះ ទទួលតាមព្រះបន្ទូលហើយ ក្រាបថ្វាយបង្គំលាទៅកាន់សំណាក់ព្រះមហាវិមលធម្ម ជាធម្មាចារ្យ គារវគោរពធ្វើវត្តប្រតិបត្តិលោក ។ ក៏ទទួលបដិសណ្ឋារស្រួលទទួលហើយ ពិតលោកថា ល្អងធូលីជាម្ចាស់ទ្រង់បង្គាប់សត្វជាខ្ញុំ ឲ្យសម្រេចសេចក្ដីពីអក្សរ ដែលរាជការបង្កើតមេត្រួតត្រាការសិក្សាធិការនឹងព្រះតេជព្រះគុណ នោះលោកថាពុទ្ធវង្សកុំព្រួយ ខ្ញុំនឹងជួយលោក ឲ្យកើតការកើតប្រយោជន៍ក្នុងពុទ្ធចក្រផង ចំណែកខាងអាណាចក្រក៏ឲ្យបានស្រួល ប៉ុន្តែព្រះអង្គម្ចាស់ សុទ្ធាវង្ស ប្រាប់ខ្ញុំថា មានលោកសង្ឃ ១ អង្គ គិតគួរចង់បានជារបស់ខ្លួនជាអ្នកត្រួតត្រាអក្សរ ក៏ចូលក្រាបទូលល្អងធូលីថា ព្រះអង្គម្ចាស់អគ្គមហាសេនា ដែលបានចូលមកក្រាបបង្គំទូលទ្រង់ថា ហ្លួងព្រមនឹងរាជការ ឲ្យពុទ្ធវង្សធ្វើជាមេត្រួតអក្សរនោះ ពាក្យនេះមិនទាន់ប្រាកដទេ ទ្រង់កុំអាលចេញព្រះបន្ទូល សូមទ្រង់បង្អង់សិន ហេតុយ៉ាងនេះខ្ញុំនឹងនាំលោកចូលថ្វាយព្រះពរហ្លួង ទើបច្បាស់ប្រាកដ ហើយលោកនាំចូលបញ្ញាគ្គប្រាសាទ គាល់ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ចមចក្រពង្សហរិរាជ បរមិន្ទ្រភូវណោយត្រៃកែវហ្វ្រាសុលាល័យ មហោយ្យមហាសម្បត្តិវង្ស ទ្រង់មានព្រះរាជឱង្ការថា ពុទ្ធវង្សសុខសប្បាយទេ សូមថ្វាយព្រះពរអាត្មាភាពបានសុខសប្បាយ ទ្រង់មានព្រះឱង្ការ ថាពុទ្ធវង្សដឹងគុណធ្ងន់ ។ ចុះស៊ីញ

ឲ្យពុទ្ធវង្សធ្វើជាមេគ្រូតអក្សរ ក្នុងនគរកម្ពុជា ថ្វាយព្រះពរថា អាត្មាភាព បួសរក្សាចតុបារិសុទ្ធិសីលនិងចម្រើនមេត្តាភាវនា បង្រៀនព្រះត្រៃបិដក សូមថ្វាយព្រះរាជកុសលដល់បរមបពិត្រ សូមទ្រង់ទទួលតម្កល់ទុកក្នុងព្រះរាជហឫទ័យ ហើយសូមផលានិសង្ស ទ្រង់ចម្រើនព្រះជន្ម ចម្រើនដល់ ១២០ ឆ្នាំ ព្រះករុណាជាម្ចាស់ជីវិតទ្រង់ទទួលថាសាធុ ៗ សម័យកាលនោះ លោកគ្រូព្រះមហាវិមលធម្មថ្វាយព្រះពរថា អាត្មាភាពសូមថ្វាយព្រះពរ សូមព្រះករុណាទ្រង់អនុញ្ញាតឲ្យព្រះពុទ្ធវង្សគ្រូតធម៌វិន័យផង ទ្រង់មានព្រះតម្រាស់ថាពុទ្ធវង្សបានអរណាស់ និងពាក្យលោកមហាវិមល-ធម្ម សូមឲ្យលោកគ្រូតធម៌វិន័យផង បានអនុញ្ញាតឲ្យលោកបង្ហាត់ធម៌តាំងពីធម៌ជយន្តោជាដើមបង្រៀនវិន័យតាំងពីបឋមបញ្ញត្តិជាដើម សូមថ្វាយព្រះពរអាត្មាភាពទទួលតាមព្រះឱង្ការ ហើយថ្វាយព្រះពរលាចេញចាកបរមរាជវាំងចតុមុខ មកអាវាសវិហារនៅទីកុដិដដែលវិញ ៗ

លុះព្រឹកឡើងថ្ងៃអង្គារ ៣ កើត ខែជេស្ឋ ឆ្នាំជូត ចត្វាស័ក ត្រូវគ្នានឹងថ្ងៃ ២ ខែយូអាំង ឆ្នាំ ១៩១២ លោកអ្នកឧកញ៉ាចក្រីធិបតីកុញ្ជរ នាំចូលទៅឯលោក ឡឺរេស៊ីដង់ សុប៉េរីយើរ ។ ប្រាប់ថាព្រះរាជប្រកាសតាំងព្រះពុទ្ធវង្ស ម៉ឺ បានហ្វាង់សាលាបង្រៀនបាលី នៅនគរវត្តខែត្រសៀមរាបចាស់ត្រូវគ្រូតត្រាសាលាបង្រៀនប្រដៅនៅវត្តគណៈមហានិកាយ ដូច្នេះលោកខំបង្រៀនលោកសង្ឃខាងក្នុងក្រុង និងខាងក្រៅក្រុងឲ្យចេះអក្សរឈរ មូល ខំឲ្យចេះគ្រប់កូនសិស្ស ហើយលោករេស៊ីដង់ សុប៉េរីយើរ

ដីឡូរេពូពិកបាកំងសេស ក្នុងក្រុងកម្ពុជាជាអធិបតី លោកបង្គាប់លោក ឧកញ៉ាចក្រី ឲ្យនាំឡើងគាល់សម្ដេចព្រះមហាសង្ឃរាជា ជាម្ចាស់ទ្រង់ជ្រាប ដំណើរហើយ ទ្រង់និមន្តលោកគ្រូព្រះមហាវិមលធម្មមកដល់ ហើយទើប ទ្រង់ត្រាស់បង្គាប់ថា មហាវិមលធម្ម លោកចេញសង្ឃដីកាប្រាប់ភិក្ខុសង្ឃ គ្រប់វត្ត ឲ្យទទួលរៀនតាមពុទ្ធវង្សមេត្រួត លោកក៏ក្រាបទូលថា សូមទ្រង់ ព្រះមេត្តាប្រោស ទូលព្រះបង្គំជាខ្ញុំចេញសង្ឃដីកាមានអំណាចតិច សូម ព្រះរាជទានសញ្ញាប័ត្រតាំងលោកពុទ្ធវង្ស តាមព្រះរាជប្រកាសទើបត្រូវ ល្អ អើលោកថានោះស្រួលមែន ដូច្នេះលោកទៅធ្វើសញ្ញាប័ត្រឲ្យឆាប់ ប្រញាប់ទាន់រាជការ លោកក៏សរសេរតែងសញ្ញាប័ត្របានថ្វាយមួយរំពេច ទើបទ្រង់ឲ្យចុះព្រះសិង្ហាក្នុងសញ្ញាប័ត្រព្រះរាជទានឲ្យហើយ ទ្រង់មានព្រះ បន្ទូលថា មហាវិមលធម្ម លោកជួយឧបត្ថម្ភទំនុកបម្រុងពុទ្ធវង្សឲ្យសុខ ស្រួល លោកទទួលព្រះបន្ទូលថា ព្រះករុណាថ្លៃវិសេស ទូលព្រះបង្គំជាខ្ញុំ នឹងជួយធុរៈពុទ្ធវង្ស សំណៅសញ្ញាប័ត្រលេខ ១៩៥ សុកមតុ ព្រះពុទ្ធ សករាជ ២៤៥៥ ព្រះវស្សា ចុលសករាជ ១២៧៤ សម្ដេចព្រះមហាសង្ឃ រាជាគណាធិបតី សិរីបរមបពិត្រសង្ឃនាយក តិលកលោកាចរិ-យោត្តម បរមមេធសង្ឃជេដ្ឋាមហាសង្ឃរាជា វរោត្តម បរមបពិត្រ ជាមគ្គនាយក សម្រេចសង្ឃកិច្ចអស់ទ្រង់ទូងសង្ឃរាជគណាទាំង ៤ សម្រាប់ទ្រង់យល់ព្រម នឹងរាជការប្រូតិកតូក៏បាកំងសែស ដែលបាន ជំនុំព្រម នឹងព្រះករុណាជាម្ចាស់ជីវិត និងកុងស៊ែយសេនាបតី ដើម្បីនឹងទំនុក

បម្រុងចំណេះវិជ្ជា ជាប្រយោជន៍ផ្សេង ៗ ឲ្យចម្រើនក្នុងនគរ ទ្រង់បាន តាំងព្រះពុទ្ធវង្ស ឲ្យជាមេគ្រួគមេគណ នូវចៅអធិការ មានបណ្ដាសក្តិ ឥតបណ្ដាសក្តិ គ្រប់វត្ត គ្រប់ខេត្តខាងអក្សរខ្មែរ ឲ្យយកចិត្តទុកដាក់សិក្សា ខំបង្ហាត់បង្រៀនកូនសិស្ស ដូចមានក្នុងព្រះរាជប្រកាសលេខ ៧៥ ស្រាប់ ៗ

អាយុ វណ្ណ សុខ ពល ឲ្យចម្រើនថ្កុំថ្កើងរុងរឿងក្នុងព្រះពុទ្ធសាសនា តរៀងទៅ ៗ

សញ្ញាប័ត្រ ធ្វើក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ ចុះថ្ងៃ ១០ រោច ខែបឋមាសាឍ ឆ្នាំជូតបញ្ចស័ក ត្រូវនឹងថ្ងៃទី ៩ ខែសូយេត ឆ្នាំ ១៩១២ ៗ

សម្ដេចព្រះមហាសង្ឃរាជ ទ្រង់ប្រដៅថា ពុទ្ធវង្សឧស្សាហ៍ព្យាយាម បង្រៀនពន្យល់មេគណ និង ឧបជ្ឈាយ៍ អាចារ្យអធិការ គ្រូសូត្រ ឲ្យខំ បង្ហាត់បង្ហាញកូនសិស្សឲ្យរៀនអក្ខរវិធី ឋាន ១១ ករណ ៤ អក្ខរភេទ ១០ ឃោសៈ អឃោសៈ គរុ លហុ ឲ្យចេះដឹងជាក់ច្បាស់ប្រាកដ កត់សម្គាល់ អក្សរត្រឹមត្រូវខ្យល់តាំងពីតូច ៗ មក ទើបបួសបានពេញផ្នួសបរិបូណ៌ បើ មិនចេះចាំអក្ខរវិធីទេ បព្វជិតកិច្ចពុំសម្រេចក្នុងព្រះពុទ្ធសាសនា ៗ

លុះថ្ងៃសុក្រ ២ កើតខែអាសាឍ ឆ្នាំរោងសប្តស័ក ត្រូវនឹងថ្ងៃ ១ ខែសូយ៉េត ឆ្នាំ ១៩១៦ ព្រះតេជព្រះគុណព្រះមហាវិមលធម្មជាធម្មាចារ្យ អធិប្បាយថា ពុទ្ធវង្សរាជការឲ្យដំនុំជំរះអក្សរបុរាណ ដែលប្រើចន្ទបាទគួស ក្រោមពីនោះ ដូចគុប្រឡំទៅជាទូ លោកកែប្រែធ្វើជាអឡូចន្ទដាក់ខាង លើ គិតបសេចក្ដី ៗដ ហេតុយ៉ាងនេះពុទ្ធវង្សបង្រៀនអក្សរឲ្យចេះ

វណ្ណយុត្តិ ចេះការន្ត ចេះព្យាង្គ ចេះដឹងសព្ទនាម នាមសព្ទ ត្រៃភា-សាបាលី សំស្ក្រឹត ភាសាខ្មែរ ឥត្ថីលិង្គ បុំលិង្គ នបុំសកលិង្គ បទ ឆាទ មាត្រា គរុ លហុ ក៏បង្ហាត់ពន្យល់ មាត្រាអក្ខរ ដូចអក្សរផ្ញើរដឹង អឃោសៈ សម្លេងស្រាល សម្រាប់ឃោសៈ សម្លេងធ្ងន់ឲ្យលុះអំណាចមាត្រាជាសម្លេងស្រាលវិញបាន បង្រៀនវគ្គ អវគ្គ ឲ្យតម្រួតអក្សរតាមវគ្គពុទ្ធវង្សលោកខំបំភ្លឺកិច្ចសាមណេរឲ្យសិក្សាធម្មវិន័យ តាមព្រះឱង្ការហ្វូងអនុញ្ញាត បើលោកសង្ស័យក្នុងធម៌ ឬ វិន័យសិក្ខាបទឯណាមួយ លោកសួរខ្ញុំកុំកោតញញើត ប៉ុន្តែលោកកុំកាន់សេចក្តីប្រមាទ ប្រហែសធ្វេស ធ្វើចិត្តសុចរិតប្រព្រឹត្តត្រឹមត្រូវតាមព្រះពុទ្ធដីកា ក៏គុណធម៌ទ្រទ្រង់លោកឲ្យចម្រើន សុខកាយសុខចិត្តឋិតថេរចេរកាល កំណត់អាយុវ័យចំណោរនៅអនាគតនឹងបានកើតទាន់ព្រះពុទ្ធត្រាស់ ហើយបានសម្រេចមគ្គផលដ៏វិសេស ។

សិស្សគណរបស់លោកក្តី កូនចៅខាងខ្ញុំក្តី លោកប្រដៅឲ្យចេះដឹងផង ធម្មទាន គឺ ឲ្យទានធម៌ដែលខ្លួនចេះដឹងប្រឹងបង្ហាញអ្នកដទៃយល់ឃើញជាក់ច្បាស់ ច្បាប់ព្រះទ្រទ្រង់សម្តែងថ្លែងទុកក្នុងព្រះត្រៃបិដក ដឹកនាំសាសនិកជន ឲ្យជឿមគ្គផលផុលផុសកុសលប្រពៃពេកណាស់ អានិសង្សផលដែលអាចនឹងបង្ហូរ និងផ្តល់សេចក្តីសុខ សេចក្តីចម្រើនមកឲ្យ គុណធម៌ដែលបង្ហូរ ដែលផ្តល់ផលបុណ្យមកឲ្យមិនដាច់ ដូចដល់សម្រេចគុណប្រយោជន៍ក្នុងលោកិយនេះផង ចំណោរទៅបរលោកនាយ នឹង សប្បាយ

ដោយភោគសម្បត្តិ បរិវារសម្បត្តិ សម្បូណ៌ហូរចូលសុទ្ធស្ថានគឺ អមតមហានិព្វាន ពុទ្ធវង្សខ្ញុំខំសន្សំធម្មទានបានគម្ពីរ ១០០ និងព្យាយាមប្រែសាស្ត្រាបាលីសព្វថ្ងៃនេះ ជាធម្មទានរបស់ខ្ញុំ ។

នធករ ២៤៧០ ថ្ងៃអាទិត្យ ១ រោច ខែស្រាពណ៍ ឆ្នាំថោះនព្វស័ក ត្រូវនឹងថ្ងៃ ១៤ ខែអាគ៊ូត ឆ្នាំ ១៩២៧ ។

ព្រះពុទ្ធវង្ស អ៊ុឹង ខេត មុឹ មេត្រួតការសិក្សាធិការអក្សរខ្មែរ ក្នុងនគរកម្ពុជា វណ្ណនាគុណកថា ព្រះតេជព្រះគុណ ព្រះមហាវិមលធម្មនាម ថោង លោកមានគុណអនេកអនន្តពន់ពេកណាស់ ព្រោះហេតុគុណសម្បត្តិលោកបង្រៀនបង្ហាត់បង្ហាញហ្វឹកហ្វឺន ខ្ញុំព្រះករុណាឲ្យចេះដឹងចំណេះវិជ្ជាក្នុងពុទ្ធចក្រផង និងសិល្បសាស្ត្រឆ្លាសឆ្លុះចុះក្នុងអាណាចក្រ ដាក់បញ្ចូលជាអាចារ្យ ក្នុងរាជការផង ឧបការគុណទាំងពីរនេះ ជាគុណុត្តរគុណប្រសើរដោយវិសេសក្នុងបច្ចុប្បន្នកាល និងអនាគតកាល ដែលខ្ញុំសាងសន្សំ ទាន សីល ភាវនា ជាកុសលសម្បត្តិ ខ្ញុំសូមឧទ្ទិសផលបុណ្យបញ្ជូនដល់ ព្រះតេជព្រះគុណធ្ងន់ ដែលទិវង្គតទៅកាន់ស្ថានសួគ៌ ឬ ភពឯណា ៗ សូមព្រះតេជព្រះគុណទទួលអនុមោទនាត្រេកអរនឹងផលបុណ្យនេះចុះ បើព្រះតេជព្រះគុណសោយសុខសម្បត្តិ ហើយជួយរក្សាព្យាបាលព្រះពុទ្ធសាសនា ឲ្យបានថ្កុំថ្កើង រុងរឿងរៀងរល់ទាល់ ៥.០០០ ព្រះវស្សា សិស្សានុសិស្សសូត្ររៀនគន្ថធុរៈនិងវិបស្សនាធុរៈរលឹក

នឹកដល់ព្រះតេជព្រះគុណ ព្រះតេជព្រះគុណមេត្តាជួយ ចម្រើនសេចក្ដីសុខ និងទុក្ខភ័យរោគសោកស្មោកគ្រោកបញ្ចៀសបញ្ចោញ អស់ពីខន្ធសន្ដាន សន្ដោសប្រោសប្រណីសាសនិកជន ពន្លឺពន្លកជ្រែកក្នុងព្រះពុទ្ធសាសនាឲ្យ សប្បាយកាយចិត្តចេតនា សុចរិតចិតខំរំពឹងគុណ ព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណ ជានិច្ចកាល ។

ពណ៌នាកិត្តិគុណ

---

# ព្រះមហាវិមលធម្ម ថោង ជារឿនឃ្លាង

## ក្រសួងចាត់ភិក្ខុសង្ឃជាគណៈមហានិកាយ តាមការក្នុង

## ព្រះបរមរាជវាំង ចតុមុខ

*ដែលបានជាការជំនុំព្រម ឲ្យធ្វើបានហ្វានសាលាបរិយត្តិធម៌*

មើលត្រួតត្រាអាចារ្យនិងសិស្សដែលរៀនព្រះពុទ្ធវចនៈមានចំនួនគ្រប់

ថ្នាក់ទាំង ៣ ថ្នាក់

*គឺមូលវិជ្ជា ១ មជ្ឈិមវិជ្ជា ១ ឧត្តមវិជ្ជា ១*

អំពីដំបូងតាមព្រះរាជប្រកាស

តៀតក្នុងឆ្នាំខាលឆស័ក ត្រូវនឹងឆ្នាំ ១៩៦៤ :

ព្រះមហាវិមលធម្ម **ថោង** និងមោនសៀរ សឺដេស បានរៀបចំប្រឡងរើសសិស្សនឹងឲ្យចូលរៀន ក្នុងសាលាបាលីជាដំបូងបានជ្រើសរើសសិស្សគឺភិក្ខុនិងសាមណេរដែលបានរៀនបាលីបានតិច ឬច្រើនធ្វើជាពួក ៗ ភិក្ខុនិងសាមណេរបានរៀនមង្គលទីបទី ១ ពួក បានរៀនធម្មបទ ១ ពួក បានរៀនមូល ១ ពួក ជា ៣ ពួកដូច្នេះ ទើបឲ្យភិក្ខុនិងសាមណេរដែលបានរៀនមង្គលទីបទី ចូលប្រែប្រយោគក្នុងគម្ពីរមង្គលវិបនីមួយអង្គម្ដង ៗ ហើយឲ្យពិន្ទុតាមសតិបញ្ញាដែលខ្លាតនឹងមិនខ្លាត រៀងរាបដរាបដល់អស់ភិក្ខុសាមណេរដែលចូលប្រឡងនឹងប្រឡងរឿងដ៏ទៃផ្សេង ៗ ផង ទើបជ្រើសរើសនូវភិក្ខុនិងសាមណេរ ដែលបានពិន្ទុច្រើនជាងគេចំនួន២០រូប ។

ឲ្យភិក្ខុសាមណេររៀនធម្មបទ ចូលប្រែប្រយោគ ក្នុងគម្ពីរធម្មបទមួយអង្គម្ដង ៗ ហើយឲ្យពិន្ទុដូចសេចក្ដីខាងលើ ទើបជ្រើសរើសភិក្ខុនិងសាមណេរចំនួន ២០ រូប ។

ឲ្យភិក្ខុនិងសាមណេររៀនមូល ចូលប្រែប្រយោគក្នុងគម្ពីរមូលធ្វើដូចសេចក្ដីខាងលើ ជ្រើសរើសភិក្ខុសាមណេរ ២០ រូប ដែលធ្វើការប្រឡងនេះក្នុងថៃវឱបោសថវេតនាកម ។

ព្រះមហាវិមលធម្ម ប្រឡងសិស្សបានចំនួន ៦០ រូបស្រេចហើយ ទើបចាត់ការបង្រៀនក្នុងសាលាមន្ទីរសទ្ធម្ម ជា ៣ ចំណែក គឺរៀន

ចំណែកខាងលិច រៀបគុកៅអីសម្រាប់អង្គុយអាចារ្យនិងសិស្ស ដែលបង្រៀននិងរៀនមូលវិជ្ជា ព្រះមហាវិមលធម្ម តាំងអាចារ្យពីររូប គឺព្រះញាណបវរវិជ្ជា ឯម ព្រះគ្រូសង្ឃសត្ថា ឈាត ឲ្យបង្រៀនមូលវិជ្ជា ចំនួនសិស្ស ២០ រូប ។

ពីរល្វែងចំណែកខាងកើត រៀបគុកៅអីសម្រាប់អង្គុយអាចារ្យនិងសិស្សដែលបង្រៀននិងរៀនមជ្ឈិមវិជ្ជា ព្រះមហាវិមលធម្ម តាំងអាចារ្យពីររូប គឺព្រះញាណវីរិយ ឌុង ឧកញ៉ាសុទ្ធម្មប្រីជា គង់ ឲ្យបង្រៀនមជ្ឈិមវិជ្ជា ចំនួនសិស្ស ២០ រូប ។

ពីរល្វែងកណ្ដាលដែលសល់ទាំងប៉ុន្មាន រៀបគុកៅអីសម្រាប់អង្គុយបង្រៀន និងរៀនអាចារ្យនិងសិស្សព្រះមហាវិមលធម្មនិងអាចារ្យ យ៉ាំង បង្រៀនឧត្តមវិជ្ជា រៀងរាល់ល្ងាចព្រឹក តាមកំណត់វេលាពីរសៀលម៉ោង១ដល់ ម៉ោង ៥ ហើយចេញចាកសាលា ទៅកាន់ទីលំនៅខ្លួន រៀងរាល់ថ្ងៃ ។

១- ពួកសិស្សដែលរៀនឧត្តមវិជ្ជាគ្រប់ពីរឆ្នាំ ព្រះមហាវិមលធម្ម តាំងការប្រឡងចេញតាមព្រះរាជប្រកាស ។

គ្រាក្រោយពួកសិស្សបានសញ្ញាប័ត្រ សុំធ្វើគ្រូបង្រៀនក្នុងក្នុងវត្តនីមួយ ៗ រាជការមិនអនុញ្ញាតឲ្យ ព្រោះមិនចេះភាសាបារាំងសែស ព្រះមហាវិមលធម្ម បានដឹងហេតុ មានចិត្តមេត្តា ដល់សិស្សខាងក្រោយ

ឲ្យមានប្រយោជន៍ទៅខាងមុខ ក៏ធ្វើសំបុត្រសូមគ្រូ បារាំងបញ្ជូនទៅរាជការ ។ យល់ព្រម បានចាត់គ្រូបារាំងឲ្យមកបង្រៀន ។

ពួកសិស្សដែលរៀនធម្មបទ តាំងពីម៉ោង ៨ ដល់ម៉ោង៩ កន្លះ ព្រះមហាវិមលធម្ម ចាត់ការបង្រៀនដូចនិយាយមក ខាងលើនេះ ឃើញថាចុះរបៀបជាផ្លូវរាជការឲ្យចម្រើនប្រយោជន៍ដល់សិស្ស ដែលរៀនបរិយត្តិធម៌ ឲ្យកើតសទ្ធាជ្រះថ្លាក្នុងពុទ្ធសាសនាក្លាហានផង ។

២- ព្រះមហាវិមលធម្ម បានប្រឹក្សាពួកអាចារ្យ ហើយក៏បង្គាប់ព្រះញាណវិរិយ ឧ.ង ខ្ញុំឲ្យតែងរៀបចំរឿងបឋមសម្ពោធិកថា ជាសង្ខេបតាមបរិច្ឆេទខ្លីនិងវែង ឲ្យល្មមស្តាប់បានគណនាវង្សព្រះបាទមហាសម្មត-រាជជាដើមជាលំដាប់ៗគ្នា មកដល់ព្រះពុទ្ធអង្គបានយាងទៅប្រោសបញ្ច-វគ្គិយភិក្ខុក្នុងព្រៃឥសិបតនមិគទាយវ័នជាទីបំផុត ។

ដើម្បីបង្រៀនសិស្សក្នុងសាលាបាលី ឲ្យដឹងពុទ្ធប្បវត្តិក្នុងការប្រឡងចេញ ហើយឲ្យព្រះខ្ញុំបង្រៀន មិនតែប៉ុណ្ណោះឡើយ បានបង្គាប់ព្រះខ្ញុំឲ្យបង្រៀនតែងគាថាតាមគម្ពីរវុត្តោទ័យពន្យល់ តាមអដ្ឋកថានិងដីកា ព្រះខ្ញុំក៏ទទួលតាមបង្គាប់ធ្វើដរាបមក មិនឲ្យខុសពេលវេលា ព្រះមហាវិមលធម្មនិងមានពាក្យពោលបន្ទោសព្រះខ្ញុំថា ធ្វើខុសមិនត្រឹមត្រូវឥតអង្គីមាន ។

៣ គ្រាក្រោយមកលោកអ្នកឧកញ៉ាចក្រីធិបតីកុញ្ញរ ក្រសួងសិក្សា-ធិការ បានប្តឹងរាជការយកព្រះខ្ញុំជួយជំនុំតែងអក្ខរាភិធានសព្ទជាមួយផង

សូម្បីពិភាក្សា អធិប្បាយពាក្យដដែលគ្នា ឲ្យស្របសេចក្ដីយល់ព្រមគ្នា ឲ្យឃើញត្រឹមត្រូវតាមទំនងពាក្យនីមួយ ៗ ក៏មិនដែលបន្ទោសព្រះខ្ញុំថា ដូចម្ដេច ៗឡើយ ខំព្យាយាមធ្វើជាលំដាប់ ៗ ដកបដល់សម្រេចការ ៗ

៤- គ្រាក្រោយមកទៀត រាជការទំនុកបម្រុងធ្វើសាលាបាលីថ្មីនៅទីដីខាងកើតសាលាវដ្ដបាល ដើម្បីឲ្យប្រមូលសិស្សទាំងអស់ទៅរួបរួមបង្រៀនក្នុងសាលាថ្មីនោះ ព្រះមហាវិមលធម្ម បានចាត់ការរៀបចំដូចមានសេចក្ដីខាងដើម ហើយមានឧស្សាហ៍ដាស់តឿនសិស្ស ត្រួតត្រាមើលការខុសត្រូវសព្វគ្រប់ ឲ្យសិស្សព្យាយាមរៀនកុំឲ្យធ្វេសប្រហែស ៗ

ពួកសិស្សដែលរៀនយកចិត្តទុកដាក់ បញ្ញាឆ្លាតក្នុងបរិយត្តិធម៌ជាងសិស្សទាំងពួង ព្រះមហាវិមលធម្ម មិនហាមបង្កាប់ឲ្យឡើងថ្នាក់តែម្ដងតាមអំពើចិត្តខ្លួន ដែលស្រឡាញ់កប់សានឡើយ ព្រះមហាវិមលធម្មប្រជុំអាចារ្យ ២ នាក់ ឬ ៣ នាក់ហើយបើកប្រយោគគម្ពីរតាមថ្នាក់ទាំង ៣ ៗ

បើពួកសិស្សរៀនមូលវិជ្ជា ឲ្យប្រែប្រយោគក្នុងធម្មបទ ៗ

ពួកសិស្សរៀនមជ្ឈិមវិជ្ជា ឲ្យប្រែប្រយោគក្នុងមង្គលទីបនី ៗ

ពួកសិស្សរៀនឧត្ដមវិជ្ជា ឲ្យប្រែប្រយោគក្នុងវិសុទ្ធិមគ្គ ៗ

ដែលឲ្យចូលប្រែប្រយោគដូច្នេះមួយអង្គម្ដង ៗ ស្រេចហើយឲ្យពិន្ទុតាមសតិបញ្ញា សិស្សឆ្លាតនិងមិនឆ្លាត ពួកសិស្សណាដែលបានពិន្ទុច្រើនជាងគេ ក៏បញ្ជូនទៅក្នុងថ្នាក់ទីមួយ ៗ ធ្វើដូច្នេះ ដើម្បីឲ្យសិស្សមានព្យាយាម

ខំរៀនបរិយត្តិធម៌ ជាប្រយោជន៍សាសនាខ្លះ ជាប្រយោជន៍ខ្លួនក្នុងលោកនេះខ្លះ ។

ព្រះមហាវិមលធម្ម ចាត់ការដូចសេចក្តីខាងលើនេះ ឃើញថាជាយុត្តិធម៌មិនឲ្យសិស្សនិន្ទាតិះដៀលដោយចិត្តស្អប់ពល់គ្នា ។

៥. ព្រះមហាវិមលធម្ម គិតឃើញថាក្រែងពួកសិស្សទើសទាល់នឹងប្រែសព្ទក្នុងបាលីបានចបួលព្រះខុំអាចារ្យ យ៉ង់ អាចារ្យ ម៉ូត ប្រែវិគ្គហបាលីដែលស្រង់យកអំពីគម្ពីរផ្សេងៗខ្លះ យកអំពីគម្ពីរអភិធានប្បទីបិកាខ្លះ សរសេរបទបាលីដែលជាវិគ្គហនីមួយៗប្រែជាសម្រាយ តាមខេមរភាសាសុទ្ធ ជាដំណើរសេចក្តីដូចបទសាធកក្នុងមូលកច្ចាយនៈដើម្បីនឹងឲ្យកជការជួយទំនុកបំរុងបោះពុម្ពទុកសម្រាប់សាលា ខំប្រែចំនួន ១០ ខែទើបស្រេចការ ការដែលប្រែវិគ្គហនេះ ឃើញថាមានប្រយោជន៍ច្រើន មិនឲ្យទាល់សព្ទបាលីក្នុងបាលីក្នុងគម្ពីរផ្សេងៗដែលជាប់សព្ទប្លែកៗ មិនធ្លាប់ប្រទះប្រែ ។

ព្រះមហាវិមលធម្ម នាំធ្វើដូចសេចក្តីខាងលើនេះ ឈ្មោះថាជួយទំនុកបំរុង ពួកជនខាងក្រោយ ដែលមិនចេះដឹងស្គាល់យល់ភាសាបាលី ឲ្យចេះដឹងស្គាល់យល់ភាសាបាលីថាជារបស់ក្រមែន នឹងមិនបានមើលងាយ នូវពាក្យសាសនព្រះពុទ្ធអង្គ ។

បើអ្នកមានបញ្ញាគង់គិតឃើញថា សេអគ្គ ទុទ្ទោវាទា ពុសា-

សង្ឃ ក្រមុំះទៅហើយ ធម្មសេនិងវិមុត្តិសេ របស់ព្រះពុទ្ធអង្គក្រណាស់ និងគណនាត្រាប់ពុំបានឡើយ ។

ហេតុដូច្នេះព្រះញាណវិរិយ ឡុង ខ្ញុំ មានសេចក្តីនឹកអាល័យស្តាយលោកណាស់ បានជាវេលាលោកបង្កើតអាពាធជាទម្ងន់ព្រះខ្ញុំទៅសួរលោកបានតែ ២ ផង លោកក៏អនិច្ចធម្មទៅ កាលដែលលោកអនិច្ចធម្មកន្លងទៅហើយ ព្រះខ្ញុំបានបបួលសិស្សជាគណៈធម្មយុត្តិកនិកាយ បានបច្ច័យចំនួន ៣២ រៀល យកទៅចូលធ្វើបុណ្យ ជាការអនុស្សតិរឭកគុណូបការ ។

សេចក្តីដែលពណ៌នាមកខាងលើនេះ ជាសេចក្តីពិតត្រង់តាមរឿងដែលព្រះខ្ញុំ បានសេពគប់ធ្វើការជាមួយមក ចំនួន ២ ឆ្នាំ ។

គួរសាធុជនទាំងពិចារណាតាមកិត្តិគុណកជានេះ ហើយនឹករឭកដល់គុណព្រះមហាវិមលធម្ម ថោង គ្រប់គ្នា ។

ព្រះញាណវិរិយ

ឡុង

# កិត្តិគុណកថា

*របស់ព្រះមហាវិមលធម្ម នាម ថោង*

## ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

## អាចារ្យ អ៊ិត ហាក់

## គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

*ពណ៌នាសរសើរ*

# គុណកថា

ពាក្យពោលសរសើរគុណសម្បត្តិនិងគុណូបការ នៃព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម ឧត្តមមេធាវីវិទូទេសវិសេសធម្មសុចរិតា មហាបរិយត្តិនាយក ចាងហ្វាងសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ ព្រះនាម ថោង ។

សេចក្តីក្នុងគុណកថានេះ នឹងបានពណ៌នារៀបរាប់ឲ្យសព្វគ្រប់តាំងអំពីព្រះតេជព្រះគុណលោកសម្ភពប្រសូតិក្នុងទីណា ៗ ជាដើម ឲ្យពិស្តារវែងឆ្ងាយទៅក៏ទេ គ្រាន់តែស្រង់យកគុណសម្បត្តិ ឬ គុណូបការ របស់លោកមកពណ៌នា យ៉ាងសង្ខេប ៗ ដើម្បីនឹងសម្តែង ឲ្យប្រាកដជាក់ស្តែងក្នុងសម័យដែលលោកទម្លាយខ័ន្ធ ទទួលអនិច្ចធម្មទៅនេះ ចំពោះលើរូបខ្ញុំជាកូនសិស្ស ដែលមានសេចក្តីស្តាយលោកជាទីបំផុតនោះ ខ្ញុំនឹងអត់ទ្រាំសម្ងំស្ងៀមនៅពុំបាន បានជាខ្ញុំសូមប្រកាសរឿងគុណកថានេះតាមពាក្យសច្ចៈរបស់ខ្ញុំ ដូចមានរៀបរៀងតយសេចក្តីជារបៀបខាងក្រោយនេះជាសាក្សីស្រាប់ ។

បឋមហេតុដំបូង កាលពីដើមខ្ញុំនៅរៀនសូត្របួសជាសាមណេរនៅវត្តសត្បូរ ក្នុងឃុំសត្បូ ស្រុកកៀនស្វាយ ខ្ញុំបានឮសំដីមនុស្សដែលគេទៅមកក្រុងភ្នំពេញ គេនិយាយពណ៌នាសរសើរពីគុណសម្បត្តិ របស់លោកគ្រូព្រះមហាវិមលធម្ម ព្រះនាម ថោង កាលលោកនៅគង់ការជាព្រះបាឡាត់សំរិដ្ឋានៅឡើយ គឺជាបាឡាត់របស់សម្តេចព្រះមហា-

សង្ឃរាជា សង្ឃនាយក ទ្រង់ព្រះនាម ទៀង គង់នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ សេចក្ដីសរសើរជាដូចេះ ៖

លោកព្រះបាឡាត់សំរិដ្ឋា ទៅរ៉ង លោកជាអ្នកប្រាជ្ញអាចចេះដឹងច្រើនក្នុងព្រះបរិយត្តិធម៌ គឺភាសាបាលីព្រះត្រៃបិដក ព្រមទាំងគតិលោកគតិធម៌ បើអ្នកណាបានទៅនៅរៀនសូត្រក្នុងសំណាក់លោកហើយ មិនសូវជាគជ័យទេ ច្រើនបានមានកេរ្តិ៍ឈ្មោះសម្រេចប្រយោជន៍ផ្សេង ៗ ព្រោះលោកមានព្រះហឫទ័យ រាប់អានទំនុកបម្រុងសង្គ្រោះអ្នករៀនសូត្រណាស់ ហើយលោកមានព្យាយាមក្នុងការបង្ហាត់បង្ហាញសាស្ត្រាបាលី មិនចេះខ្ជិល មានគ្រៀតបង្ហាញវេលាយប់ផង បើកូនសិស្សណារៀនបានចេះដឹងល្អមធ្យ៉ត្រ អាចារ្យបង្រៀនសិស្សបាន លោកមានអំណរណាស់ លោករឹតតែជួយទំនុកបម្រុង ឲ្យកាន់តែចម្រើនចំណេះចម្រើនលាភច្រើនឡើងទៅទៀត ព្រះហទ័យលោកមិនដែលស្អប់អ្នកចេះដឹងទេ លោកស្រឡាញ់រាប់អានអ្នកចេះដឹងជាទីបំផុត កុំថាឡើយតែកូនសិស្សរបស់លោក សូម្បីកូនសិស្សលោកណាក៏ដោយ តែគេចេះដឹងហើយលោកមិនមានព្រះហឫទ័យឥច្ឆាឈ្នានិះឡើយ លោកស្រឡាញ់រាប់អានពេញទី ដូចកូនសិស្សរបស់លោក បើមានឱកាសល្អមជួយទំនុកបម្រុងឲ្យមានប្រយោជន៍ មានកេរ្តិ៍ឈ្មោះបាន លោកក៏ជួយឲ្យបានសម្រេចប្រយោជន៍តិចច្រើន តាមកម្លាំងអន្តេវាសិក និងសទ្ធិវិហារិក ដែលនៅក្នុងសំណាក់លោកទាំងប៉ុន្មាន មិនដែលព្រួយពីសេចក្ដីអត់ឃ្លានឡើយ លោកអាច

និងចិញ្ចឹមបានទាំងអស់ ឥតមានព្រះទ័យធុញថប់ឡើយ ។

ខ្ញុំបានឮគេពណ៌នាសរសើរគុណសម្បត្តិរបស់លោករឿយ ៗ ដូច្នោះហើយ ក៏មានចិត្តនឹកស្រឡាញ់លោកពីចម្ងាយពន់ពេកណាស់ មានចិត្តគិតចង់ប្រាថ្នាមកនៅជ្រកកោន រៀនសូត្រនឹងលោក ។

គិតហើយ ទើបទូលលោកគ្រូ ព្រះសំវរបញ្ញា ជាចៅអធិការវត្តសត្ថរ ជាគ្រូដើមរបស់ខ្ញុំសិកចាកសិក្ខាបទជាគ្រហស្ថ មកសុំនៅជ្រកកោនក្រោមម្លប់បុណ្យលោក រៀនសូត្រនឹងលោក តាំងពីខ្ញុំនៅក្នុងវ័យអាយុ ១៩ ឆ្នាំ ពាក្យដែលគេនិយាយសរសើរគុណសម្បត្តិរបស់លោកទាំងប៉ុន្មានពីដើមមកនោះ ខ្ញុំមិនមានភ្លេចសោះ ខ្ញុំតាំងព្យាយាមសង្កេតអាការកិរិយាប្រព្រឹត្តហេតុរបស់លោកជានិច្ច ហើយយកមកប្រៀបផ្ទឹមផ្ទួនគ្នានឹងពាក្យដែលគេសរសើរនោះ ប្រៀបផ្ទឹមមើលសព្វគ្រប់ទៅ ឃើញថាប្រាកដពិតមែន ដូចពាក្យគេនិយាយឥតមានខ្វះ មានតែវិសេសលើសជាងនេះទៅទៀត ខ្ញុំក៏រឹតតែពេញចិត្តឥតមានរង្កៀសអ្វីសោះឡើយ ខ្ញុំតាំងចិត្តគោរពប្រតិបត្តិលោក ទុកលោកដូចជាមាតាបិតារបស់ខ្ញុំ លោកក៏មានព្រះហឫទ័យមេត្តាករុណាទំនុកបម្រុងខ្ញុំដូចជាកូន ដល់ខ្ញុំបានអាយុ ២០ ឆ្នាំ លោកប្រាប់ខ្ញុំថា ឯងល្មមបួសជាភិក្ខុហើយ កិច្ចដែលនឹងបំបួសនោះ ស្រេចនៅលើឆាន់ទាំងអស់ ។

ខ្ញុំក៏មានអំណរពេកណាស់ ដោយគិតឃើញថា ខ្លួនមកនៅក្នុងទីនេះ ឥតមានញាតិសាលោហិតឯណាមួយនឹងជួយឧបត្ថម្ភក្នុងការបួសនោះឡើយ

ទើបខ្ញុំទូលតបទៅលោកវិញថា បើព្រះតេជព្រះគុណ នឹងមេត្តាសង្គ្រោះខ្ញុំព្រះករុណាដូច្នោះ ខ្ញុំព្រះករុណា មានអំណរអរព្រះតេជព្រះគុណឥតប្រៀបបាន ដោយមានព្រះតេជព្រះគុណជាទីពឹងមាំ ដល់ខ្ញុំព្រះករុណាបួស សូមនិមន្តព្រះតេជព្រះគុណធ្វើជាឧបសម្បទាចារ្យ សូត្រឲ្យខ្ញុំព្រះករុណាម្ខាង សូមនិមន្តសម្តេចព្រះមហាសង្ឃរាជជាធ្វើជាព្រះឧបជ្ឈាយ៍ គ្រូសូត្រម្ខាងទៀត ស្រេចទៅព្រះតេជព្រះគុណសព្វព្រះហឫទ័យចុះ បើព្រះតេជព្រះគុណសព្វព្រះហឫទ័យយកលោកណា ខ្ញុំព្រះករុណាក៏ទទួលយកលោកនោះតាមអធ្យាស្រ័យព្រះតេជព្រះគុណ លោកមានពុទ្ធដីកាថា ឆាន់មិនសូត្រទេ ឆាន់បានបង្ហាត់បង្រៀនឯងហើយចាំបាច់សូត្រអីទៀត ត្រូវយកលោកឯទៀតឲ្យសូត្រទាំងអស់ទៅទើបល្អ ដើម្បីឲ្យបានគ្រូច្រើនទីង បានជួយប្រដៅគ្នា កុំប្រកាន់តែមួយ ៗ ដូច្នេះមិនត្រូវទេ មនុស្សដែលចេះដឹងច្រើន អាស្រ័យនឹងគ្រូច្រើន មនុស្សម្នាក់ ៗ មិនដែលចេះចំណេះវិជ្ជាគ្រប់យ៉ាងទេ ខ្លះចេះវិជ្ជានេះ ខ្លះចេះវិជ្ជានោះ តាមវាសនា បើទុកជាចេះចំណេះដូចគ្នា ក៏គង់មានខ្លាំងមានខ្សោយ ៗ

លោកមានព្រះពុទ្ធដីកាដូច្នោះហើយ ខ្ញុំក៏ចូលចិត្តស្តាប់បាន ឃើញថាត្រូវប្រាកដមែន ឃើញថាលោកមិនមានព្រះហឫទ័យហួងហែងកូនសិស្ស ព្រះហឫទ័យលោកត្រង់នេះ រកបានដោយកម្រណាស់ ព្រោះធ្លាប់ដឹងមក មានលោកខ្លះប្រកបដោយសិស្សមច្ឆរិយ បើមានកូនសិស្សមកនៅរៀនសូត្រផង តែងហួងហែងមិនឲ្យកូនសិស្សខ្លួន ទៅរៀនសូត្រ

ទីងអ្នកណាឡើយ កាលបើដល់កាលកំណត់គ្រូកូនសិស្សនោះ បួសជាភិក្ខុ ឬសាមណេរ មិនដែលឲ្យទៅបួសទីងលោកណាសោះ ទុកឲ្យនៅបួសតែក្នុងសំណាក់ខ្លួន ទោះបីកូនសិស្សនោះចេះក៏ដោយ មិនចេះក៏ដោយ ឥតមានវេល់ មានតែពីហួងហែងម៉្យាង ។

ដល់មកខែពិសាខឆ្នាំកុរឯកស័ក អាយុខ្ញុំបាន ២០ ឆ្នាំគត់ លោកគ្រូលោករៀបចាត់ចែងបំបួសខ្ញុំ លោកនិមន្តសម្តេចព្រះមហាសង្ឃរាជសង្ឃនាយកជាព្រះឧបជ្ឈាយ៍ និមន្តលោកគ្រូព្រះមង្គលទិព្វាចារ្យ ភុយ ជាគ្រូសូត្រស្តាំ លោកគ្រូព្រះពុទ្ធវង្ស ឧដ្ឋ ជាគ្រូសូត្រខាងឆ្វេង បំបួសខ្ញុំបានឡើងឧបសម្បទជាភិក្ខុភាវ ក្នុងព្រះពុទ្ធសាសនា ក្នុងវិហារវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

ដល់ខ្ញុំបួសបាន ៣ វស្សា ទទួលគ្រោះកាចមានជម្ងឺឈឺម្តងជាទម្ងន់ ដោយអហិវាតករោគមកពាល់ត្រូវ លោកក៏ខំរកគ្រូមកមើលខ្ញុំពាល់តែបានជា ដាច់ខាតសោហ៊ុយលោកជាច្រើន ក្នុងពេលដែលខ្ញុំកំពុងឈឺនោះ លោកឃើញថាខ្ញុំមានសេចក្តីទន្ទត់ណាស់ លោកក៏មកគង់ជិតខ្ញុំហើយ លោកសម្តែងធម៌ឲ្យឱវាទដល់ខ្ញុំថា លោកកុំតក់ស្លុតពេកឡើយ រោគលោកនេះមិនជាអ្វីទេ ស្អែកៗ ជាហើយ ចូរលោកប្រុងស្មារតីចាំស្តាប់ពាក្យខ្ញុំ ៗ នឹងឲ្យឱវាទដល់លោក លោកបណ្តាសត្វកើតមកក្នុងលោកនេះរមែងមានសេចក្តីទុក្ខពាល់ត្រូវជាធម្មតា ទីងជៀសវាងមិនផុតទេ ព្រះជាគ្រូយើងព្រះអង្គទ្រង់សម្តែងថា ទុក្ខមានដល់ទៅ ១៣ កង បានជាតិទុកជាដើម

មានបញ្ចុបាទានក្ខន្ធទុក្ខ ជាបរិយោសាន តែខ្ញុំនឹងលើកយកតែទុក្ខ ៤ កង មកសម្តែង យ៉ាងសង្ខេប ៗ ឲ្យលោកស្តាប់ ដើម្បីនឹងរម្ងាប់សេចក្តីក្រវល់ក្រវាយដែលមានក្នុងសន្តានលោក ៗ

ឯទុក្ខទាំង ៤ កងនោះគឺ :

១- ជាតិទុក្ខ អធិប្បាយថា បណ្តាទុក្ខទាំងពួង ដែលកើតមានបុគ្គលគ្រប់រូបនោះ ក៏អាស្រ័យនឹងមានជាតិជាបច្ច័យ បើគ្មានជាតិកំណើតទេ ទុក្ខនឹងមកអាស្រ័យនៅនឹងអ្វីបាន បានអ្វីនឹងទាំត្រងទ្រនូវទុក្ខនោះ ហេតុដូច្នោះបានជាព្រះជាគ្រូព្រះអង្គឲ្យឈ្មោះថាជាតិទុក្ខ ទុក្ខកើតព្រោះតែមានជាតិកំណើត ៗ

២- ជរាទុក្ខ ទុក្ខកើតព្រោះសេចក្តីចាស់ជរា ១ ធ្វើឲ្យឥន្ទ្រិយគ្រាំគ្រាវិកលវិការវិបរិតប្រែប្រួលទៅផ្សេង ៗ មានធ្វើឲ្យធ្មេញបាក់ សក់ស្កូវ ថ្ពាល់ផត សាច់ស្បែកជ្រួញជ្រីវយុរយារស្វិតស្រពោន ភ្នែកងងឹត ប្រចៀកថ្លង់ជាដើម គួរឲ្យសង្វេគពេកណាស់ ជរានេះបុគ្គលទាំងឡាយមិនអាចនឹងមើលបានដោយមំសចក្ខុទេ លុះតែបុគ្គលប្រកបដោយបញ្ញាចក្ខុនោះ ទើបនឹងមើលឃើញប្រាកដ ជាក់ច្បាស់បាន ជរានេះប្រៀបឧបមាដូចភ្លើងឆេះព្រៃហើយលត់ទៅ ភ្លើងនោះកាលដែលឆេះក៏មិនបានប្រាកដ លុះនៅតែផេះនិងធ្យូង ទើបប្រាកដដល់ជនទាំងឡាយនោះ មានឧបមាដូចម្តេចមិញ ជរាទុក្ខនេះ ក៏មិនបានប្រាកដដល់ជនទាំងឡាយ មានឧបមេយ្យដូច្នោះឯង លុះតែបុគ្គលបានឃើញរូបអ្នកណា ១ មានធ្មេញបាក់

សក់ស្កូវ ថ្គាល់ផតគ្គី សាច់ស្បែកស្វិត ជ្រួញជ្រីវយុរយារ ក្អែកងឹត ត្រចៀកថ្លង់ក្តី ទើបដឹងប្រាកដថាជរាមកដល់ហើយ ពុំនោះសោតជរានោះ ដូចជាតម្បាញដែលគេត្បាញ ស្រ្តីអ្នកត្បាញសំពត់បោះត្រល់ទៅមកម្តង ១ សរសៃ ៗ ខាងមុខកាន់តែតិចទៅ ៗ ខាងក្រោយកាន់តែច្រើនឡើង ៗ នោះ មានឧបមាដូចម្តេចមិញ ជរាដែលព្យាយាមស៊ីលេបអាយុសត្វ ស៊ីលេបបន្តិចម្តង ៗ រូបកាយក៏កាន់តែក្រោមទ្រុឌទៅ ថយទៅវិនាសទៅ រាល់កាល រាល់វេលា មិនចេះឈប់ឈរ មិនចេះបង្អង់ក្នុងពេលណា ខណៈណាសោះឡើយ ក៏មានឧបមេយ្យដូច្នោះឯង ដូចអ្នកណា ១ កើតមកមានអាយុ កំណត់ ១០០ ឆ្នាំ កន្លងថ្ងៃ ១ ទៅ ក៏ខ្វះអំពី ១០០ ឆ្នាំ នោះបាន ១ ថ្ងៃ លុះកន្លងទៅបាន ១ ខែ ក៏ខ្វះអំពី ១០០ ឆ្នាំ នោះបាន ១ ខែ លុះកន្លងទៅបាន ១ ឆ្នាំ ក៏ខ្វះអំពី ១០០ ឆ្នាំ នោះបាន ១ ឆ្នាំ យ៉ាងនេះជាដើមរៀង ៗ ទៅ សេចក្តីជរាតែងបណ្តេញ បំបរបន្ថយ អាយុសត្វ ហើយគៀងប្រមូលបញ្ចូលទៅរកសេចក្តីស្លាប់ ជានិច្ចសព្វកាលមិនដែលដាច់ ជរានេះរមែងធ្វើឥន្ទ្រិយទាំង ៦ មានចក្ខុន្ទ្រិយជាដើមឲ្យសៅហ្មងល្អក់គ្រាំគ្រាអាការទាំង ៣២ មានសក់ជាដើមសោតក៏វិបរិតប្រែប្រួលទៅផ្សេង ៗ គ្រប់រូបរាំងអស់ឥតមានសល់ រូបកាយយើងរាល់គ្នានេះ មានតណ្ហាជានាយជាង ជាអ្នកតាក់តែងធ្វើឲ្យកើតឡើង ដូចជានាយជាងធ្វើផ្ទះ លុះបានជាផ្ទះហើយកាលបើមានខ្យល់ព្យុះពោល គឺជរាមកបៀតបៀនកាលណា ផ្ទះគឺអត្តភាពនេះក៏មិនអាចនឹងទប់ទល់ទ្រាំ

ទ្រស្អិតនៅបាន បេះតែគ្រាំគ្រាវិនាសទៅកល់វេលា ឥរិយាបថទាំង ៤ ទៀត ក៏ពេះតែអន់ បេះតែថយចុះជាប្រក្រតី នឹងដេកដើរ ឈរអង្គុយក៏ពីបាក ថ្ងៃបណ្តើរ ដកដង្ហើមដំបណ្តើរ ដោយទុក្ខវេទនាមិនមានល្ហែ ហេតុដូច្នោះបានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ឲ្យឈ្មោះថាជរាទុក្ខ ទុក្ខកើតមានព្រោះសេចក្តីចាស់ជរា ។

៣- ព្យាធិ ទុក្ខា ទុក្ខកើតព្រោះព្យាធិរោគាមកបៀតបៀន ព្រះបរមគ្រូទ្រង់សម្តែងថា ព្យាធិដែលកើតឡើងក្នុងរូបកាយនៃសត្វទាំងឡាយនោះ ព្រោះដោយហេតុធាតុប្រែប្រួល គឺថាជួនកាលត្រជាក់ ជួនកាលក្តៅ ធ្វើឲ្យរូបកើតសោប់សល់ ព្យាធិគឺសេចក្តីឈឺចាប់ ចានឈឺគ្រុន ឈឺក្បាលវិលមុខ ឈឺពោះជាដើម ព្យាធិនេះបៀតបៀនសត្វឲ្យដល់នូវសេចក្តីទុក្ខច្រើនប្រការណាស់ តែងបណ្តេញ បំបរ បញ្ចូនអាយុសត្វ ឲ្យទៅកាន់សេចក្តីស្លាប់ ហេតុដូច្នោះបានជាព្រះបរមលោកនាថ ទ្រង់ឲ្យឈ្មោះថាព្យាធិទុក្ខ ទុក្ខកើតព្រោះព្យាធិរោគាមកបៀតបៀន ។

៤-មរណា ទុក្ខា ទុក្ខកើតព្រោះសេចក្តីស្លាប់មកបៀតបៀន ព្រះសាស្តាទ្រង់សម្តែងថា ធម៌ទាំងឡាយគឺ ចុតិបេក់ចិត្តនៃសត្វក្តី ទំលាយខន្ធនៃសត្វក្តី ចោលបោះបង់សាកអសុភនៃសត្វក្តី ផ្តាច់បង់ជីវិតនៃសត្វក្តី ធម៌ទាំងនេះឈ្មោះថាមរណធម៌ទាំងអស់ព្រោះថាសត្វទាំងឡាយកាលបើទៀបនឹងដល់មរណកាល ហើយតែជាធាតុក្នុងសរីរកាយនោះកើតក្តៅក្រៅខ្លាំងឡើង ធ្វើឲ្យក្តៅក្រហាយពេញពលសោច់សល់សព្វកាយ ដូចជាទៅ

ជិតគំនរភ្លើង បានឈ្មោះថាមរណទុក្ខម្យ៉ាង ម្យ៉ាងទៀតបើសត្វណា បានធ្វើអកុសលកម្ម ដ៏លាមកអាក្រក់ដោយកាយជាដើម ឥតមានមេត្តាករុណា កាលបើជិតនឹងដល់មរណកាល ទុក្ខនិមិត្តក៏កើតឡើងឲ្យឃើញប្រាកដដល់សត្វនោះ គឺឲ្យឃើញភ្លើងនរកខ្លះ ជួនកាលឲ្យឃើញនាយនិរយបាលកាន់គ្រឿងសាស្ត្រាវុធ មកចោមរោមគំរាមកំហែងធ្វើទុក្ខធ្វើទោស ជួនកាលក៏ឃើញជាជ្រួលច្រវាក់ ឃើញសត្វក្អែកគ្នាតមកចោមរោមក៏សឹងមាន ម៉្លោះហើយសេចក្តីតក់ស្លុត រន្ធត់ភ្ញាក់ភ្ញាក់ភិតភ័យស្តាយជីវិត ទំរាំតែនឹងរលត់ចិត្តទៅនោះ ដោយកម្រពីបាកក្រៃពេកណាស់ ខ្លះក៏ស្រែកយំបម្រះនទៀល អន្ទះអន្ទែងទៅមក ត្រដររកខ្យល់បាត់ស្មារតី ខ្លះក៏ស្លាប់ដោយគេប្រហារនឹងគ្រឿងប្រហារផ្សេង ៗ ក៏មាន ព្រោះជាគ្រួទ្រង់ឲ្យឈ្មោះថាមរណទុក្ខ ទុក្ខកើតព្រោះសេចក្តីស្លាប់ មកបៀតបៀនសត្វទាំងឡាយរមែងខ្លាចសេចក្តីស្លាប់ជាទីបំផុត ដោយហេតុព្រោះតែស្តាយជីវិត ចង់តែរស់ទៅក្រៃពេកណាស់ វៀរលែងតែព្រះអរិយបុគ្គលមានព្រះពុទ្ធជាដើម លោកមិនមានរន្ធត់ភិតភ័យខ្លាចសេចក្តីស្លាប់ឬស្តាយជីវិតដូចសត្វដទៃគ្មាន ។

ទុក្ខទាំង ៤ ប្រការ គឺជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ នេះប្រៀបដូចជាសត្រូវ ៤ នាក់ យើងពលគ្នាប្រៀបដូចជាមនុស្សមានពៀរនឹងសត្រូវទាំង ៤ នោះ សត្រូវទាំង ៤ នោះ គិតតែស្វែងរកឧបាយនឹងព្យាបាទសម្លាប់មនុស្សដែលមានពៀរនឹងខ្លួននោះ មិនបេះក្បេប

ខ្លួននោះ មិនចេះភ្លេច សត្រូវទី ១ ចូលទៅរកមនុស្សនោះ ហើយធ្វើជាមិត្តស្និទ្ធស្នាល និយាយប្រលោមលួងលោមបញ្ជោរបញ្ឆោតបំពោតនាយអាយ ធ្វើឲ្យមនុស្សនោះទុកចិត្តស្និទ្ធស្នាលមេត្រី មនុស្សនោះក៏មិនដឹងខ្លួនថាជាសត្រូវមកបួមធ្វើឧបាយកលឡើយ ក៏លុះដោយអំណាចឧបាយកលនៃសត្រូវនោះទៅ ដោយគិតស្មានថាជាគេមានចិត្តស្មោះត្រង់រាប់អានជាមិត្តសំឡាញ់ពិតប្រាកដមែន ក៏ឆោតជឿតាមពាក្យសំដីសត្រូវនោះទៅឥតសង្ស័យ សត្រូវនោះបានដឹងថាមនុស្សនោះ ជឿស៊ប់ដោយឧបាយខ្លួនហើយ ក៏ដឹកនាំបបួលមនុស្សនោះ ដើរចូលទៅក្នុងព្រៃស្ងាត់ ដល់ហើយស្រាប់តែឃើញសត្រូវទី ២ ស្ទុះចូលមកចាប់មនុស្សនោះ វាយដំប្រំធាក់ជាទម្ងន់ ទើបសត្រូវទី ៣ ស្ទុះចូលមកជួយវាយដំបន្ថែមឲ្យជាទម្ងន់ក្រៃលែងទៅទៀត សត្រូវទី ៤ ស្រាប់តែស្ទុះមកកាត់ក្បាលមនុស្សនោះ ដោយដាវដ៏មុតថ្លាដាច់ចេញពីខ្លួនក្សណក្ស័យជីវិត ក្នុងខណៈនោះទៅ ។

ឯសត្រូវទាំង ៤ នោះ សត្រូវទី ១ គឺជាតិទុក្ខដែលជាអ្នកលលួងបញ្ឆោតយើងរាល់គ្នា ឲ្យតបដិសន្ធិ ប្រកបដោយ បញ្ចខន្ធ ថាជាទីសុខស្រួល ។

សត្រូវទី ២ គឺជរាទុក្ខ ដែលជាអ្នកជួយធ្វើយើងរាល់គ្នាឲ្យគ្រាំគ្រាថមថយកម្លាំងទៅ មានធ្វើឲ្យជ្រួញជ្រាក់ សក់ស្កូវជាដើម ។

សត្រូវទី ៣ គឺព្យាធិទុក្ខ ដែលជាអ្នកជួយធ្វើរាងកាយឲ្យរឹតតែគ្រាំគ្រាទុព្វលភាពក្រៃលែងថែមទៅទៀត ។

សត្រូវទី ៤ គឺមរណទុក្ខ ដែលជាអ្នកតែងបៀតបៀនផ្តាច់បង់ជីវិតិន្ទ្រិយនៃយើងរាល់គ្នា ។

កាលណាបើលោកគ្រូខ្ញុំ លោកសម្តែងអំពីកងទុក្ខទាំង ៤ យ៉ាង ដោយសង្ខេបចប់ស្រេចកាលណា សេចក្តីសាប់សល់ក្រវល់ក្រវាយដែលមានក្នុងកាយខ្ញុំក៏បានស្បើយក្នុងខណៈនោះទៅ ។

## នេះជាគុណូបការដ៏វិសេស ១ ។

ក្នុងឆ្នាំនោះឯង លោកនឹងនិមន្តទៅស្រុកសៀម ប្រាថ្នានឹងទៅរកជាវគម្ពីរសាស្ត្រាព្រះត្រៃបិដកភាសាបាលីជាអក្សរខ្មែរ គិតប្រុងយកខ្ញុំទៅជាមួយផង តែខ្ញុំទៅមិនរួចព្រោះទើបនឹងងើបពីឈឺ លោកក៏និមន្តទៅជាមួយ នឹងលោកឯទៀតទៅ ក៏ក្នុងសម័យដែលខ្ញុំមកនៅរៀនសូត្រនោះ សាស្ត្រាបាលីព្រះត្រៃបិដកមិនទាន់មានបរិបូណ៌នៅឡើយ មានតិចណាស់ សាស្ត្រារបស់លោកគ្រូខ្ញុំក៏មានតិចគម្ពីរ កូនសិស្សលោកច្រើន រៀនមិនគ្រប់គ្រាន់ ខ្វះសាស្ត្រាគេមករៀនខ្វះ លោកគ្រូខ្ញុំលោកខំសាងណាស់ដែរ សាងដោយជួលគេចារខ្លះ ដោយជាវគេខ្លះ នៅតែមិនល្មម បានជាលោកខំព្យាយាមនិមន្តទៅស្រុកសៀមនោះ ព្រោះស្រុកគេមានច្រើនងាយរក ស្រាប់តែទៅជាវយកមកតែម្តងជាការងាយឆាប់ទាន់ចិត្ត ដោយព្រះហឫទ័យលោកចង់ឲ្យបានកូនសិស្សរៀនដោយស្រួល ។

ដល់លោកនិមន្តត្រឡប់មកវិញ បានសាស្ត្រាប្រហែល ៣០ គម្ពីរ

យកមកទុកឲ្យសិស្សរៀនសូត្របរិបូណ៌ តាំងពីនោះមក សិស្សលោកទាំង គេ ទាំងខ្ញុំ មិនសូវព្រួយនឹងរកសាស្ត្រារៀនសូត្រទេ រូបលោកចេះតែ សាងបណ្ដើរ ៗ មកទៀតមិនចេះឈប់ឡើយ នេះជាគុណសម្បត្តិរបស់ លោកដ៏ប្រពៃ ១ ។

ដល់ខ្ញុំនៅនឹងលោកបាន ៥ វស្សា នឹកចង់ទៅស្គាល់ស្រុកសៀម នឹងគេម្ដង ទើបខ្ញុំទូលៈលោកពីសេចក្ដីបំណងរបស់ខ្ញុំនោះ លោកក៏មាន ព្រះពុទ្ធដីកាថា បើលោកចង់ទៅស្គាល់ស្រុកសៀមនោះស្រួលហើយ មិន អីទេ ចាំឆាន់ជូនទៅ ព្រោះខ្ញុំក៏ត្រូវការនឹងទៅរកជាវគម្ពីរដែរ តែថាឲ្យ លោករៀនអក្សរសៀម ភាសាសៀមឲ្យចេះខ្លះសិន រួចសឹមទៅ ទើបនឹង បានស្រួលល្អ ។

តាំងពីថ្ងៃនេះមក លោកក៏ឲ្យខ្ញុំរៀនអក្សរសៀម ភាសាសៀមពី លោក ខ្ញុំក៏ខំរៀនបាន ៥-៦ ខែ បានមើលដាច់និយាយបានខ្លះ តែមិន សូវច្បាស់ដូចលោកទេ ឯលោកបើមានព្រះពុទ្ធដីកាជាភាសាសៀម ក៏ ច្បាស់លាស់ដូចជាជាតិសៀម បណ្ដាជាតិខ្មែរដែលចេះសៀម គ្មាននរណា និយាយសៀមច្បាស់ជាងលោកទេ បើខ្លាំងណាស់គ្រាន់តែប្រហែលគ្នា ហើយនឹងថយជាងលោក ។

ដល់រដូវចេញវស្សា នោះខែកត្តិកក្នុងឆ្នាំនោះឯង លោកក៏រៀប ចំដំណើរនាំខ្ញុំទៅស្រុកសៀមតាមផ្លូវជើងគោក កាលទៅពីកាយ ទៅ សំណាក់នៅស្រុកបាត់ដំបង ១ រាត្រី ទៅពីស្រុកបាត់ដំបងទៅសំណាក់

នៅវត្តថ្វាន់ ក្នុងខែត្រមង្គលបូរី ១ កន្លែង កាលនៅ ។ វត្តនោះ ខ្ញុំមានជម្ងឺឈឺដោយពេគម្លួលជាទម្ងន់ណាស់ រៀបតែនឹងស្លាប់ហោកក៏ខំប្រឹងរកគ្រូក្នុងស្រុកគេនោះមកមើលជម្ងឺខ្ញុំទាល់តែបានជាស្បើយ ។

## ត្រង់នេះជាគុណូបការធំបំផុត ១ ។

រួចទើបលោករៀបដំណើរចេញពីស្រុកនោះ ឆ្ពោះទៅស្រុកសៀមតាមផ្លូវលើដកបទៅ ដល់បានទៅដល់ស្រុកសៀមហើយ ទៅនៅសំណាក់នៅវត្តចក្រវត្តិពជាវាស ក្នុងក្រុងបាងកកជាសុខសប្បាយ ហើយលោកទៅសុំឲ្យខ្ញុំរៀនមូលកច្ចាយនពីលោកគ្រូ ព្រះអាចារ្យ ប៊ុន ជាអាចារ្យធំក្នុងហ្នូង ។

ឯលោកគ្រូព្រះអាចារ្យ ប៊ុន នោះ លោកបង្ហាញភាសាបាលីជាន់ខ្ពស់ លោកឈប់លែងបង្ហាញមូលកច្ចាយនយូរណាស់ទៅហើយ លោកត្រូវបង្ហាញតែគម្ពីរខ្ពស់ ៗ លោកប្រកែកមិនព្រមទទួលបង្ហាញមូលនោះសោះ លោកគ្រូខ្ញុំ លោកមេត្តាដល់ខ្ញុំ លោកក៏តាំងព្យាយាមទៅសុំអង្វរលោកគ្រូព្រះអាចារ្យនោះ ទាល់តែលោកទទួលបង្រៀនខ្ញុំបាន ។

## ត្រង់នេះជាគុណូបការជាទីបំផុត ១ ។

ខ្ញុំបានរៀនមូលកច្ចាយនក្នុងសំណាក់លោកគ្រូព្រះអាចារ្យនោះ បាន ១២ ខែចប់ រួចហើយលោកគ្រូខ្ញុំ លោកនាំខ្ញុំត្រឡប់មកស្រុកខ្មែរវិញ ។

ក្នុងឆ្នាំដែលលោកនិមន្តមកពីស្រុកសៀមនោះ ព្រះករុណាជាម្ចាស់ជីវិត គឺព្រះបាទសម្តេចព្រះ នរោត្តម ទ្រង់ប្រោសព្រះរាជទានតាំងលោកឲ្យឡើងយសសក្តិជាមន្ត្រីសង្ឃទីរាជាគណៈ ទម្រង់នារជាព្រះមហាវិមលធម្ម ឿឈ ហ្វង ត្រូវមុខក្រសួងត្រួតត្រាព្រះសង្ឃក្នុងរាជនិមន្ត និង ត្រូវជំនុំជម្រះរម្ងាប់អធិករណ៍សង្ឃក្នុងស្រុកខ្មែរ តាមគណៈហើយលោកបានតាំងខ្ញុំឲ្យធ្វើបាឡាត់លោក នារជាព្រះបាឡាត់អរិយវិមល ជាជំទប់លោកសម្រាប់ជួយត្រួតត្រាការក្នុងដំណែងក្រសួងជាមួយគ្នា ។

ត្រង់នេះជាគុណូបការធំ ១ ។

ដល់មកក្នុងខែមាឃឆ្នាំ ១៩១១ រាជការត្រូវការរើសយកព្រះសង្ឃ ១ អង្គ ទៅស្រុកបារាំង លោកក៏ក្រាបទូលសម្តេចព្រះមហាសង្ឃរាជា សុំឲ្យទ្រង់ចាត់ខ្ញុំទៅស្រុកបារាំង ទ្រង់ក៏មេត្តាប្រោស ចាត់ឲ្យខ្ញុំទៅ តាមត្រូវការ ដើម្បីឲ្យខ្ញុំបានស្គាល់ស្រុកធំដែលជាមាតាបិតាស្រុកយើង ។

ដល់ខ្ញុំត្រឡប់មកពីស្រុកបារាំងវិញនៅនឹងលោកបាន ១ ឆ្នាំ លោកក៏ក្រាបទូលសម្តេចព្រះមហាសង្ឃរាជា សូមទ្រង់ថ្វាយចុតហ្មាយព្រះករុណាជាម្ចាស់ជីវិត សុំនារព្រះសីលសំវរ ទីរាជាគណៈឲ្យខ្ញុំ ។

នេះជាគុណូបការដ៏ឧត្តម ១ ។

ដល់មកឆ្នាំ ១៩១៤ លោកមោនសៀវហ្វើណូត ជាចាងហ្វាងសាលា

អេកស្ត្រែមអូរីយ៉េន ស្រុកហាណូយ លោកសុំយកខ្ញុំទៅធ្វើការជាមួយនឹងលោក លោកគ្រូខ្ញុំលោកអនុញ្ញាតឲ្យទៅតាមអធ្យាស្រ័យ ខ្ញុំទៅនៅស្រុកហាណូយបាន ១ ឆ្នាំត្រឡប់មកវិញ ទៅធ្វើការជាមួយនឹងលោកម៉ាទសៀរ ស៊ីដែស ក្នុងក្រុងភ្នំពេញបាន ១ ឆ្នាំ ក៏លាសិក្ខាបទ សឹកចេញចាកសមណភេទក្នុងចុងឆ្នាំ ១៩១៦ ដល់មកក្នុងឆ្នាំ ១៩១៧ លោកគ្រូខ្ញុំលោកជួយទំនុកបម្រុងខ្ញុំ ឲ្យបានប្រឡងចូលធ្វើជាអាចារ្យ បង្ហាញភាសាបាលីក្នុងសាលាបាលីជាន់ខ្ពស់ នៅក្រោមបង្គាប់លោក បានសេចក្ដីសុខ តាំងពីនោះដរាបមកដល់សព្វថ្ងៃនេះ ឥតមានសៅហ្មងអ្វីឡើយ ។

## នេះជាគុណូបការក្រៃលែង ១ ។

ខ្ញុំមានសេចក្ដីស្ដាយលោករកអ្វីប្រៀបឲ្យស្មើគ្មាន ខ្ញុំទុកលោកដូចជាមាតាបិតាបង្កើតខ្ញុំ ដោយហេតុខ្ញុំបានមកនៅជ្រកកោននឹងលោក ១ ក៏មេត្តាខ្ញុំ ទំនុកបំរុងសង្គ្រោះខ្ញុំ ឲ្យខ្ញុំបានចេះដឹងក្នុងផ្លូវប្រតិបត្តិផ្សេង ៗ ក្នុងព្រះពុទ្ធសាសនា ឲ្យមានកេរ្តិ៍ឈ្មោះពិរោះលោក ។

កាលដែលខ្ញុំកំពុងតែនៅរៀនសូត្រនឹងលោកនោះ លោកប្រិតប្រៀនប្រដៅខ្ញុំពីច្បាប់ល្អសព្វគ្រប់ឥតមានចន្លោះ តែខ្ញុំចាំបានខ្លះ ភ្លេចខ្លះ ហេតុនេះខ្ញុំសូមកំណត់យកតែខ្លះណា ១ ដែលខ្ញុំនៅចាំបាននោះ មកសម្ដែងឲ្យប្រាកដជាក់ស្ដែងក្នុងគ្រានេះ ។

ដំណើរហេតុ កាលខ្ញុំនៅធ្វើជាបាឡាត់ ព្រះអរិយវិមលនៅឡើយ

នោះ ក្នុងសម័យ ១ ខ្ញុំមានសេចក្ដីអផ្សុក បង់តែដើរទៅនិយាយលេងនឹងលោកសង្ឃជាមិត្ត ក្នុងវត្តឧណ្ណាលោមរឿយ ៗ លោកជ្រាបថាខ្ញុំមានកិរិយាបច្ចត្តគ្គង់ដូច្នោះ វេលាយប់ ១នោះ លោកក៏ឲ្យឱវាទដល់ខ្ញុំថា ធម្មតាធ្វើជាមនុស្សនិមួយ ៗ ត្រូវរក្សាកិរិយាមារយាទឲ្យសុភាពរៀបរយថ្លៃថ្នូរ ទើបបានឈ្មោះថាជាមនុស្ស មានលក្ខណៈល្អបរិបូណ៌ ដើម្បីកុំឲ្យអ្នកប្រាជ្ញទាំងឡាយ លោកឲ្យឈ្មោះថាជាមនុស្សខាតលក្ខណ៍ ឯខាតលក្ខណ៍នោះ មាន ៣ ប្រការ ដូចមានបាលីក្នុងគម្ពីរលោកនីតិសម្ដែងថា :

អនិមន្តនិយំគន្ធា អបុដ្ឋាបរិភាសតិ

អត្តានត្ថាបសំសន្តា តិវិធំហីនលក្ខណំ

ប្រែថាខាតលក្ខណ៍ មាន ៣ យ៉ាង គឺ ៖

១- ដែលគេមិនបានត្រូវការហៅគេឲ្យទៅផ្ទះគេ ហើយខ្លួនបេះតែទៅញយៗឥតមានអៀនខ្មាស ធ្វើឲ្យគេកើតសេចក្ដីធុញទ្រាន់ ។

២- ការអ្វីដែលគេមិនទាន់សាកសួរចំពោះខ្លួន គេមិនទាន់ឲ្យខ្លួននិយាយឆ្លើយឆ្លង ខ្លួនបេះតែឆ្លើយ បេះតែនិយាយកាត់គេ កាត់ឯងផ្ដេសផ្ដាសតាសកល នាំឲ្យគេកើតវិការទ្រួយចិត្តព្រោះសម្ដីខ្លួន ។

៣- តែនិយាយឡើងកាលណា គោលលើកសរសើរអួតតែខ្លួនឯង ហើយបន្ទាប់អ្នកដទៃឥតមានញញើត ។

ខាតលក្ខណ៍ទាំង ៣ ប្រការនេះបើមាននៅក្នុងសន្តានអ្នកណា អ្នកនោះឈ្មោះថាជាមនុស្សខាតលក្ខណ៍ ឬ ហៅថាជាមនុស្សហីនលក្ខណ៍ក៏បាន ឬ នឹងហៅថាជាមនុស្សក្មេង ជាមនុស្សល្ងើយវិញក៏សម ។

ខ្ញុំបានស្តាប់ឱវាទលោកគ្រូខ្ញុំ លោកឲ្យទានដូច្នោះហើយចាប់ដើមតាំងតែពីថ្ងៃនោះមក ខ្ញុំលែងដើរលេងផ្តេសផ្តាសតទៅ ។

## នេះជាគុណូបការដ៏ខ្ពង់ខ្ពស់ ១ ។

កាលជាខាងក្រោយមកទៀត នៅក្នុងរវាងឆ្នាំដែលធ្វើបុណ្យបូជាព្រះសពសម្តេចព្រះមហាសង្ឃរាជជា ជាម្ចាស់ សម័យនោះបណ្តាពួកលោកឋានាកជាគណសង្ឃ ក្នុងវត្តឧណ្ណាលោមក្តី វត្តឯទៀតក្តី មានលោកខ្លះបណ្តាលហេតុឲ្យជាសត្រូវនឹងលោកគ្រូខ្ញុំនោះ ខ្ញុំអត់មិនបាន ខ្ញុំចេះតែនិយាយពីឈ្មោះនោះ ដោយពិតតាមដំណើរដែលឈ្មោះនោះគេធ្វើដូចម្តេចៗខ្លះនឹងលោកគ្រូខ្ញុំ លោកគ្រូខ្ញុំ លោកបានឮខ្ញុំនិយាយដូច្នោះហើយលោកក៏មានព្រះពុទ្ធដីកាឃាត់ខ្ញុំឲ្យឱវាទខ្ញុំថា បណ្តាសត្រូវដែលថយកម្លាំងទៅលែងធ្វើអាក្រក់ដល់យើង ព្រោះយើងតាំងចិត្តមិនតបនឹងគេវិញ បើយើងតាំងអធិវាសនខន្តី មិនតតបនឹងគេវិញហើយ សេចក្តីអាឃាដរបស់សត្រូវនោះ ក៏នឹងរលាយរលត់បាត់ទៅមិនខាន បើយើងក្តៅក្រហាយ ចេះតែនិយាយពីឈ្មោះសត្រូវនោះរឿយៗទៅ គង់តែនឹងដឹងដល់គេមិនលែង គេរឹតតែក្តៅក្រហាយឡើង ខ្លាំងហើយគេតាំងព្យាយាមរកឧបាយគិតព្យាបាទយើង ដូចជាយើងយកភ្លើងទៅដុតគេ ឬ ឲ្យកម្លាំងគេ ។

លោកឲ្យឱវាទដូច្នោះហើយ ខ្ញុំក៏ពេញចិត្តទទួលត្រង់ត្រាប់ស្ដាប់យកជាច្បាប់ ។

## នេះជាគុណូបការវិសេសក្រៃ ១ ។

ឯកិរិយាលោកគ្រូខ្ញុំ ។ ធ្លាប់ចំណាំមកយូរឆ្នាំហើយ បើមានឈ្មោះណា ១ ជាទោសជាសត្រូវនឹងលោក ៗ មិនដែលពោលអាក្រក់ចេញឈ្មោះសត្រូវនោះឡើយ បើទុកជាអ្នកណាមកនាំលោកនិយាយយ៉ាងណាក្ដី លោកនៅតែស្ងៀមតក់តើយធ្ងន់ បើនិយាយពីរឿងអ្វីដែលមានប្រយោជន៍ ហើយឥតទោសផង ទើបលោកពេញព្រះហឫទ័យទទួលសន្ទនាផងដោយរួសាន់ ។

## នេះជាគណសម្បត្តិរបស់លោកដ៏វិសេស ១ ។

សម័យ ១ ទៀត មានលោកសង្ឃ ១ រូបឈ្មោះ ម៉ា បានទៅរៀនសូត្រឯស្រុកសៀម រៀនភាសាបាលីធ្វើជាអាចារ្យបង្ហាញសាស្ត្រព្រះត្រៃបិដកបានខ្លះ លោកអាចារ្យ ម៉ា នោះចូលចិត្តតែមកនិយាយលេងនឹងខ្ញុំស្ទើរតែទាំងរាល់ថ្ងៃ រាល់យប់ មកនោះទៀតក៏មិនដឹងជាពេលណាគួរពេលណាមិនគួរ ចង់មកថ្មើរណា ក៏មកថ្មើរនោះ ហើយនិយាយក៏ច្រើនឥតសាប់ឥតសារ ច្រើននិយាយតែពាក្យជាតិរឿនកថា លោកគ្រូខ្ញុំ លោកឃើញដូច្នោះ លោកក៏មិនហាមថាអ្វីឲ្យគេទេ ដល់វេលាមានឱកាសស្រួល លោកឲ្យឱវាទដល់ខ្ញុំថា ការដែលនិយាយមិនដឹងពេល មិនដឹង

វេលាចេះតែនិយាយទៅៗ នាំឲ្យខូចប្រយោជន៍ច្រើនយ៉ាងណាស់ គួរគប្បីយើងគិតនិយាយឲ្យស្គាល់កាល ស្គាល់វេលាអធ្យាស្រ័យ ហើយឲ្យបានជាប្រយោជន៍ផង ទើបប្រសើរ ត្បិតព្រះជាគ្រូយើងព្រះអង្គទ្រង់សម្តែងថា វាចាដែលបុគ្គលពោលទៅហើយឥតមានទោសនោះ មាន ៥ យ៉ាងគឺ :

១- កាលេនចភាសិតា ពោលសមគួរតាមកាលដែលគួរពោល គឺថាបើនឹងពោលប្រាប់ទៅនឹងបុគ្គលណា ត្រូវសង្កេតមើល កាលវេលាអធ្យាស្រ័យបុគ្គលនោះ កាលគួរពោលសឹមពោល កាលមិនគួរពោលកុំពោល កាលគួរពោលនោះ គឺកាលដែលគេទំនេរឥតមានកិច្ចការអ្វី ហើយគេក៏ត្រេកអរទទួលចង់ស្តាប់ពាក្យខ្លួនផង កាលដែលមិនគួរពោលនោះ គឺកាលដែលគេកំពុងតែរវល់ធ្វើការងារជាដើម ឬ គេកំពុងតែជាប់ពាក្យនិយាយនឹងអ្នកឯណា ១ ៗ

២- សច្ចាចភាសិតា បើនឹងពោលកាលណា វាចាក៏ល្អពីរោះប្រពៃវាជាប្រកបដោយធម៌ វៀរបង់នូវ វចីទុច្ចរិត ទាំង ៤ ៗ

៣- សណ្ហាចភាសិតា បើនឹងពោលកាលណា វាចាល្អិតហ្មត់ចត់ គឺថាពាក្យត្រង់ណាដែលពោលទៅហើយ អ្នកស្តាប់ ស្តាប់មិនទាន់ចូលចិត្តសេចក្តីច្បាស់លាស់នៅឡើយ នៅមានងឿងឆ្ងល់សន្ទិះសង្ស័យក៏ខំគិតរកឧបាយនាំឧទាហរណ៍ឯណានីមួយដែលកន្លងទៅហើយក្តី ដែលមាននៅក្នុងបច្ចុប្បន្ននេះក្តី ទាញយកមកប្រៀបផ្ទឹម ឧបមាឧបមេយ្យ

ពន្យល់ ឲ្យទាល់តែគេយល់ស្តាប់បានដោយងាយ ។

៤. អត្ថសញ្ហិតាភាសិតា បើទឹងពេលកាលណា ពោលតែពាក្យណា ដែលជាពាក្យមានប្រយោជន៍ ពាក្យជាច្បាប់ឲ្យបានជាតម្រាប់ល្អដល់ខ្លួនផង ដល់អ្នកស្តាប់ផង ។

៥. មេត្តចិត្តេនចភាសិតា បើទឹងពេលកាលណា ពោលប្រកបដោយមេត្តាចិត្ត គឺថាពាក្យចេញទៅយ៉ាងណា ចិត្តខាងក្នុង ក៏យ៉ាងនោះដែរ គឺល្អព្រមទាំងខាងក្នុងខាងក្រៅ មិនមានចិត្តគិតទុច្ចរិត អាក្រក់ខាងក្នុង ហើយពោលបញ្ចើតែវាចាឲ្យល្អពីរោះតែខាងក្រៅឲ្យគេជឿតាម ។

លោកគ្រូខ្ញុំ លោកឲ្យទានឱវាទដល់ខ្ញុំយ៉ាងនេះ ខ្ញុំក៏មានចិត្តសោមនស្សត្រេកអរ ទទួលប្រតិបត្តិតាមឱវាទលោករៀងមកឥតមានល្អៀង ។

## នេះជាគុណូបការដ៏ប្រសើរឧត្តម ១ ។

លោកគ្រូខ្ញុំ លោកបរិបូណ៌ដោយគុណសម្បត្តិ នឹងគុណូបការដូច្នេះ បានជាលោកប្រកបដោយកិត្តិគុណជាអ្នកប្រាជ្ញធំល្បីឮខ្ចរទៅក្នុងនានាប្រទេស ព្រមទាំងយសសក្តាបណ្តាសក្តិពេញទី មិនតែប៉ុណ្ណោះសោត កូនសិស្សលោកក៏ច្រើន បានជាអ្នកប្រាជ្ញ បណ្តាដែលមានកូនសិស្សជាអ្នកប្រាជ្ញច្រើននោះ គ្មានលោកណាមានច្រើនជាងលោកគ្រូខ្ញុំទេក្នុងជាន់នេះ ។

លោកគ្រូខ្ញុំ លោកប្រិតប្រៀនទូន្មានប្រដៅឲ្យឱវាទដល់ខ្ញុំនោះ ជាអនេកបរិយាយនឹងគណនាត្រាកប់មិនសព្វគ្រប់បើនឹងពណ៌នាគុណសម្បត្តិ

នូវគុណូបការរបស់លោក ឲ្យសព្វគ្រប់ទៅយល់ជាពិស្តារវែងឆ្ងាយណាស់ ខ្ញុំសូមពណ៌នាដោយសង្ខេបខ្លី ៗ គ្រាន់តែឲ្យបានជាទីនឹករឭក ព្រះតេជព្រះគុណ លោកតែប៉ុណ្ណោះឯង ។

ខ្ញុំសូមបញ្ចប់គុណកថាតាមសមគួរដល់កាលវេលាតែប៉ុណ្ណោះ ។

អាចារ្យ អ៊ិត ហាត់ ជាអ្នកពណ៌នា ដោយសេចក្ដីកតវេទី ពណ៌នាចប់នៅថ្ងៃ ១ រោចខែស្រាពណ៍ ឆ្នាំថោះនព្វស័កត្រូវគ្នានឹងថ្ងៃ ១៤ ខែ អាអ៊ូត ឆ្នាំ ១៩២៧ ព.ស. ២៤៧០ ។

## កតវេទិកថា

---

# ឧកញ៉ាភក្តីរាជា យុំង សម្តែងពណ៌នា

## រៀបរាប់អំពីគុណូបការ និង គុណសម្បត្តិ

## នៃ

## *ព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម ព្រះសព*

## ជាធម្មាចរិយ ដោយសេចក្តីសង្ខេប

# កតវេទិកថា

ថ្ងៃពុធ ១៤កើត ខែស្រាពណ៍ ឆ្នាំថោះនព្វស័ក

ត្រូវនឹងថ្ងៃ ១. ខែអ៊ូត ឆ្នាំ ១៩២៧

ខ្ញុំបាទឈ្មោះ យ៉ាំ ង៉ែ សារ ជាឧកញ៉ាកត្តិកជា អាយុ ៤៧ ឆ្នាំ ជាអាចារ្យបង្រៀនក្នុងសាលាបាលីជាន់ខ្ពស់ សូមពណ៌នាឧបការគុណ របស់ព្រះតេជព្រះគុណលោកគ្រូព្រះមហាវិមលធម្ម ព្រះនាមដើម ថោង ជាធម្មាចារ្យនៃខ្ញុំ ឲ្យឃើញជាក់ច្បាស់តាមសេចក្តីពិត តាមរឿងដែលលោកមានឧបការគុណ ចំពោះដល់រូបខ្ញុំដោយជាក់ស្តែង ។

ហេតុដែលខ្ញុំបាទមកធ្វើជាសិស្សលោកនោះ ដើមឡើយខ្លួនខ្ញុំអាយុ ១៧ ឆ្នាំ បួសជាសាមណេរ ជាសិស្សផ្ទាល់ព្រះអង្គ សម្តេចព្រះមហាសង្ឃរាជា គណាធិបតី សង្ឃនាយក ព្រះនាម ទៀង គង់នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

ខ្ញុំបាទរៀនព្រះបរិយត្តិធម៌ក្នុងសំណាក់សម្តេច តាំងអំពីមេសូត្រដល់មូលកច្ចាយន, សន្ធិ នាម, សមាស, ដល់កាលតមកខាងក្រោយ ខ្ញុំបាទក្រាបទូលសូមអនុញ្ញាតទៅសូមរៀនមូល តទ្ធិត, អាខ្យាត, ក្រិត, ឧណាទិ, ការក, រៀនគម្ពីរព្រះធម្មបទ, មង្គលទីបនី, សារត្ថសង្គហ, ហើយបានរៀនអក្សរសៀម រៀនភាសាសៀម អក្សរលន្នាជាបាលី អំពីលោកគ្រូ